# គោលការណ៍ណែនាំ
# សម្រាប់ការប្រើប្រាស់សៀវភៅបណ្ដុះបណ្ដាលមូលដ្ឋានគ្រឹះទាំង៣

មធ្យោបាយបំផុតដើម្បីប្រើប្រាស់សៀវភៅនេះ គឺត្រូវធ្វើតាមគម្រូនៃរបៀបដែលព្រះយេស៊ូវបានបង្ហាត់បង្រៀនអ្នកដើរតាមទ្រង់។ នេះគឺជាសេចក្ដីសង្ខេបនៃអ្វីដែលព្រះយេស៊ូវបានធ្វើដើម្បីបង្ហាត់បង្រៀនពួកគេ៖

- ព្រះយេស៊ូវបានចំណាយពេលច្រើនជាមួយអ្នកដើរតាមទ្រង់។
- ព្រះយេស៊ូវបានពិភាក្សាបទពិសោធន៍ជីវិតជាច្រើនជាមួយពួកសិស្សទ្រង់ ហើយជួយពួកគេអនុវត្តព្រះបន្ទូលនៃព្រះក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។
- ព្រះយេស៊ូវបានជួយពួកគេឲ្យយល់អំពីព្រះវរបិតា ហើយអំពីរបៀបរីកចម្រើនក្នុងភាពទំនាក់ទំនងជាមួយព្រះវរបិតា ដោយមានជំនួយមកពីព្រះវិញ្ញាណបរិសុទ្ធ។

ព្រះយេស៊ូវគ្រីស្ទមិនត្រឹមតែបានប្រទានសេចក្ដីសង្គ្រោះ សម្រាប់មនុស្សគ្រប់គ្នាក្នុងពិភពលោកប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏បានបង្រៀន និងប្រទាននូវគម្រូដ៏មានប្រសិទ្ធភាពមួយដើម្បីជួយអ្នកដទៃ ហើយចុងក្រោយ គឺដើម្បីជះឥទ្ធិពលដល់ពិភពលោកផងដែរ។ ទ្រង់បានធ្វើដូច្នេះ ដោយការផ្ដោតលើពួកសិស្សប៉ុន្មាននាក់ដែលពិតជាចង់រៀនសូត្រពីទ្រង់។ ទ្រង់គួរតែចាប់ផ្ដើមជាអង្គការធំ ឬបង្កើតសាលារៀនមួយដែលមានថ្នាក់រៀនជាច្រើនក៏បានដែរ តែផ្ទុយទៅវិញ ទ្រង់បានវិនិយោគពេលវេលា៣ឆ្នាំនៃព្រះរាជព័ន្ធកិច្ចរបស់ទ្រង់ ក្នុងជីវិតអ្នកដើរតាមទ្រង់មួយចំនួន ដោយទ្រង់បានចំណាយពេលជាច្រើនក្នុងការពិភាក្សា អធិស្ឋាន និងធ្វើការជាមួយពួកគេ។ ឥទ្ធិពលរបស់ទ្រង់លើពួកគេ បានរីកចម្រើនជាពហុគុណទូទាំងសកលលោក។

ក្រោយមក សាវ័កប៉ុលមានប្រសាសន៍ថា គាត់បានត្រាប់តាមគម្រូនៃព្រះយេស៊ូវអំពីរបៀបដែលទ្រង់បានជួយមនុស្ស (១កូរិនថូស ១០:៣១-១១:១) ហើយបន្ទាប់មក គាត់បានទូន្មានយើងឲ្យត្រាប់តាមគម្រូរបស់គាត់ក្នុងការធ្វើដូច្នោះដែរ។

នេះជាហេតុដែលសៀវភៅបណ្ដុះបណ្ដាលមូលដ្ឋានគ្រឹះទាំងបី ត្រូវបានបង្កើតឡើង។ សៀវភៅទាំងនេះគឺជាឧបករណ៍សម្រាប់ជួយមនុស្ស ឲ្យរៀនធ្វើតាមគម្រូនៃព្រះយេស៊ូវក្នុងការជួយមនុស្ស ដូចដែលបានពណ៌នាក្នុងព្រះគម្ពីរ។ ព្រះយេស៊ូវបណ្ដុះបណ្ដាលពួកសិស្សរបស់ទ្រង់ តាំងពីដើមដំបូងនៃព្រះរាជព័ន្ធកិច្ចរបស់ទ្រង់ រហូតដល់ពេលដែលទ្រង់បានចាត់ពួកគេចេញទៅធ្វើជាអ្នកដឹកនាំ ហើយនោះក៏ជាគោលបំណងនៃសៀវភៅទាំងនេះដែរ។

## របៀបធ្វើតាមគម្រូនៃព្រះយេស៊ូវតាមរយៈការប្រើប្រាស់សៀវភៅបណ្ដុះបណ្ដាលទាំងនេះ

- ***ចំណាយពេលជាមួយពួកសិស្ស។*** ត្រូវស្គាល់ពួកគេ។ បង្ហាញចិត្តគួលអាណិតសម្រាប់អ្វីដែលកំពុងកើតឡើងក្នុងគ្រប់ផ្នែកនៃជីវិតរបស់ពួកគេ ហើយរៀនស្គាល់របៀបដែលពួកគេបានលូតលាស់ឡើងក្នុងជីវិតជាមួយព្រះយេស៊ូវគ្រីស្ទ។
- ***អធិស្ឋានឲ្យបានញឹកញាប់សម្រាប់ពួកសិស្ស។*** ព្រះយេស៊ូវបានចំណាយពេលច្រើនយប់ក្នុងការអធិស្ឋាន។ ដូចគ្នាដែរ សាវ័កប៉ុលបានកត់សេចក្ដីអធិស្ឋានរបស់គាត់ជាច្រើនក្នុងគម្ពីរសញ្ញាថ្មី។ ចូរអធិស្ឋាន ហើយទូលសុំព្រះវិញ្ញាណបរិសុទ្ធជួយពួកសិស្សដែលអ្នកស្គាល់ ឲ្យគេយល់បន្ថែមអំពីព្រះ និងព្រះយេស៊ូវគ្រីស្ទ។

- *ជួយពួកសិស្សផ្ចង់ចិត្តលើការស្គាល់ព្រះកាន់តែពេញលេញ។* ជួយពួកគេឲ្យយល់ថែមទៀតអំពីព្រះ ហើយមើលឃើញអ្វីព្រះកំពុងធ្វើក្នុងគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅ។ (សៀវភៅ ទី១)
- *ជួយពួកសិស្សឲ្យដឹងរបៀបរស់នៅដោយព្រះបន្ទូលរបស់ព្រះក្នុងជីវិតរស់នៅប្រចាំថ្ងៃ។* ទូលសុំព្រះឲ្យប្រទានប្រាជ្ញាដល់អ្នកអំពីការណាមួយក្នុងព្រះបន្ទូលទ្រង់ ដែលនឹងមានប្រយោជន៍បំផុតសម្រាប់ពួកគេក្នុងពេលបច្ចុប្បន្ននៃជីវិតរបស់ពួកគេ។ នៅពេលអ្នកដឹងខ្លឹមសារនៃសៀវភៅបណ្តុះបណ្តាលមូលដ្ឋានគ្រឹះទាំងបី សៀវភៅទាំងនេះនឹងជួយអ្នកដឹងថានៅត្រង់ណាក្នុងព្រះបន្ទូលរបស់ព្រះ ដែលនឹងមានប្រយោជន៍សម្រាប់សិស្ស។ អ្នកមិនចាំបាច់ធ្វើដំណើរឆ្លងកាត់សម្ភារៈនេះតាមលំដាប់លំដោយដូចការរៀបរៀងនេះទាំងស្រុងទេ។ សៀវភៅទី២ មានអត្ថប្រយោជន៍ជាពិសេសសម្រាប់សិស្ស ដែលត្រូវអភិវឌ្ឍអត្តចរឹត និងទម្លាប់អស់មួយជីវិតរបស់ពួកគេ។ អ្នកអាចអធិស្ឋាន និងសម្រេចចិត្តថាការណាមួយដែលនឹងមានប្រយោជន៍សម្រាប់សិស្ស យោងតាមបទពិសោធន៍ដែលពួកគេកំពុងឆ្លងកាត់។
- *មានការពិភាក្សាផ្ទាល់ខ្លួនច្រើនជាមួយសិស្សម្នាក់ៗ។* ចូរពិភាក្សារឿងរ៉ាវដែលពួកគេកំពុងរៀនអំពីព្រះ។ រៀនអំពីការអភិវឌ្ឍរបស់ពួកគេក្នុងជីវិតរស់នៅជាមួយព្រះយេស៊ូវគ្រីស្ទ។ ប្រសិនបើអាច សូមរួមបញ្ចូលសិស្សម្នាក់ឬពីរនាក់ទៀតក្នុងការពិភាក្សា ដូច្នេះគ្រប់គ្នាអាចរៀនពីគ្នាទៅវិញទៅមក។
- *ធ្វើការជាមួយគ្នា និងបម្រើគ្នាទៅវិញទៅមកជាមួយពួកសិស្ស។* ចូរធ្វើគំរូដល់សិស្ស និងជួយពួកគេរៀនពីគម្រូ និងបទពិសោធន៍របស់អ្នក។
- *ធ្វើតាមការណែនាំសម្រាប់ "របៀបក្លាយជាឪពុកម្តាយខាងវិញ្ញាណ"* នៅចុងបញ្ចប់សៀវភៅទី៣។

សម្គាល់: គោលការណ៍ណែនាំទាំងនេះក៏មានអត្ថប្រយោជន៍សម្រាប់ឪពុកម្តាយក្នុងការចិញ្ចឹមបីបាច់កូនៗរបស់ពួកគេផងដែរ!

សៀវភៅ ទី១ ក្បួនតម្រា ស្ដីពីមូលដ្ឋានគ្រឹះអំពីព្រះ
គឺជាក្បួនតម្រាដំបូង ចំណោមកម្រងក្បួនតម្រាចំនួនបីក្បាល ដូចបានបង្ហាញខាងក្រោម។

## សៀវភៅ ទី១
## មូលដ្ឋានគ្រឹះអំពីព្រះ
*(សៀវភៅកិច្ចការ ដើម្បីស្គាល់ព្រះ និងព្រះគម្ពីរ)*

- ភាពធំឧត្តមរបស់ព្រះត្រូវបានបង្ហាញក្នុងប្រវត្តិសាស្ត្រ
- សេចក្តីសង្គ្រោះរបស់ព្រះ
- ព្រះរាជលក្ខណៈរបស់ព្រះ
- សេចក្តីសន្យារបស់ព្រះ

## សៀវភៅ ទី២
## មូលដ្ឋានគ្រឹះនៃការបង្ហាត់បង្រៀនរបស់ព្រះ
*(ការណែនាំអំពីការផ្តល់ឱវាទ)*

- ជំហានដំបូងៗ
- មូលដ្ឋានគ្រឹះនៃការបង្ហាត់បង្រៀនរបស់ព្រះ

## សៀវភៅ ទី៣
## មូលដ្ឋានគ្រឹះនៃគ្រួសាររបស់ព្រះ
*(គម្រូសម្រាប់គ្រួសារ និងពួកជំនុំ)*

- មូលដ្ឋានគ្រឹះនៃគ្រួសារ
- មូលដ្ឋានគ្រឹះនៃគ្រួសារខាងវិញ្ញាណ (ពួកជំនុំ)
- ជំហានដែលត្រូវអនុវត្ត សម្រាប់ការក្លាយជាឪពុកម្តាយខាងវិញ្ញាណ
- ជំហានដែលត្រូវអនុវត្ត សម្រាប់ការក្លាយជាអ្នកដឹកនាំពេញវ័យខាងវិញ្ញាណ
- ការទទួលស្គាល់ និងការប្រគល់វិញ្ញាបនបត្រ

# សេចក្ដីផ្ដើម

## បុគ្គលដែលមានឥទ្ធិពលបំផុតក្នុងប្រវត្តិសាស្ត្រ

គ្មានអ្នកណាផ្សេងទៀត ទូទាំងពិភពលោកក្នុងប្រវត្តិសាស្ត្រទាំងមូល ដែលមានឥទ្ធិពលខ្លាំងដូចព្រះយេស៊ូវគ្រីស្ទនោះទេ។ សព្វថ្ងៃនេះ ស្ទើរតែគ្រប់មនុស្សទាំងអស់នៅលើពិភពលោកទទួលស្គាល់ព្រះរាជកំណើតរបស់ទ្រង់ នៅពេលដែលពួកគេសរសេរលេខនៃឆ្នាំកំណើតរបស់ទ្រង់។ ប្រព័ន្ធកំណត់កាលបរិច្ឆេទដែលប្រើជាទូទៅបំផុតទូទាំងពិភពលោក គឺផ្អែកលើឆ្នាំប៉ាន់ប្រមាណនៃកំណើតរបស់ព្រះយេស៊ូវគ្រីស្ទ។

ចំនួនមនុស្សដែលកំណត់អត្តសញ្ញាណខ្លួនថាជាគ្រីស្ទបរិស័ទនៅលើពិភពលោក គឺមានចំនួនច្រើនជាងសាសនាដទៃទៀត។ ពួកគេភាគច្រើនយល់ខុសអំពីព្រះយេស៊ូវ ប៉ុន្តែយ៉ាងហោចណាស់ ពួកគេមានចំណាប់អារម្មណ៍ចំពោះទ្រង់។ ព្រះគម្ពីរ ដែលព្រះយេស៊ូវគ្រីស្ទជាតួឯក ជាសៀវភៅដែលត្រូវបានអានច្រើនជាងគេបំផុតក្នុងពិភពលោក ចាប់តាំងពីរោងពុម្ពត្រូវបានបង្កើតឡើង។ តាមពិត រោងពុម្ពត្រូវបានបង្កើតឡើងក្នុងគោលបំណងបោះពុម្ពច្បាប់ចម្លងគម្ពីរបន្ថែមទៀត។ គម្ពីររាប់លានច្បាប់ត្រូវបានលក់ លើសពីការប្រៀបធៀបជាមួយនឹងសៀវភៅផ្សេងទៀតក្នុងពិភពលោក។

ព្រះយេស៊ូវគ្រីស្ទមិនត្រឹមតែមានអ្នកដើរតាមច្រើនជាងមនុស្សផ្សេងទៀតនៅក្នុងប្រវត្តិសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែការបង្រៀនរបស់ទ្រង់ក៏មានអានុភាពខ្លាំងជាងមនុស្សនៅលើវេទដទៃទៀតដែរ។ កំណើតនៃសាកលវិទ្យាល័យជាច្រើននៅអឺរ៉ុប អាមេរិកខាងជើង និងអាមេរិកខាងត្បូង ត្រូវបានចាប់ផ្ដើមក្នុងគោលបំណងដើម្បីបង្រៀនព្រះគម្ពីរ។ មន្ទីរពេទ្យជាច្រើននៅទូទាំងពិភពលោកត្រូវបានចាប់ផ្ដើមដោយមនុស្សដែលមានជំនឿលើព្រះយេស៊ូវគ្រីស្ទ។ អង្គការកាកបាទក្រហម (ឈើឆ្កាងក្រហម) ដែលមានសាខាជាច្រើន បានផ្ដល់ជំនួយនៅទូទាំងពិភពលោក។ ដើមកំណើតរបស់អង្គការនេះបានមកពីពួកគ្រីស្ទាន ដែលបានទទួលស្គាល់ព្រះយេស៊ូវគ្រីស្ទថាជាព្រះអង្គសង្គ្រោះដ៏ អស្ចារ្យបំផុតនៃពិភពលោក ហើយជារឿយៗ ឈើឆ្កាងត្រូវបានគេតាំងជាតំណាង ដែលជានិមិត្តសញ្ញានៃរបៀបដែលទ្រង់បានប្រទានព្រះជន្មរបស់ទ្រង់សម្រាប់មនុស្សជាតិទាំងអស់។

## បុគ្គលដែលពិសេសបំផុតក្នុងប្រវត្តិសាស្ត្រ

ព្រះយេស៊ូវគ្រីស្ទមិនត្រឹមតែមានឥទ្ធិពលខ្លាំងបំផុតក្នុងពិភពលោកប៉ុណ្ណោះទេ ទ្រង់ថែមទាំងជាបុគ្គលដែលពិសេសបំផុតក្នុងពិភពលោកផងដែរ។ ទ្រង់បានទាយទុកមុនអំពីរបៀបដែលទ្រង់នឹងត្រូវបានធ្វើគុត ថាតើទ្រង់ត្រូវសុគតយូរប៉ុណ្ណា និងពេលណាដែលទ្រង់នឹងរស់ឡើងវិញ។ មិនដែលមានអ្នកណាក្នុងប្រវត្តិសាស្ត្រដែលអាចធ្វើដូច្នោះបានឡើយ។

ទ្រង់មិនត្រឹមតែបានរស់ឡើងវិញ តាមការទាយទុកមុនរបស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែព្រះយេស៊ូវគ្រីស្ទថែមទាំងបានអះអាងថាទ្រង់គឺជាព្រះ ជាអ្នកបង្កើតពិភពលោក ដែលបានយាងមកយកភាពជាមនុស្ស។ ដើម្បីបង្ហាញឲ្យឃើញព្រះចេស្ដាទ្រង់ ព្រះយេស៊ូវបានប្រោសអស់អ្នកដែលត្រូវបាននាំមកឯទ្រង់ ឲ្យជាសះស្បើយពីជំងឺគ្រប់មុខ បណ្ដេញចេញអស់ទាំងវិញ្ញាណអាក្រក់ ធ្វើឲ្យមានអាហារយ៉ាងសម្បើមចេញពីភាពគ្មានធនធាន ត្រួតត្រាអាកាសធាតុ ព្រមទាំងជ្រាបដឹងគំនិតរបស់មនុស្សផងដែរ។ មិនដែលមានអ្នកណាក្នុងប្រវត្តិសាស្ត្រដែលបានអះអាងខ្លួនឯងថាជាព្រះ ជាអ្នកបង្កើតពិភពលោក ហើយថែមទាំងបានទាយអំពីការរស់ឡើងវិញរបស់ទ្រង់ ដើម្បីបង្ហាញថាទ្រង់មានអំណាចលើសេចក្ដីស្លាប់ ដែលជាសត្រូវធំបំផុតនៃមនុស្សគ្រប់គ្នា។

ព្រមជាមួយនឹងការអះអាងរបស់ព្រះយេស៊ូវថាជាព្រះ ទ្រង់ក៏បានពន្យល់ផងដែរថាគ្រប់ទាំងបទគម្ពីរដែលបានចែងមុនកំណើតរបស់ទ្រង់ សុទ្ធតែត្រូវបានកត់ទុកមកដើម្បីព្យាករណ៍ពីការយាងមករបស់ទ្រង់ ហើយដើម្បីរៀបចំពិភពលោកសម្រាប់ការយាងមករបស់ទ្រង់។ អាចនិយាយម្យ៉ាងទៀតថា ព្រះយេស៊ូវគ្រីស្ទបានអះអាងថាទ្រង់គឺជាតួអង្គឯកដ៏កំពូលនៃប្រវត្តិសាស្រ្ត ហើយទ្រង់មានព្រះបន្ទូលទៀតដែរថា ទ្រង់ក៏នឹងធ្វើជាចំណុចកំពូលនៃប្រវត្តិសាស្រ្តក្នុងពេលអនាគត នៅពេលព្រះអង្គយាងត្រឡប់មកពិភពលោកវិញ ក្នុងនាមជាអ្នកដឹកនាំកំពូលនៃពិភពលោក ដូចបានពន្យល់ស្រាប់ក្នុងព្រះគម្ពីរ។

## ព្រះគម្ពីរគឺជាសៀវភៅដ៏វិសេសបំផុត

តួអង្គសំខាន់បំផុតក្នុងព្រះគម្ពីរគឺជាព្រះយេស៊ូវ ហើយព្រះគម្ពីរផ្ទាល់គឺជាសសៀវភៅដ៏វិសេសបំផុតលើសជាងអស់ទាំងសៀវភៅ។

- ព្រះគម្ពីរត្រូវបានចងក្រងអស់រយៈពេលប្រមាណជា ២០០០ឆ្នាំ ដោយមនុស្សជាង៣០នាក់ ប៉ុន្តែឥតមានការប្រឆាំងគ្នាណាក្នុងនោះ ឬជាមួយប្រវត្តិសាស្រ្តជាក់ស្តែង និងវិទ្យាសាស្រ្តឡើយ។
- គុណភាព និងបរិមាណនៃការបកប្រែ គឺស្មើគ្នា ឬថែមទាំងវិសេសជាងសំណេរដទៃទៀតពីជំនាន់តំណាលគ្នានោះ។ សេចក្តីនៃសាក្សីផ្ទាល់ភ្នែក និងការរក្សាឯកសារអំពីតួអង្គឯក គឺព្រះយេស៊ូវគ្រីស្ទ គឺត្រូវគ្នាបេះបិតទៅនឹងឯកសារដើម ហើយក៏មានបរិមាណច្រើនជាងគេលើសអស់ទាំងសេចក្តីទាំងឡាយផ្សេងទៀតពីអំឡុងពេលដំណាលគ្នានោះ (០-១០០ នៃគ.ស.)។
- សេចក្តីចម្លងជាច្រើននៃចំណែកធំៗរបស់ព្រះគម្ពីរ ដែលមានអាយុកាលជាង២០០០ឆ្នាំ គឺនៅមានក្នុងសារៈមន្ទីរ ដែលសេចក្តីទាំងអស់នោះស្របគ្នាជាមួយការបកប្រែបច្ចុប្បន្ន ដែលបង្ហាញពីភាពអាចទុកចិត្តបានដោយគ្មានការប្រែប្រួលនៃខ្លឹមសារដើម។
- ព្រះគម្ពីរត្រូវបានបង្កើតឡើងជាការបរិយាយអំពីរបៀបដែលព្រះបានធ្វើការទូទាំងប្រវត្តិសាស្រ្ត ហើយវាស្របគ្នាជាមួយនឹងប្រវត្តិសាស្រ្តដែលត្រូវបានបញ្ជាក់ជាការពិតទាំងអស់។
- ព្រះគម្ពីរមានពេញដោយការព្យាករណ៍អំពីព្រឹត្តិការណ៍អនាគតជាច្រើន អំពីរដ្ឋាភិបាល ដែលទាំងអស់សុទ្ធតែបានកើតឡើង ហើយក៏មានរួមបញ្ចូលទាំងការព្យាករណ៍មិនធម្មតាទាំងឡាយ អំពីជាតិសាសន៍ដែលព្រះយេស៊ូវបានប្រសូត្រនិងធំឡើងក្នុងនោះ ហើយដែលកំពុងតែកើតឡើងបច្ចុប្បន្ន។

## ជីវិតផ្លាស់ប្រែ

វាជារឿងគួរឲ្យភ្ញាក់ផ្អើល ដែលជីវិតមនុស្សជាច្រើនត្រូវបានបំផ្លាស់បំប្រែដោយសារទំនាក់ទំនងផ្ទាល់ខ្លួនជាមួយបុគ្គលដ៏ពិសេសនេះ។ អ្នកដើរតាមដំបូងៗរបស់ព្រះយេស៊ូវគ្រីស្ទបានរៀងសូត្រសេចក្តីជាច្រើនពីទ្រង់ ហើយបានឃើញទ្រង់ធ្វើការអស្ចារ្យជាច្រើន។ ពួកគេបានការជម្រុញទឹកចិត្តជាខ្លាំងដោយសារអ្វីដែលព្រះយេស៊ូវមានព្រះបន្ទូល ប៉ុន្តែនៅពេលដែលពួកគេបានឃើញមេដឹកនាំរបស់ពួកគេចាប់ខ្លួនទ្រង់ និងធ្វើទារុណ្ណកម្មទ្រង់ ពួកគេបានបាត់បង់ការជម្រុញទឹកចិត្តលែងចង់ប្រាប់គេថាពួកគេគឺជាអ្នកដើរតាមទ្រង់ ហើយបានបះបង់ទ្រង់ចោល។ ទោះបីយ៉ាងណា ពួកគេបានផ្លាស់ប្រែវិញភ្លាម បន្ទាប់ពីព្រះយេស៊ូវបានលេចមកឲ្យពួកគេឃើញម្តងហើយម្តងទៀត ក្នុងព្រះកាយរបស់ទ្រង់ដែលបានរស់ពីសុគតឡើងវិញ អស់រយៈពេលសែសិបថ្ងៃ ហើយថែមទាំងបានសោយអាហារជាមួយពួកគេផងដែរ។ ចុងក្រោយ បន្ទាប់ពីពួកគេបានមើលឃើញទ្រង់យាងឡើងទៅលើមេឃ ការគិតរបស់ពួកគេពិតជាត្រូវបានបំផ្លាស់បំប្រែទាំងស្រុង ទើបពួកគេបានក្លាយជាអ្នកសង្រួបសង្រួមសម្រាប់ទ្រង់ សូម្បីដល់ថ្នាក់ពួកគេត្រូវស្លាប់ដោយសារអស់អ្នកដែលប្រឆាំងនឹងពួកគេក៏ដោយ

ព្រោះពួកគេមិនព្រមប្រែក្រឡះទីបន្ទាល់របស់ពួកគេដែលថាពួកគេបានឃើញព្រះយេស៊ូវគ្រីស្ទរស់ពីសុគត ឡើងវិញខាងរូបកាយនៅថ្ងៃទីបីក្រោយការសុគតរបស់ទ្រង់។

លោកប៉ុល ដែលធ្លាប់ជាសត្រូវរបស់ព្រះយេស៊ូវគ្រីស្ទ បានផ្លាស់ប្រែដោយសារការបានឃើញព្រះយេស៊ូវគ្រីស្ទ ដោយផ្ទាល់ក្នុងព្រះកាយដែលបានរស់ឡើងវិញរបស់ទ្រង់។ បន្ទាប់មក លោកប៉ុលបន្តក្លាយជាមិត្តជាមួយអ្នក ដើរតាមព្រះយេស៊ូវគ្រីស្ទដទៃទៀត ហើយក៏បានសរសេរសេចក្តីបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ ដែលត្រូវយក ទៅអនុវត្តដោយមនុស្សគ្រប់គ្នាក្នុងពិភពលោក។

## ចម្លើយចម្បងបំផុតទៅកាន់បញ្ហាទាំងឡាយនៃពិភពលោក

ព្រះយេស៊ូវគ្រីស្ទបានអះអាងថាទ្រង់គឺជាចម្លើយទៅកាន់បញ្ហានៃពិភពលោក ហើយអ្នកដើរតាមទ្រង់បានជឿ ជាក់លើការនេះយ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទគឺជាដំណោះស្រាយដ៏ស៊ីជម្រៅ និងល្អិតល្អន់បំផុត ទៅកាន់ គ្រប់អស់ទាំងទិដ្ឋភាពនៃភាពខ្វិចខ្វាំក្នុងគ្រប់ផ្នែកនៃពិភពលោក។

តើមនុស្សរកឃើញជំនួយដ៏មានអំណាចបំផុតសម្រាប់ជីវិតផ្ទាល់ខ្លួនរបស់ពួកគេ និងសម្រាប់សេចក្តីត្រូវការនៃ ពិភពលោកដោយរបៀបណា? ការពន្យល់ដ៏ពេញលេញត្រូវបានរកឃើញក្នុងព្រះគម្ពីរ ដូចជាព្រះយេស៊ូវគ្រីស្ទ បានបង្រៀននៅពេលទ្រង់គង់នៅលើផែនដីនេះក្នុងរូបសាច់ទ្រង់។ សេចក្តីពិតជាមូលដ្ឋានគ្រឹះសម្រាប់គ្រប់ អស់ទាំងជីវិតគឺត្រូវបានរកឃើញក្នុងព្រះគម្ពីរ ហើយព្រះយេស៊ូវបានពន្យល់ថាព្រះវិញ្ញាណនៃព្រះនឹងជួយ ឲ្យមនុស្ស ម្នាក់ៗយល់សេចក្តីពិត។

## របៀបដែលអ្នកនឹងបានផ្លាស់ប្រែ

ដូចពួកសិស្ស និងសាវ័កប៉ុលដែរ កាលណាអ្នកកាន់តែយល់ថាតើព្រះយេស៊ូវគ្រីស្ទជានរណា និងព្រះជា នរណា ហើយកាលណាអ្នកកាន់តែចុះចូលនឹងសេចក្តីពិតរបស់ទ្រង់កាន់តែច្រើន នោះការគិតរបស់អ្នកនឹង កាន់តែផ្លាស់ប្រែ ហើយជីវិតរបស់អ្នកកាន់តែផ្លាស់ប្រែ។ កាលណាអ្នកសញ្ជឹងគិតពីការពិតនៃព្រះកាន់តែច្រើន ជាពិសេសដូចដែលបានបើកសម្តែងតាមរយៈព្រះយេស៊ូវគ្រីស្ទ នោះអ្នកនឹងកាន់តែក្លាយជាមនុស្សដែលខុស ពីមុន។ លោកប៉ុលបានសរសេរនៅក្នុង ២កូរិនថូស ៣:១៨ ថា «ហើយយើងរាល់គ្នាទាំងអស់ ដែលកំពុងតែ រំពឹងមើលសិរីល្អព្រះអម្ចាស់ ទាំងមុខទទេ ដូចជាឆ្លុះមើលទ្រង់ក្នុងកញ្ចក់ យើងកំពុងតែផ្លាស់ប្រែទៅ ឲ្យដូចជា រូបឆ្លុះនោះឯង ពីសិរីល្អទៅដល់សិរីល្អ គឺដោយសារព្រះអម្ចាស់ដ៏ជាព្រះវិញ្ញាណ»។ (ពីព្រះគម្ពីរបកប្រែចាស់ ឆ្នាំ១៩៥៤)

មនុស្សខ្លះរីករាយនឹងព្រះយេស៊ូវគ្រីស្ទជាព្រះអង្គសង្គ្រោះរបស់ពួកគេ ហើយពួកគេរីករាយនឹងការអានរឿងអំពី ព្រះជន្មរបស់ទ្រង់ ប៉ុន្តែពួកគេមិនបានដឹងថាព្រះយេស៊ូវក៏ជាគម្រូសម្រាប់របៀបមានអាពាហ៍ពិពាហ៍ប្រកប ដោយសេចក្តីស្រឡាញ់នោះទេ។ គ្រីស្ទបរិស័ទឯទៀតមិនបានដឹងថាព្រះយេស៊ូវជាគម្រូសម្រាប់ការជួយ មនុស្សម្នាក់ទៀតឲ្យក្លាយជាគ្រីស្ទបរិស័ទដែរទេ ហើយមនុស្សជាច្រើនមិនបានដឹងថាព្រះយេស៊ូវជាគម្រូ សម្រាប់ការចាប់ផ្តើមព្រះវិហារទេ! តាមពិត ព្រះយេស៊ូវគឺជាគម្រូដ៏សំខាន់បំផុតសម្រាប់គ្រប់ទិដ្ឋភាពនៃជីវិត របស់យើង!

- ទ្រង់គឺជាគម្រូសម្រាប់គ្រប់ទាំងទំនាក់ទំនងប្រកបដោយក្តីស្រឡាញ់។
- ទ្រង់គឺជាគម្រូសម្រាប់ភាពជាអ្នកដឹកនាំ។
- ទ្រង់គឺជាគម្រូសម្រាប់ការជួយគ្នា និងការបម្រើ។

- ទ្រង់គឺជាគម្រូសម្រាប់ការធ្វើការ និងការវិនិយោគទុន។
- ទ្រង់គឺជាគម្រូសម្រាប់ការអប់រំ។

## ឧបករណ៍ដើម្បីជួយអ្នកឲ្យស្គាល់ព្រះយេស៊ូវគ្រីស្ទ

ដើម្បីជួយណែនាំអ្នកក្នុងដំណើរជីវិតដ៏អស្ចារ្យនៃការស្គាល់ព្រះ តាមរយៈព្រះយេស៊ូវគ្រីស្ទ សៀវភៅណែនាំស្ដីពីបណ្ដុះបណ្ដាលចំនួនបីក្បាលត្រូវបានបង្កើតឡើង។ សៀវភៅទាំងបីនេះត្រូវបានហៅថា មូលដ្ឋានគ្រឹះ (The Basics)។ ទាំងបីក្បាលគឺដូចជាស្ពានសម្រាប់ស្គាល់ព្រះ និងព្រះយេស៊ូវគ្រីស្ទ តាមរយៈព្រះគម្ពីរ។

- សៀវភៅទី១ «**មូលដ្ឋានគ្រឹះអំពីព្រះ**» ជួយអ្នកឲ្យស្គាល់ថាតើ***ព្រះជានរណា*** ហើយ ***តើទ្រង់បានធ្វើអ្វីខ្លះសម្រាប់យើង*** ដូចដែលបានបើកសម្ដែងក្នុងព្រះគម្ពីរ។
- សៀវភៅទី២ «**មូលដ្ឋានគ្រឹះអំពីការបង្ហាត់បង្រៀនរបស់ព្រះ**» ជួយអ្នកឲ្យស្គាល់ថាតើ ***ព្រះកំពុងបង្រៀនអ្វីខ្លះ*** ហើយ ***តើព្រះយេស៊ូវបានធ្វើគម្រូអ្វីខ្លះសម្រាប់អ្នក*** ដូចបានបើកសម្ដែងក្នុងព្រះគម្ពីរ។
- សៀវភៅទី៣ «**មូលដ្ឋានគ្រឹះអំពីគ្រួសាររបស់ព្រះ**» ជួយអ្នកឲ្យយល់***បរិស្ថានរបស់ព្រះសម្រាប់ការបង្រៀន និងបណ្ដុះបណ្ដាលអ្នក។*** នេះគឺជាគ្រួសារខាងរូបកាយ និងគ្រួសារខាងវិញ្ញាណរបស់អ្នក ដូចដែលបានពន្យល់ក្នុងព្រះគម្ពីរ។

សៀវភៅបណ្ដុះបណ្ដាលទាំងបីនេះនាំអ្នកទៅកាន់ព្រះគម្ពីរ និងអ្វីដែលគម្ពីរចែងអំពីព្រះ និងកិច្ចការរបស់ទ្រង់នៅក្នុងពិភពលោក។ ព្រះបានផ្ដល់ឲ្យយើងនូវអ្វីគ្រប់យ៉ាងដែលយើងត្រូវដឹង សម្រាប់ការរស់នៅយ៉ាងពេញលេញ និងពោរពេញដោយភាពរីករាយបំផុតដែលអាចធ្វើទៅបាន នៅក្នុងពិភពលោកនេះ។ នៅត្រង់ចំណុចកណ្ដាលនឹងតែងតែជាទំនាក់ទំនងប្រកបដោយសេចក្ដីស្រឡាញ់ជាមួយព្រះយេស៊ូវគ្រីស្ទ។

ទ្រង់គឺជាប្រភពនៃជីវិតរបស់អ្នកក្នុងគ្រប់ផ្លូវទាំងអស់ - ផ្លូវកាយ វិញ្ញាណ អារម្មណ៍ និងផ្លូវចិត្ត។

# សៀវភៅ ទី១

# មូលដ្ឋានគ្រឹះអំពីព្រះ

## របៀបដែលអ្នកនឹងស្គាល់ព្រះតាមរយៈ “មូលដ្ឋានគ្រឹះអំពីព្រះ”។

ក្នុងអស់ទាំងភាពធំឧត្តមរបស់ទ្រង់ ព្រះអាទិករនៃយើងបានប្រទានដល់យើងនូវព្រះគម្ពីរ ដែលមានភាពចម្រុះគ្នានៃដំណើររឿងដែលពណ៌នាអ្វីដែលទ្រង់បានធ្វើក្នុងជីវិតរបស់មនុស្ស រួមជាមួយសេចក្តីណែនាំជាច្រើនប្រភេទ។ កាលណាយើងយល់ដំណើររឿងទាំងនេះដែលព្រះបានធ្វើក្នុងប្រវត្តិសាស្ត្រនៃអតីតកាល យើងរៀនស្គាល់បន្ថែមទៀតអំពីភាពធំឧត្តមរបស់ទ្រង់ ហើយសេចក្តីពិតជាមូលដ្ឋានគ្រឹះថាតើទ្រង់ជានរណា និងរបៀបដែលទ្រង់ធ្វើការជាមួយមនុស្ស។ ខណៈពេលដែលអ្នក ឬមនុស្សណាម្នាក់ សម្របការគិតរបស់អ្នក និងបែបផែនជីវិតរបស់អ្នក យោងតាមសេចក្តីពិតអំពីព្រះជានរណា នោះអ្នកនឹងកាន់តែបានស្កប់ចិត្តក្នុងគ្រប់ទាំងផ្លូវ។ សមត្ថភាពរបស់អ្នកដើម្បីស្រឡាញ់ អំណាររបស់អ្នក និងសេចក្តីសុខសាន្តរបស់អ្នក នឹងកាន់តែពោរពេញជាងមុន។ កាលណាអ្នកកាន់តែយល់អំពីព្រះជានរណា ក្នុងគ្រប់ទាំងព្រះរាជលក្ខណៈរបស់ទ្រង់ ហើយក្នុងសេចក្តីសន្យាដែលទ្រង់បានប្រទាន នោះអ្នកនឹងកាន់តែស្រឡាញ់ទ្រង់ ហើយចង់សម្របជីវិតរបស់អ្នកដល់ទ្រង់។ ទន្ទឹមគ្នានោះដែរ ទំនាក់ទំនងរបស់អ្នកជាមួយមនុស្សក៏នឹងបានបំផ្លាស់បំប្រែលើសជាអ្វីដែលអ្នកធ្លាប់មានបទពិសោធន៍ពីមុនមក។

ការបំផ្លាស់បំប្រែនៃកើតឡើងនៅពេលអ្នកស្គាល់ព្រះក្នុងគ្រប់ទិដ្ឋភាពនៃភាពធំឧត្តមរបស់ព្រះ។ សេចក្តីនេះត្រូវបានរៀបរាប់បង្ហាញទៅតាមរបៀបខុសៗគ្នាដែលព្រះបានបើកសម្តែងអង្គទ្រង់។ មានបួនផ្នែក ដូចដែលបានរៀបរាប់នៅទីនេះ។

**មូលដ្ឋានគ្រឹះអំពីព្រះ**

១. ភាពធំឧត្តមរបស់ព្រះត្រូវបានបង្ហាញក្នុងប្រវត្តិសាស្ត្រ
២. សេចក្តីសង្គ្រោះរបស់ព្រះ
៣. ព្រះរាជលក្ខណៈរបស់ព្រះ
៤. សេចក្តីសន្យារបស់ព្រះ

## សេចក្តីណែនាំ

ខណៈពេលដែលលោកអ្នកសិក្សាផ្នែកទីមួយ ដែលមានចំណងជើងថា “ភាពធំឧត្តមរបស់ព្រះ ត្រូវបានបង្ហាញក្នុងប្រវត្តិសាស្ត្រ” (ដែលជាការសិក្សាពីព្រឹត្តិការណ៍ និងមនុស្សនៅក្នុងព្រះគម្ពីរ) អ្នកនឹងបានឃើញជានិច្ច ថាតើព្រះជានរណា និងអ្វីខ្លះដែលទ្រង់បានធ្វើ។ អ្នកអាចសរសេរការសង្កេតទាំងនេះ នៅក្នុងផ្នែកដែលមានចំណងជើងថា "សេចក្តីសង្គ្រោះរបស់ព្រះ" "ព្រះរាជលក្ខណៈរបស់ព្រះ" និង "សេចក្តីសន្យារបស់ព្រះ" ។ ផ្នែកនីមួយៗ ត្រូវបានគូសបញ្ជាក់នៅក្នុង “មាតិកានៃសៀវភៅតម្រានេះ”។

នៅក្នុង“ មាតិកានៃសៀវភៅតម្រានេះ” អ្នកនឹងសម្គាល់ឃើញពាក្យថា “ទំព័រ” ត្រូវបានបោះពុម្ព ដោយមានទុកចន្លោះទទេបន្ទាប់ពីវា។ បន្ទាត់ទទេទាំងនេះ គឺសម្រាប់អ្នក សរសេរលេខទំព័រ ដែលចំណងជើងនោះ ត្រូវ

បានបោះពុម្ព នៅក្នុងសៀវភៅនេះ។ នេះនឹងជួយអ្នក រកទំព័រដើម្បីសរសេរការសង្កេតរបស់លោកអ្នក អំពីព្រះ នៅពេលអ្នកកំពុងអាន និងសិក្សាព្រះគម្ពីរ។

នៅទំព័របន្ទាប់ នៃជាតុនីមួយៗ នៅក្នុងផ្នែក "សេចក្ដីសង្គ្រោះរបស់ព្រះ" "ព្រះរាជលក្ខណៈរបស់ព្រះ" និង "សេចក្ដីសន្យារបស់ព្រះ" មានចន្លោះទំនេរធំៗ។ កន្លែងទំនេរទាំងនេះ គឺជាកន្លែងដែលអ្នក នឹងសរសេរការសង្កេតរបស់អ្នក អំពីព្រះ ខណៈពេលដែលអ្នកសិក្សាព្រឹត្តិការណ៍ និងមនុស្សនៅក្នុងផ្នែក "ភាពធំឧត្តមរបស់ព្រះ ដែលបានបង្ហាញ នៅក្នុងប្រវត្តិសាស្ត្រ" ។

ឧទាហរណ៍ ព្រឹត្តិការណ៍ដំបូង ដែលបានបរិយាយនៅក្នុងផ្នែក "ភាពធំឧត្តមរបស់ព្រះ ដែលបានបង្ហាញនៅក្នុងប្រវត្តិសាស្ត្រ" គឺ "ការបង្កើត"។ លោកុប្បត្តិ ១ - ២ ត្រូវបានផ្ដល់មក សម្រាប់ការអាន។ នៅក្នុងខដំបូង លោកុប្បត្តិ ១:១ អ្នកអានសេចក្ដីដែលបានចែងថា "ព្រះបានបង្កើតផ្ទៃមេឃនិងផែនដី"។ នេះគឺជាសេចក្ដីថ្លែងការណ៍ អំពីព្រះ។ តើអ្នកឃើញអ្វីខ្លះ អំពីព្រះ នៅក្នុងសេចក្ដីដែលបានចែងនេះ? អ្នកឃើញថា ទ្រង់មានព្រះចេស្ដាបង្កើត បង្កើត។ តើអ្នកអាចសរសេរ ការសង្កេតនេះ នៅទីណា? អ្នកនឹងមើលនៅក្នុងផ្នែក "ព្រះរាជលក្ខណៈរបស់ព្រះ" ពីព្រោះការសង្កេតនេះ មិនទាក់ទងដោយផ្ទាល់ ទៅនឹង "សេចក្ដីសង្គ្រោះរបស់ព្រះ" ឬ" សេចក្ដីសន្យារបស់ព្រះ" ។ ហើយនៅពេលអ្នកត្រឡប់ ទៅផ្នែកដែលមានចំណងជើងថា "ព្រះរាជ លក្ខណៈរបស់ព្រះ" អ្នកនឹងឃើញតារាងព្រះរាជលក្ខណៈដប់យ៉ាងផ្សេងៗគ្នា នៃព្រះរាជលក្ខណៈរបស់ព្រះ ដែលមានក្នុងទម្រង់សំណួរ។ តារាងទីមួយគឺ "១. តើព្រះ មាន*ព្រះចេស្ដា* ប៉ុណ្ណា?" នេះគឺជាប្រភេទ ដែលលោកអ្នកផ្អែកការសង្កេតរបស់អ្នក លើ លោកុប្បត្តិ ១:១ - ដែលថា ព្រះមានព្រះចេស្ដានឹងបង្កើត។ ឥឡូវ បង្វែរទំព័រទៅកន្លែងដែលអ្នកឃើញ "១. តើព្រះមានព្រះចេស្ដាប៉ុន្មាន?" ដែលត្រូវបានបោះពុម្ព នៅផ្នែកខាងលើ ដោយមានចន្លោះទទេធំមួយ នៅពីក្រោមវា។ នេះជាកន្លែងដែលអ្នក អាចសរសេរការសង្កេតរបស់អ្នក អំពីព្រះ ហើយកត់ត្រាលេខខយោង លោកុប្បត្តិ ១:១ ដោយមានមតិបន្ទាប់ពីនោះ ដូចជា "ព្រះមានសមត្ថភាពបង្កើត" ។

អ្នកនឹងអនុវត្តតាមរបៀបដូចគ្នានេះ សម្រាប់ការសង្កេតផ្សេងទៀត អំពីព្រះជាស់ ដែលអ្នកនឹងធ្វើអំពីព្រះគម្ពីរ។ ការសង្កេតខ្លះ នឹងបរិយាយអំពីព្រះរាជលក្ខណៈផ្សេងទៀតរបស់ព្រះ ហើយការសង្កេតខ្លះទៀត ចែងអំពី "សេចក្ដីសន្យារបស់ព្រះ" ឬអំពី "សេចក្ដីសង្គ្រោះរបស់ព្រះ" ។

## មាតិកានៃក្បួនតម្រា សៀវភៅទី ១ មូលដ្ឋានគ្រឹះអំពីព្រះ


**សេចក្តីសង្គ្រោះរបស់ព្រះ** ... ទំព័រ ____

១. បញ្ហារបស់មនុស្ស ... ទំព័រ ____

២. ភាពមិនគ្រប់គ្រាន់របស់មនុស្ស ... ទំព័រ ____

៣. ការផ្គត់ផ្គង់របស់ព្រះ ... ទំព័រ ____

៤. ការឆ្លើយតបរបស់មនុស្សចំពោះព្រះ ... ទំព័រ ____

៥. ការធានារបស់ព្រះ ដល់ប្រជារាស្ត្ររបស់ទ្រង់ ... ទំព័រ ____

**ព្រះរាជលក្ខណៈរបស់ព្រះ** ... ទំព័រ ____

១. ទំហំនៃ*ព្រះចេស្តា* របស់ព្រះ...ទំព័រ ____

២. ទំហំនៃ*ព្រះវត្តមាន* របស់ព្រះ...ទំព័រ ____

៣. ទំហំនៃ*សេចក្តីស្រឡាញ់* របស់ព្រះ...ទំព័រ ____
(រួមទាំង *សេចក្តីមេត្តា ករុណា* និង*ព្រះគុណ* របស់ទ្រង់)

៤. ទំហំនៃ*សព្វញ្ញុញាណ* របស់ព្រះ ... ទំព័រ ____

៥. ទំហំនៃ*យុត្តិធម៌* របស់ព្រះ...ទំព័រ ____

៦. ទំហំនៃ*ការគ្រប់គ្រង* និង*អធិបតេយ្យភាព* របស់ព្រះ ... ទំព័រ ____

៧. ទំហំនៃ*ភាពមិនចេះប្រែប្រួល* របស់ព្រះ...ទំព័រ ____

៨. ទំហំនៃ*ភាពស្មោះត្រង់* របស់ព្រះ...ទំព័រ ____

៩. ទំហំនៃ*ភាពគ្រប់លក្ខណ៍* និង*ភាពបរិសុទ្ធ* របស់ព្រះ ... ទំព័រ ____

១០.ទំហំនៃ*ជំនួយ* របស់ព្រះ...ទំព័រ ____

**សេចក្តីសន្យារបស់ព្រះ**...ទំព័រ ____

១. សេចក្តីសន្យារបស់ព្រះ អំពីសេចក្តីសង្គ្រោះ / **ការផ្សះផ្សា** ... ទំព័រ ____

២. សេចក្តីសន្យារបស់ព្រះ អំពី**ព្រះវត្តមានរបស់ព្រះអង្គ** ... ទំព័រ ____

៣. សេចក្តីសន្យារបស់ព្រះ អំពី**ការដឹកនាំ** / **ការណែនាំ** ... ទំព័រ ____

៤. សេចក្តីសន្យារបស់ព្រះ អំពី**ការការពារ**...ទំព័រ ____

៥. សេចក្តីសន្យារបស់ព្រះ អំពី**ប្រាជ្ញា** / **ចំណេះដឹង** / **ការយល់ដឹង**...ទំព័រ ____

៦. សេចក្តីសន្យារបស់ព្រះ អំពី**ការផ្គត់ផ្គង់** / **អំណោយទាន**...ទំព័រ ____

៧. សេចក្តីសន្យារបស់ព្រះ អំពី**ការប្រោសឲ្យជា** / **ការស្តារឡើងវិញ**...ទំព័រ ____

៨. សេចក្តីសន្យារបស់ព្រះ អំពី**ជំនួយ** / **កម្លាំង**...ទំព័រ ____

៩. សេចក្តីសន្យារបស់ព្រះ អំពី**ការល្បួងល** និង**ការរងទុក្ខ** ... ទំព័រ ____

១០.សេចក្តីសន្យារបស់ព្រះ អំពី**ទំនាក់ទំនងរបស់ទ្រង់ជាមួយយើង** ... ទំព័រ ____


### កិច្ចការដំបូង

កិច្ចការដំបូងរបស់អ្នក គឺសរសេរលេខទំព័រឲ្យត្រឹមត្រូវ នៅលើបន្ទាត់ទាំងអស់ខាងលើ។ ទំព័រនេះ ឥឡូវនេះ នឹងក្លាយជាចំណុចយោង សម្រាប់ការសិក្សានាពេលអនាគតរបស់អ្នក នៅពេលដែលអ្នកនឹងកត់ត្រាការ

សង្កេតជាច្រើន អំពីព្រះ នៅក្នុងប្រភេទផ្សេងៗគ្នា។ *នៅពេលណា ដែលអ្នកអានអ្វីមួយ អំពីព្រះនៅក្នុងព្រះគម្ពីរ សូមបើកទំព័រនេះ ហើយរកកន្លែង ដែលអ្នកនឹងសរសេរកំណត់ចំណាំរបស់អ្នក។*

ប៉ុន្មានខែទៀត ពេលដែលអ្នកចំណាយកាន់តែច្រើន ក្នុងការស្វែងរក និងសរសេរការសង្កេតផ្សេងៗគ្នា អំពីព្រះជានរណា នោះនឹងធ្វើឲ្យអ្នកភ្ញាក់ផ្អើល និងលើកទឹកចិត្តកាន់តែច្រើន។ សូមឲ្យព្រះវិញ្ញាណរបស់ទ្រង់បង្រៀនអ្នក រាល់ពេលដែលអ្នកអានព្រះគម្ពីរ ហើយរីករាយនឹងការផ្លាស់ប្តូរ ដែលនឹងកើតឡើងនៅក្នុងការគិត និងក្នុងជីវិតរស់នៅរបស់អ្នក។

# ភាពធំឧត្តមរបស់ព្រះ
# ត្រូវបានបង្ហាញនៅក្នុងប្រវត្តិសាស្ត្រ



## ទស្សនៈពីរ

ភាពធំឧត្តមរបស់ព្រះ ត្រូវបានបង្ហាញ ទាំងនៅក្នុងទស្សនៈខ្នាតធំ (ធំទូលាយ ធំធេង) និងទស្សនៈខ្នាតតូច (តូច លម្អិត)។ នេះជាភស្តុតាងជាក់ស្តែងក្នុងការបង្កើតរបស់ទ្រង់។ សកលលោកដ៏ធំធេង ដែលមានផ្កាយរាប់ពាន់លាន និងកាឡាក់ស៊ី ហួសពីការយល់ដឹងរបស់យើង។ ហើយនៅពេលដែលយើងចូល ទៅក្នុងរូបកាយរបស់យើងផ្ទាល់ ភាពស្មុគស្មាញ នៃDNAផ្ទាល់របស់យើង នៅតែមិនទាន់ត្រូវបានគេយល់នៅឡើយ។



ព្រះទ្រង់បានបង្ហាញអង្គទ្រង់ ដោយវិធីទាំងពីរ ដល់អ័ប្រាហាំដែលជាតួអង្គសំខាន់ម្នាក់ នៅដើមដំបូងនៃព្រះគម្ពីរ ដែលបានរស់នៅប្រហែលបួនពាន់ឆ្នាំមុន។ ព្រះអង្គបានធ្វើព្រឹត្តិការណ៍ មិនធម្មតាមួយ នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់អ័ប្រាហាំ (ទស្សនៈខ្នាតតូច) ហើយនៅពេលដំណាលគ្នា ទ្រង់បានផ្តល់គំនិតដល់អ័ប្រាហាំ នូវអ្វីដែលទ្រង់នឹងធ្វើ ក្នុងរយៈពេលរាប់ពាន់ឆ្នាំ ហួសពីពេលវេលានៃជីវិតរបស់គាត់ (ទស្សនៈខ្នាតធំ) ។

ព្រះទ្រង់មានព្រះបន្ទូល ទៅកាន់លោកអ័ប្រាហាំថា "កូនដែលកើតពីអ្នកផ្ទាល់ នឹងត្រូវស្នងមរតកអ្នក"។ ទ្រង់ក៏បាននាំគាត់ទៅខាងក្រៅ ហើយមានបន្ទូលថា “ចូរមើលទៅលើមេឃ ហើយរាប់ចំនួនផ្កាយទាំងប៉ុន្មានចុះ ឲ្យតែអ្នករាប់វាអស់”។ បន្ទាប់មក ទ្រង់មានបន្ទូល ទៅកាន់គាត់ថា “កូនចៅរបស់អ្នក នឹងបានជាដូច្នោះដែរ” ។ (លោកុប្បត្តិ ១៥:៤-៥)

ព្រឹត្តិការណ៍ដែលមិនធម្មតា ដែលអ័ប្រាហាំមានកូនប្រុសម្នាក់ បន្ទាប់ពីគាត់មានអាយុ ៩០ ឆ្នាំ បានតម្រូវឲ្យព្រះធ្វើអ្វីមួយចំនួន តាមកម្រិតម៉ូលេគុល នៃរាងកាយរបស់គាត់ ហើយប្រហែលជាសូម្បីតែនៅក្នុងDNAរបស់គាត់។ ហើយបន្ទាប់មកព្រះបានមានបន្ទូលប្រាប់លោកអ័ប្រាហាំថាជីវិតកូនប្រុសរបស់គាត់នឹងកើនច្រើនឡើងទៅអនាគតតាមរបៀបដ៏ធំធេងដែលកូនចៅរបស់គាត់នឹងស្រដៀងនឹងផ្កាយនៅលើមេឃ។ ព្រះបានបង្ហាញអង្គទ្រង់ទាំងវិធីផ្ទាល់ខ្លួនយ៉ាងលម្អិតដល់អ័ប្រាហាំ និងផែនការដ៏ធំធេងបំផុតដែលលាតសន្ធឹងមនុស្សជាច្រើនជំនាន់ទៅអនាគត។

## ពេលវេលាកំណត់បង្ហាញពីភាពធំឧត្តមរបស់ព្រះ

តារាងពេលវេលានៅទំព័របន្ទាប់ សង្ខេបពីវិធីដែលព្រះបានបង្ហាញអង្គទ្រង់ ខ្នាតធំដែលមានអាយុកាល រាប់ពាន់ឆ្នាំ ហើយក៏បានប្រាប់ឈ្មោះមនុស្សសំខាន់ៗ ដែលព្រះអង្គបានបង្ហាញអង្គទ្រង់ផ្ទាល់ ក្នុងកម្រិតតូចមួយ

ក្នុងពត៌មានលម្អិតនៃជីវិតរបស់ពួកគេម្នាក់ៗ។ ទាំងខ្នាតធំ និងខ្នាតតូច សុទ្ធតែត្រូវបានពន្យល់នៅក្នុងទំព័រ នៃព្រះគម្ពីរ។

វិធីបីយ៉ាងនៃរបៀបដែលព្រះបានបង្ហាញអង្គទ្រង់ ស្ថិតលើកម្រិតខ្នាតធំ ត្រូវបានបង្ហាញនៅលើតារាងពេលវេលានេះ។ មានដូចជាៈ

- **តាមរយៈការបង្កើត**។ "តាំងពីកំណើតពិភពលោកមក ព្រះចេស្ដាដ៏អស់កល្ប និងនិស្ស័យជាព្រះរបស់ព្រះអង្គ ដែលទោះជាគេមើលមិនឃើញក្ដី នោះក៏បានបង្ហាញឲ្យឃើញច្បាស់ ហើយយល់បាន តាមរយៈអ្វីៗដែលព្រះអង្គបង្កើតមកដែរ។ ដូច្នេះ គេមិនអាចដោះសាបានឡើយ" (រ៉ូម ១:២០)។
- **តាមរយៈសាសន៍អ៊ីស្រាអែល** ក្រុមមនុស្សនៃពួកកូនចៅយ៉ាកុប ដែលក្រោយមកត្រូវបានគេហៅថា អ៊ីស្រាអែល។ ព្រះបានថ្លែងបទទំនាយ អំពីកូនចៅអ៊ីស្រាអែល នៅក្នុងគម្ពីរលោកុប្បត្តិ ហើយទ្រង់បានបន្តថ្លែងទំនាយលម្អិតបន្ថែមទៀត ក្នុងរយៈពេលជាច្រើនសតវត្សកន្លងផុតទៅ។ បទទំនាយទាំងនេះ ត្រូវបានបំពេញជាបន្តបន្ទាប់ ក្នុងប្រវត្តិសាស្ត្រ ហើយនឹងត្រូវបានបំពេញជាបន្តទៅអនាគត ដូចបានរៀបរាប់នៅក្នុងគម្ពីរ វិវរណៈ។ នេះបង្ហាញពីការគ្រប់គ្រងដ៏អស្ចារ្យរបស់ព្រះ ចំពោះប្រវត្តិសាស្ត្រទាំងអស់។
- **តាមរយៈព្រះយេស៊ូវគ្រីស្ទ**។ ព្រះបានចាប់ផ្ដើមថ្លែងទំនាយ អំពីព្រះយេស៊ូវគ្រីស្ទ ជាព្រះមេស្ស៊ីចំពោះអ័ដាម និងអេវ៉ា។ ទ្រង់បានបន្តធ្វើការថ្លែងទំនាយ ក្នុងប្រវត្តិសាស្ត្រ រហូតដល់ព្រះយេស៊ូវគ្រីស្ទបានប្រសូតមកលើផែនដី។ បទទំនាយជាច្រើន នៅតែត្រូវបានបំពេញ នាពេលអនាគតដូចជាបទទំនាយ ដែលបានធ្វើនៅក្នុងគម្ពីរសញ្ញាចាស់ អំពីការយាងត្រឡប់មកវិញ របស់ព្រះយេស៊ូវគ្រីស្ទដ៏ជាស្ដេច (សាការី ១៤:១-៩) រឿងដែលព្រះយេស៊ូវបានមានបន្ទូលដោយផ្ទាល់អំពីការយាងត្រឡប់មកវិញ របស់ព្រះអង្គដ៏ជាស្ដេច (ម៉ាថាយ ២៥:៣១-៤៦) និងសេចក្ដីថ្លែងនៅក្នុងវិវរណៈ អំពីការយាងត្រឡប់មកវិញ របស់ព្រះអង្គដ៏ជាស្ដេច (វិវរណៈ ជំពូក ១៩-២២)។ នេះគឺជាវិធីមួយទៀត ដែលព្រះកំពុងបង្ហាញពីការគ្រប់គ្រងដ៏អស្ចារ្យ នៅក្នុងប្រវត្តិសាស្ត្រ។

ភាពធំឧត្តមរបស់ព្រះ ក៏ត្រូវបានបង្ហាញនៅក្នុងកម្រិត***ខ្នាតតូច***មួយ នៅក្នុងព្រះគម្ពីរដែរ។ នៅពេលយើងអានពីរបៀប ដែលព្រះបានរៀបចំសេចក្ដីលម្អិត នៃជីវិតរបស់មនុស្ស ដូចជាលោកម៉ូសេ ត្រូវបានប្រទះឃើញ ជាទារកនៅក្នុងកន្ត្រកអណ្ដែត នៅក្នុងទន្លេនីល ហើយបន្ទាប់មក ព្រះនាងបានបង់ថ្លៃជូនម្ដាយរបស់គាត់ផ្ទាល់ ដើម្បីចិញ្ចឹមគាត់ យើងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង អំពីរបៀបដែលព្រះ ចូលរួមយ៉ាងលម្អិត។ ព្រះគម្ពីរមានពត៌មានលម្អិតដ៏អស្ចារ្យ ដូចនេះដែលបង្ហាញពីព្រះរាជលក្ខណៈរបស់ទ្រង់ តាមរបៀបជាច្រើន។ យើងឃើញព័ត៌មានលម្អិតទាំងនេះនៅក្នុង -

- **ជីវិតរបស់បុគ្គលម្នាក់ៗ**
- **ព្រឹត្តិការណ៍**ជាក់លាក់

ពេលអ្នកអានដំណើររឿងព្រះគម្ពីរ អំពីរបៀបដែលព្រះបានបង្ហាញអង្គទ្រង់ ក្នុងប្រវត្តិសាស្ត្រ សូមកត់ត្រាការសង្កេតរបស់អ្នកអំពីព្រះ នៅទំព័រក្នុងផ្នែកសមស្របនានា។ ផ្នែកទាំងនេះ ត្រូវបានពិពណ៌នា នៅក្នុងផ្នែកដំបូងនៃឯកសារនេះ ដែលមានចំណងជើងថា "សេចក្ដីណែនាំ" ។ ដោយសរសេរការសង្កេតដូចនេះនិងទូលសូមឲ្យព្រះជួយអ្នកចងចាំ នោះគំនិតរបស់អ្នកនឹងមានការចាប់អារម្មណ៍ ចំពោះទិដ្ឋភាពជាច្រើន នៃភាពអស្ចារ្យរបស់ទ្រង់។

## ការពន្យល់តាមរយៈ តារាងពេលវេលា នៃប្រវត្តិសាស្ត្រ

នៅទំព័របន្ទាប់ គឺជាតារាងពេលវេលា នៃប្រវត្តិសាស្ត្រទាំងអស់ ចាប់តាំងពីការបង្កើតពិភពលោក រហូតដល់ពេលវេលា ដែលព្រះយេស៊ូវគ្រីស្ទ នឹងយាងត្រឡប់មកវិញ ធ្វើជាស្ដេច ហើយបង្កើតផ្ទៃមេឃថ្មីផែនដីថ្មី។ ព្រះគម្ពីរ គឺជាគម្ពីររបស់ព្រះ ដែលបង្ហាញពីអ្វី ដែលទ្រង់បានធ្វើ ហើយទ្រង់នឹងធ្វើនៅក្នុងប្រវត្តិសាស្ត្រទាំងមូល។ តារាងពេលវេលានេះ បង្ហាញពីរបៀបដែលព្រះបានបង្ហាញអង្គទ្រង់ដល់មនុស្ស នៅទូទាំងប្រវត្តិសាស្ត្រ។

ព្រះទ្រង់បានបង្កើតយើងមក ដើម្បីស្គាល់ទ្រង់ និងមានទំនាក់ទំនងជាមួយទ្រង់។ ទ្រង់បានបង្ហាញអង្គទ្រង់តាមវិធីផ្សេងៗគ្នា នៅទូទាំងប្រវត្តិសាស្ត្រ។ វិធីទីមួយដែលព្រះបានបង្ហាញភាពធំឧត្តមរបស់ទ្រង់ គឺតាមរយៈការបង្កើតរបស់ទ្រង់។ (កត់សម្គាល់ បន្ទាត់បញ្ឈរ នៅការបង្កើត ដែលភ្ជាប់ជាមួយបន្ទាត់ផ្ដេក ដែលឆ្លងកាត់ទំព័រទាំងពីរ។ នេះជានិមិត្តរូប នៃការបង្កើតរបស់ព្រះ ដែលកំពុងបន្តឆ្លងកាត់ប្រវត្តិសាស្ត្រទាំងមូល។) នៅពេលយើងក្រឡេកមើល ទៅលំហដ៏ធំទូលាយ ដែលមានកាឡាក់ស៊ីរាប់ពាន់លាន ដែលពេញទៅដោយផ្កាយរាប់ពាន់លាន ហើយមិនអាចយល់ពីអំណាច និងការជ្រាបដឹង អំពីព្រះបាន បន្ទាប់មក នៅពេលយើងក្រឡេកមើលរាងកាយរបស់យើងផ្ទាល់ លើភាពស្មុគស្មាញ នៃកោសិកានីមួយៗ និងមុខងាររាប់លាន ដែលអនុវត្តដោយ DNA នៅក្នុងកោសិកាមួយ គំនិតរបស់យើងមានការប៉ះពាល់ម្ដងទៀត ដោយការជ្រាបដឹង និងសមត្ថភាពរបស់ព្រះ ដែលហួសពីការយល់ដឹងរបស់យើង។

ព្រះក៏បានបង្ហាញ និងបង្ហាញឲ្យឃើញ នូវភាពធំឧត្តមរបស់ព្រះ តាមរបៀបដែលព្រះអង្គធ្វើការជាមួយមនុស្ស។ នៅពេលដែលយើងឃើញ ពីរបៀបដែលទ្រង់បំពេញសេចក្ដីសន្យា ក្នុងរយៈពេលរាប់ពាន់ឆ្នាំ ទោះបីមានភាពអាក្រក់ និងការប្រឆាំងក៏ដោយ ក៏យើងអាចឈរដោយកោតស្ញប់ស្ញែង ដោយមិនអាចយល់បាន អំពីរបៀបដែលការនោះអាចទៅរួច។ នៅពេលដែលយើងក្រឡេកមើលព័ត៌មានលម្អិត នៃជីវិតរបស់មនុស្សម្នាក់ និងឃើញការអស្ចារ្យដែលទ្រង់បានធ្វើ។

ការងាររបស់ព្រះជាមួយមនុស្ស ត្រូវបានកត់ត្រាទុក នៅក្នុងព្រះគម្ពីរ ដែលមានដំណើររឿងជាច្រើន ដែលពិពណ៌នាអំពីអ្វីដែលព្រះបានធ្វើ ក្នុងប្រវត្តិសាស្ត្រ និងអ្វីដែលទ្រង់បានធ្វើ នៅក្នុងជីវិតរបស់មនុស្ស។ ដូចដែលបានបញ្ជាក់ពីមុន ព្រះគម្ពីរពិពណ៌នា អំពីទិដ្ឋភាពពីរ នៃទំនាក់ទំនងរបស់ទ្រង់ជាមួយមនុស្ស:

១. **ផែនការរយៈពេលវែង របស់ព្រះ (ទស្សនៈវិស័យខ្នាតធំ)** - ព្រះគម្ពីរពិពណ៌នា អំពីផែនការដែលព្រះកំពុងតែអនុវត្ត តាំងពីដំបូងនៃប្រវត្តិសាស្ត្រ រហូតដល់ទីបញ្ចប់។ វាគឺជាផែនការរបស់ទ្រង់ ក្នុងការមានទំនាក់ទំនងជិតស្និទ្ធជាមួយមនុស្សគ្រប់ទីកន្លែង តាំងពីដំបូងនៃការបង្កើតរបស់ទ្រង់ រហូតដល់ពេលដែលទ្រង់បង្កើតពិភពលោកថ្មី។ ព្រះបាន និងកំពុងបង្ហាញអង្គទ្រង់ នៅក្នុងវិធីបួនយ៉ាង ក្នុង

ប្រវត្តិសាស្ត្រ។ វិធីនីមួយៗ ក្នុងចំណោមវិធីទាំងបួន បង្ហាញពីភាពធំឧត្តមដែលគួរស្ញែងខ្លាចរបស់ទ្រង់ ដោយសមត្ថភាពផ្សេងៗគ្នា។ វិធីទាំងបួននេះ ត្រូវបានគូសបញ្ជាក់ នៅលើតារាងពេលវេលា។

- ព្រះបង្ហាញអង្គទ្រង់តាមរយៈការបង្កើត។
- ព្រះបង្ហាញអង្គទ្រង់តាមរយៈក្រុមមនុស្សដែលជាកូនចៅរបស់អ័ប្រាហាំដែលមានឈ្មោះតាមចៅប្រុសរបស់គាត់គឺអ៊ីស្រាអែល (យ៉ាកុប) ។
- ព្រះបង្ហាញអង្គទ្រង់តាមរយៈព្រះយេស៊ូវគ្រីស្ទដែលត្រូវបាននិមិត្តរូបដោយកូនចៀមដែលបានលះបង់នៅទូទាំងប្រវត្តិសាស្ត្រ។
- ព្រះបង្ហាញអង្គទ្រង់តាមរយៈក្រុមគ្រួសារដ៏អស់កល្បរបស់ទ្រង់គឺពួកជំនុំ។

២. **ការងារផ្ទាល់របស់ព្រះ (ទស្សនៈវិស័យខ្នាតតូច)** - ព្រះគម្ពីរពិពណ៌នា នូវឧទាហរណ៍ជាច្រើន អំពីរបៀប ដែលព្រះបានទាក់ទង តាមវិធីផ្ទាល់ខ្លួន ដល់មនុស្សគ្រប់ប្រភេទ ទូទាំងប្រវត្តិសាស្ត្រ។ ដំណើររឿងនៃជីវិតរបស់មនុស្សម្នាក់ៗ បង្ហាញពីទិដ្ឋភាពកាន់តែច្រើន នៃភាពធំឧត្តមរបស់ទ្រង់។

ខាងក្រោមនេះ គឺជាសេចក្តីសង្ខេប នៃដំណើររឿងប្រវត្តិសាស្ត្រដំបូងៗ ដែលបានកត់ត្រា នៅក្នុងព្រះគម្ពីរ។ ព្រឹត្តិការណ៍ និងមនុស្សទាំងនេះ ត្រូវគ្នានៅលើតារាងពេលវេលា ជាមួយឯកសារនេះ។ តារាងព្រឹត្តិការណ៍ និងឧយោងខាងក្រោម អាចត្រូវបានប្រើសម្រាប់ការសង្ខេបនៃព្រះគម្ពីរ។ បន្ទាប់ពីទិដ្ឋភាពទូទៅនេះ គឺជាទំព័រដែលបង្ហាញពីព្រឹត្តិការណ៍ដូចគ្នា និងមនុស្សដែលមានព័ត៌មានលម្អិត និងឧយោងព្រះគម្ពីរ។ សូមអានព័ត៌មានទាំងអស់ ហើយធ្វើតាមការណែនាំទាំងអស់ ដែលបានផ្តល់សម្រាប់ព្រឹត្តិការណ៍ និងមនុស្សម្នាក់ៗ។ សូមកត់ត្រារាល់ការសង្កេតរបស់អ្នក អំពីព្រះ យោងតាមការណែនាំ ដែលបានចែង នៅខាងដើមឯកសារនេះ។ ទស្សនៈរបស់អ្នកចំពោះព្រះ និងពិភពលោក នឹងត្រូវផ្លាស់ប្តូរ!

## ការសង្កេតមើលសង្ខេបៗពីព្រះគម្ពីរ

១. ការបង្កើត - លោកុប្បត្តិ ១:១-៣១
២. អ័ដាម និងអេវ៉ា - លោកុប្បត្តិ ២:៨-២៥
៣. ការធ្លាក់ចុះ - លោកុប្បត្តិ ៣:១-២៤
៤. ណូអេនិងទឹកជំនន់ - លោកុប្បត្តិ ៦:៥ - ៨:២២
៥. ប៉មបាបិល - លោកុប្បត្តិ ១១:១-៩
៦. អ័ប្រាហាំ និងសេចក្តីសន្យារបស់ព្រះ - លោកុប្បត្តិ ១២:១-៧
៧. កូនចៅរបស់អ័ប្រាហាំ - លោកុប្បត្តិ ២៥:១៩-២៦ ។ នេះជាការចាប់ផ្តើម នៃប្រជាជាតិអ៊ីស្រាអែល។

- ព្រះបានធ្វើការថ្លែងទំនាយ អំពីផែនការរបស់ទ្រង់ សម្រាប់ពិភពលោក តាមរយៈអ៊ីស្រាអែល - បទទំនាយថា កូនចៅរបស់គាត់ នឹងរស់នៅលើទឹកដីនេះ ជារៀងរហូត។

## ព្រះជាម្ចាស់


ព្រះជាម្ចាស់បង្ហាញអង្គទ្រង់ តាមរយៈការបង្កើតរបស់ទ្រង់ (ទំនុកដំកើង ១៩:១-៤; រ៉ូម ១:២០)
ព្រះជាម្ចាស់បង្ហាញអង្គទ្រង់ តាមរយៈជាតិសាសន៍មួយ គឺ អ៊ីស្រាអែល (អេសេគាល ៣៦:២២-២៦)
ទឹកជំនន់សកល
ប៉មបាបិល
កូនចៅរបស់អ័ប្រាហាំរស់នៅក្នុងស្រុកកាណាន
អ៊ីស្រាអែលទៅនៅអេស៊ីព្ទ៤០០ឆ្នាំ និងធ្វើជាទាសករ
អ៊ីស្រាអែលត្រឡប់ទៅស្រុកកាណាន (បុណ្យរំលង)
អ៊ីស្រាអែលត្រូវបានបង្កើតឡើងជានគរមួយ
ការបង្កើត
អ័ប្រាហាំ
អ៊ីសាក់
យ៉ាកុប (អ៊ីស្រាអែល)
អ័ដាម&អេវ៉ា
ណូអេ
យ៉ូសែប
ម៉ូសេ
សូល
2600
2100
1850
1400
1030
1.500+ ឆ្នាំ


ព្រះជាម្ចាស់បង្ហាញអង្គទ្រង់ តាមរយៈព្រះយេស៊ូវគ្រីស្ទ ដែលជា*កូនចៀម*នៃព្រះ
យេរូសាឡិមត្រូវបានបំផ្លាញ ហើយអ៊ីស្រាអែលត្រូវបាន ដកចេញ
អ៊ីស្រាអែល វិលត្រឡប់មកវិញ
ព្រះវិហារ ត្រូវបានសាងសង់
ព្រះយេស៊ូវ គ្រីស្ទ
ដាវីឌ
អេសាយ
ដានីយ៉ែល
1000
700
550
0

## ព្រះជាម្ចាស់


ព្រះជាម្ចាស់បង្ហាញអង្គទ្រង់ តាមរយៈការបង្កើតរបស់ទ្រង់ (ទំនុកដំកើត ១៩:១-៤; រ៉ូម ១:២០)
ព្រះជាម្ចាស់បង្ហាញអង្គទ្រង់ តាមរយៈជាតិសាសន៍មួយ គឺ អ៊ីស្រាអែល (អេសេគាល ៣៦:២២-២៦)
ព្រះជាម្ចាស់បង្ហាញអង្គទ្រង់ តាមរយៈព្រះយេស៊ូវគ្រីស្ទ ដែលជា*កូនចៀម*នៃព្រះ
ព្រះជាម្ចាស់បង្ហាញអង្គទ្រង់ តាមរយៈពួកជំនុំ
ពួកជំនុំត្រូវបានបង្កើតឡើង
យេរូសាឡិមត្រូវបានបំផ្លាញ ហើយ អ៊ីស្រាអែលត្រូវបានដកចេញ
អ៊ីស្រាអែលត្រូវបានស្ថាបនា ជាប្រទេសជាតិមួយឡើងវិញ
**ព្រះវិញ្ញាណ បរិសុទ្ធ**
**ព្រះយេស៊ូវ គ្រីស្ទ**
**ព្រះយេស៊ូវគ្រីស្ទ** យាងត្រឡប់មកវិញ ក្នុងនាមជាស្តេច
0
70
1948
សព្វថ្ងៃ

៨. យ៉ូសែប - ដំណើររឿងរបស់គាត់ ពន្យល់ពីរបៀបដែលអ៊ីស្រាអែល បានបញ្ចប់នៅស្រុកអេស៊ីព្ទ - លោកុប្បត្តិ ៣៧:១-៣៦, ៤១:៤១-៤៩, ៤៥:១-១១
៩. អ៊ីស្រាអែល និងកូនចៅទាំងអស់ ចាកចេញពីស្រុកកាណាន ទៅកាន់ស្រុកអេស៊ីព្ទ មាន ៧០ នាក់ - លោកុប្បត្តិ ៤៦:២៦-២៧
១០. លោកម៉ូសេ, គ្រោះកាចនិងបុណ្យរំលង (កូនចៀមគឺជាគ្រឿងបូជាជំនួសដើម្បីកុំឲ្យមនុស្សម្នាក់ស្លាប់) - និក្ខមនំ ១១:១ - ១២:១៧, និង ១២:២៩-៣៣

- ព្រះបានទាយ អំពីផែនការរបស់ព្រះអង្គ សម្រាប់ពិភពលោក តាមរយៈអ៊ីស្រាអែល - ទ្រង់បានមានបន្ទូលថា កូនចៅអ៊ីស្រាអែល នឹងរស់នៅលើទឹកដី ដែលព្រះ បានសន្យា ជាមួយលោកអ័ប្រាហាំ។

១១. សាសន៍អ៊ីស្រាអែលទាំងអស់ បានចាកចេញពីស្រុកអេស៊ីព្ទ វិលត្រឡប់ទៅស្រុកកាណានវិញ (បុរស ស្ត្រី និងកុមារ ចំនួន ៦០ ម៉ឺន នាក់) - និក្ខមនំ ១២:៣៧
១២. បញ្ញត្តិទាំងដប់ប្រការ - និក្ខមនំ ២០:១-២១
១៣. រោងឧបោសថ - ព្រះទ្រង់បានរចនាឡើង ដើម្បីជួបជាមួយទ្រង់។ កូនចៀម គឺជាសត្វចម្បង ដែលបានថ្វាយជាយញ្ញបូជា ជនគណនា ២៨-២៩, - និក្ខមនំ ២៥:៨-៩, ២៩:៣៨-៤៦
១៤. ដាវីឌ - សាំយូអែលទី១ ១៧:១-៥៨
១៥. ដាវីឌ ត្រូវបានតែងតាំង ជាស្តេចអ៊ីស្រាអែល - សាំយូអែលទី២ ៥:១-៥ ដាវីឌ ស្រឡាញ់ព្រះ ហើយបានតែងទំនុកតម្កើង ជាច្រើន។ ទំនុកតម្កើង ២៣ ជាគម្រូល្អមួយ។

- ព្រះបានទាយ អំពីផែនការរបស់ទ្រង់ សម្រាប់ពិភពលោក តាមរយៈអ៊ីស្រាអែល - ព្រះបានមានបន្ទូលថា ពូជរបស់ដាវីឌ នឹងគង់លើបល្ល័ង្ករបស់ទ្រង់ ជារៀងរហូត - យេរេមា ៣៣:១៤-២៦

១៦. សាឡូម៉ូន បានឡើងសោយរាជ្យ នៅលើពួកអ៊ីស្រាអែល - ពង្សាវតារក្សត្រទី១ ៤:២០ - ៣៤
១៧. ពួកអាសស៊ើរបានបណ្តេញពួកអ៊ីស្រាអែល ចេញពីស្រុកកាណាន។ ក្រោយមក យូដា គឺជាកុលសម្ព័ន្ធអ៊ីស្រាអែល ចុងក្រោយដែលត្រូវពួក បាប៊ីឡូនបានកាន់កាប់ - យេរេមា ៣៩ - ៤៤
១៨. ដានីយ៉ែល - គាត់ត្រូវបានខ្មាំងសត្រូវ ចាប់ទៅ ហើយត្រូវបានព្រះប្រើប្រាស់ ដើម្បីមានឥទ្ធិពលលើមនុស្សជាច្រើន នៅលើពិភពលោក - ដានីយ៉ែល ១-១២

- ព្រះបានធ្វើការថ្លែងទំនាយ អំពីផែនការរបស់ទ្រង់ សម្រាប់ពិភពលោក តាមរយៈអ៊ីស្រាអែល - ដានីយ៉ែល ៧:១៣-១៤ (ព្រះយេស៊ូវ បានដកស្រង់អត្ថបទគម្ពីរនេះ ហើយមានបន្ទូលថា ទ្រង់នឹងបំពេញបទទំនាយនេះ)

១៩. អេសាយ និងបទទំនាយអំពីព្រះមេស្ស៊ី - អេសាយ ៩:៦, អេសាយ ៥៣:១-១២, មីកា ៥:២

- ព្រះបានធ្វើការថ្លែងទំនាយ អំពីផែនការរបស់ទ្រង់ សម្រាប់ពិភពលោក តាមរយៈអ៊ីស្រាអែល - ព្រះបានមានបន្ទូលថា ពូជម្នាក់របស់ដាវីឌ នឹងក្លាយជាស្តេច (ព្រះមេស្ស៊ី) ជាព្រះដែលត្រូវប្រសូតនៅភូមិបេថ្លេហិម

២០. សាសន៍អ៊ីស្រាអែល (សាសន៍យូដា) បានត្រឡប់ទៅសាងសង់ក្រុងយេរូសាឡិម និងអ៊ីស្រាអែលឡើងវិញ (យូដា) - នេហេមា

២១. លោកយ៉ូហានបាទីស្ទ បានរស់នៅក្នុងពេលតែមួយដែលព្រះយេស៊ូវ ប៉ុន្តែបានចាប់ផ្តើមការងាររបស់គាត់ មុនពេលដែលព្រះយេស៊ូវបានធ្វើ។ (នៅក្នុង យ៉ូហាន ១:២៩-៣១ យ៉ូហាន បានប្រាប់ប្រជាជនថា កូនចៀមនៃព្រះ បានមកហើយ)

២២. ព្រះយេស៊ូវគ្រីស្ទ - អះអាងថាជាព្រះ - យ៉ូហាន ១០:២២-៣៣ បានថែងថា គោលបំណងរបស់ទ្រង់ គឺដើម្បីសងថ្លៃលោះបាប - ម៉ាកុស ១០:៤៥ ។ នៅបុណ្យរំលងចុងក្រោយ ព្រះយេស៊ូវបានមានបន្ទូលថា ពែងតំណាងឲ្យព្រះលោហិតរបស់ទ្រង់ ជំនួសឲ្យការតំណាងដោយឈាមរបស់កូនចៀមកាលពីមុន - លូកា ២២:២០ ។

២៣. ព្រះយេស៊ូវគ្រីស្ទ ដែលត្រូវគេឆ្កាង - លូកា ២៣:២០-៥៦ (នៅពេលដំណាលគ្នា កូនចៀមនៃបុណ្យរំលង ត្រូវបានថ្វាយជាយញ្ញបូជា!)

២៤. ការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ - លូកា ២៤:១-១២, ៣៦-៥៣ ។

២៥. ព្រះយេស៊ូវគ្រីស្ទ - ការយាងឡើងទៅស្ថានសួគ៌ ហើយបានសន្យាថានឹងត្រឡប់មកវិញ - កិច្ចការ ១:១-១៤ និងក្រុមជំនុំរបស់ទ្រង់ (កិច្ចការ ២: ៤២-៤៧)

២៦. ព្រះវិញ្ញាណបរិសុទ្ធ - ចាប់ផ្តើមគង់នៅក្នុងមនុស្សនៅពេលពួកគេទុកចិត្តលើព្រះគ្រីស្ទ - យ៉ូហាន ១៤:១៧

២៧. ប៉ូល - បានរស់នៅក្នុងពេលដំណាលគ្នា ជាមួយព្រះយេស៊ូវគ្រីស្ទ ហើយទទួលបានការអប់រំខ្ពស់បំផុត ក្នុងពេលវេលារបស់គាត់។ គាត់បានសរសេរគម្ពីរជាច្រើន នៅក្នុងគម្ពីរសញ្ញាថ្មី។ នៅក្នុងកិច្ចការ ១៣:១៦-៤១ សុន្ទរកថាមួយ របស់ប៉ូលត្រូវបានកត់ត្រាទុក។ វាសង្ខេបប្រវត្តិព្រះគម្ពីរ ហើយពន្យល់ថា ព្រះយេស៊ូវគឺជាអង្គ ដែលបានប្រទានការអត់ទោសបាប។ (១៣:៣៨-៣៩ គឺជាខសំខាន់ៗ)

២៨. ទីក្រុងយេរូសាឡិម ត្រូវបានបំផ្លាញ ដោយពួករ៉ូម៉ាំង នៅឆ្នាំ ៧០ គ.ស.។ ពួកគេបានសម្លាប់ ឬចាប់យក (ធ្វើជាទាសករ) ស្ទើរតែគ្រប់សាសន៍យូដា ដែលរស់នៅអ៊ីស្រាអែល។ តំបន់នេះលែងត្រូវបានគេហៅថា អ៊ីស្រាអែល ហើយឈប់មានជាប្រជាជាតិមួយ។

២៩. អ៊ីស្រាអែល ត្រូវបានអង្គការសហប្រជាជាតិ ស្តារឡើងវិញជាប្រទេសមួយ នៅឆ្នាំ ១៩៤៨ បន្ទាប់ពីសង្គ្រាមលោកលើក ទី២។ អារ៉ាប់ បានព្យាយាមបំផ្លាញប្រជាជាតិថ្មីមួយនេះ នៅថ្ងៃដំបូងដែលត្រូវបានបង្កើត ប៉ុន្តែប្រទេសនេះបានរស់រានមានជីវិត ដោយការអស្ចារ្យ។ វាជារឿងមួយទៀតស្រដៀងនឹងដាវីឌ និងកូលីយ៉ាត។

៣០. ផ្ទៃមេឃ និងផែនដីថ្មី ដែលមានព្រះយេស៊ូវគ្រីស្ទ ជាស្តេច - វិវរណៈ ២១:១-២៧ ។ ព្រះយេស៊ូវត្រូវបានពិពណ៌នាថាជា កូនចៀម។ ទ្រង់ក៏មានបញ្ជីជីវិត ២១:២៧។

**សម្គាល់:** យោងទៅលើប្រធានបទ អំពី កូនចៀមដែលជាដង្វាយយញ្ញបូជា ត្រូវបានរៀបរាប់នៅក្នុងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ នៅក្នុងលេខ ១០, ១៣, ២១, ២២, ២៩។ នេះគឺជាប្រធានបទដ៏ធំមួយ របស់ព្រះនៅទូទាំងប្រវត្តិសាស្ត្រ តាំងពី លោកុប្បត្តិ រហូតដល់ វិវរណៈ ហើយប្រធានបទនេះ ជួយយើងឲ្យយល់អំពីតួអង្គព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ។ នៅក្នុងតារាងលំដាប់ខាងលើ ដំណើររឿងអំពីចៀម (កូនចៀម) ដែលត្រូវបានផ្តល់ជូនអ័ប្រាហាំ ដើម្បីកុំឲ្យគាត់សម្លាប់កូនប្រុសរបស់គាត់។ វាមាននៅក្នុងផ្នែកបន្ទាប់

នៃក្បួនតម្រានេះ ដែលបានសិក្សាអំពីជីវិតរបស់អ័ប្រាហាំ។ នេះគឺជានិមិត្តរូបដ៏អស្ចារ្យ អំពីព្រះយេស៊ូវគ្រីស្ទ ប៉ុន្តែ សម្រាប់អ្នកដែលមិនមែនជាគ្រីស្ទបរិស័ទ ដែលទើបតែត្រូវបានណែនាំ ទៅកាន់ព្រះគម្ពីរ ដំណើររឿងនៃការដែល ព្រះតម្រូវឲ្យមានការថ្វាយមនុស្សជាយញ្ញបូជា អាចបង្កឲ្យមានការភ័ន្តច្រឡំ។

ទំព័របន្ទាប់ ផ្តោតលើព្រឹត្តិការណ៍ និងតួអក្សរសំខាន់ៗ ក្នុងព្រះគម្ពីរ ដែលត្រូវបានដាក់ឈ្មោះនៅលើតារាងពេលវេលា។ អ្នកនឹងអានព័ត៌មាន ហើយក៏នឹងមានសំណួរ ដើម្បីជួយអ្នកគិត អំពីភាពធំឧត្តមរបស់ព្រះជាម្ចាស់ ពីទស្សនៈវិស័យខ្នាតធំ និងខ្នាតតូច។ អ្វីជាលទ្ធផល នោះគឺជាការយល់ដឹង អំពីការងារដ៏ អស្ចារ្យរបស់ព្រះ នៅលើពិភពលោក និងជាការកោតស្ញប់ស្ញែងថា តើព្រះអង្គដែលជាអ្នកបង្កើត ដ៏អស្ចារ្យរបស់យើង ទ្រង់ជានរណា!

# ពត៌មានលម្អិត នៃព្រឹត្តិការណ៍ព្រះគម្ពីរ និងមនុស្ស

ពេលអ្នកអានដំណើររឿង ក្នុងគម្ពីរអំពីរបៀប ដែលព្រះបានបង្ហាញអង្គទ្រង់ ក្នុងប្រវត្តិសាស្ត្រ សូមកត់ត្រាការសង្កេតរបស់លអ្នក អំពីព្រះ នៅលើទំព័រ ក្នុងផ្នែកសមស្រប ដូចដែលបានរៀបរាប់ នៅក្នុងសេចក្តីណែនាំ ដែលបានប្រាប់រួចហើយ នៅក្នុងឯកសារនេះ។ ដោយសរសេរការសង្កេតដូចនេះ ហើយសុំឲ្យព្រះជួយអ្នកចងចាំ នោះគំនិតរបស់អ្នក នឹងត្រូវមានការចាប់អារម្មណ៍ ចំពោះទិដ្ឋភាពជាច្រើន នៃភាពធំឧត្តមរបស់ទ្រង់។

## ការបង្កើត

សូមអាន លោកុប្បត្តិ ជំពូក ១ - ២

- ព្រះជាអ្នកបង្កើតសកលលោកទាំងមូល និងអ្វីៗទាំងអស់ នៅក្នុងនោះ។
- តើអ្នកអាចនិយាយអ្វីខ្លះ អំពី***ព្រះចេស្តា*** របស់ព្រះ ពេលអ្នកអានឃើញថា ទ្រង់គឺជាអ្នកដែលបានបង្កើតអ្វីៗទាំងអស់? កត់ត្រាការសង្កេតរបស់អ្នកនៅក្នុងផ្នែកអំពីព្រះ - ចរិតលក្ខណៈរបស់គាត់“ តើព្រះមានអំណាចប៉ុន្មាន?”
- ការបង្កើត បង្ហាញថា ព្រះមានការជ្រាបដឹង អំពីអ្វីៗទាំងអស់ ដែលមាន។ ចេញពីដំណើររឿងនេះ សូមពិពណ៌នា អំពីកម្រិតនៃ***ការជ្រាបដឹង*** របស់ព្រះ។ សូមកត់ចំណាំការសង្រ្កតរបស់អ្នកនៅក្នុងផ្នែកថា“ តើព្រះ***ជ្រាបដឹង*** ច្រើនប៉ុណ្ណា?” នៅក្នុងមូលដ្ឋានគ្រឹះអំពីព្រះ - ព្រះរាជលក្ខណៈរបស់ព្រះអង្គ។
- តើមានអ្វីផ្សេងទៀត ដែលអ្នកឃើញ អំពីព្រះ នៅក្នុងជំពូកពីរដំបូង នៃគម្ពីរ លោកុប្បត្តិ? (សូមសរសេរការសង្កេតរបស់អ្នក នៅក្នុងផ្នែក “ព្រះរាជលក្ខណៈរបស់ព្រះ”)។
- សម្រាប់ការគិត ឬ ការពិភាក្សា - ព្រះបានបង្កើតមនុស្ស តាមរូបអង្គទ្រង់ (១:២៦-២៧) ។ តើនេះមានន័យដូចម្តេច?
- សម្រាប់ការគិត ឬ ការពិភាក្សា - ព្រះបានបង្កើតមនុស្ស ឲ្យមើលថែចំពោះការបង្កើតរបស់ទ្រង់ (១:២៦) ។ តើយើងគួរធ្វើដូចម្តេច ដោយសារ ការពិតនេះ?

## អ័ដាម និង អេវ៉ា

សូមអាន លោកុប្បត្តិ ២:១៥ - ៣:២៤

- ព្រះបានប្រទានការណែនាំ ដល់អ័ដាមនិងអេវ៉ា ហើយក៏ប្រាប់ពួកគេថា បើពួកគេមិនស្តាប់បង្គាប់ ពួកគេនឹងត្រូវស្លាប់ (២:១៧) ។
- ព្រះបានបង្កើតបុរស និងស្ត្រី សម្រាប់ភាពជាដៃគូជិតស្និទ្ធ (អាពាហ៍ពិពាហ៍) ។ (២:១៨, ២៣-២៤)
- ព្រះបានបង្កើតមនុស្ស សម្រាប់ទំនាក់ទំនងជាមួយអង្គទ្រង់ផ្ទាល់ (២:៨-៩)
- ព្រះបរិសុទ្ធ ដូច្នេះគ្មានបាបណា អាចនៅចំពោះព្រះភ័ក្ត្រទ្រង់បានឡើយ។ ការដាច់ចេញពីព្រះ ក៏មានន័យថា ស្លាប់ខាងឯវិញ្ញាណ ដែរ។
- ព្រះ ក៏មានព្រះហឫទ័យមេត្តាករុណាខ្លាំងណាស់ដែរ បានជាទ្រង់អនុញ្ញាត ឲ្យមនុស្សបន្តរស់ នៅទោះបីបន្ទាប់ពីពួកគេមិនស្តាប់បង្គាប់ទ្រង់ក៏ដោយ (ទោះបី អ័ដាមនិងអេវ៉ាបានស្លាប់ខាងព្រលឹងវិញ្ញាណភ្លាមៗ នៅពេលដែលពួកគេបានធ្វើបាបក៏ដោយ)! ជាមួយនឹងស្តង់ដារ នៃភាពបរិសុទ្ធរបស់

ព្រះ គឺជាការអស្ចារ្យ ដែលទ្រង់ទ្រាំទ្រ នឹងមនុស្សបានយូរដូច្នោះ ហើយទ្រង់នៅតែចង់ឲ្យយើងស្តារទំនាក់ទំនងជិតស្និទ្ធ ជាមួយទ្រង់ឡើងវិញ។

- តើមានអ្វីផ្សេងទៀត ដែលអ្នកឃើញអំពីព្រះ នៅក្នុងជំពូកពីរដំបូង នៃគម្ពីរ លោកុប្បត្តិ? (សរសេរការសង្កេតរបស់អ្នក នៅក្នុងផ្នែក នៃក្បួនតម្រានេះ ដែលមានចំណងជើងថា "សេចក្តីសង្គ្រោះរបស់ព្រះ" "ព្រះរាជលក្ខណៈរបស់ព្រះ" និង "សេចក្តីសន្យារបស់ព្រះ")

## ណូអេ

សូមអាន លោកុប្បត្តិ ៦ - ៩

ព្រះទ្រង់ស្រឡាញ់មនុស្ស ហើយចង់មានទំនាក់ទំនង ប្រកបដោយសេចក្តីស្រឡាញ់ ជាមួយពួកគេ ប៉ុន្តែទ្រង់នឹងមិនបង្ខំមនុស្ស ឲ្យស្រឡាញ់ទ្រង់ទេ។ ទ្រង់នឹងមិនបង្ខំមនុស្សឲ្យរស់នៅជាមួយទ្រង់ទេ។ នេះត្រូវបានបង្ហាញ នៅពេលដែលព្រះជំនុំជម្រះពិភពលោក ដោយទឹកជំនន់ពាសពេញពិភពលោក។

- ព្រះហឫទ័យរបស់ព្រះ ពោរពេញទៅដោយការឈឺចាប់ - ហួសពីការនឹកស្រមៃរបស់យើងទៅទៀត! ព្រះហឫទ័យរបស់ទ្រង់ ពោរពេញដោយការឈឺចាប់ ដោយសារតែភាពអាត្មានិយមរបស់មនុស្ស។ (លោកុប្បត្តិ ៦:៦)
- អំពើបាប ទាមទារសេចក្តីស្លាប់ ដូចព្រះអង្គបានប្រាប់រួចហើយ នៅពេលទ្រង់បង្កើតមនុស្សដំបូង។ (លោកុប្បត្តិ ២:១៧)
- ព្រះបានជំនុំជម្រះមនុស្ស ប៉ុន្តែសេចក្តីមេត្តាករុណារបស់ទ្រង់ នៅតែចងចាំជានិច្ច។ ដោយសារតែសេចក្តីមេត្តាករុណារបស់ទ្រង់ ព្រះអង្គបានអនុញ្ញាត ឲ្យមនុស្សជាច្រើន អស់រយៈពេលជាច្រើនឆ្នាំ ដើម្បីរីករាយ នឹងការយកចិត្តទុកដាក់ និងការផ្គត់ផ្គង់របស់ទ្រង់ ថ្វីបើពួកគេស្ថិតក្នុងការគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន អំពើហឹង្សាប្រឆាំងនឹងគ្នា និងការបដិសេធព្រះក៏ដោយ។
- យើងអាចប្រាកដថា មនុស្សគ្រប់គ្នាស្លាប់ទឹកជំនន់ ប៉ុន្តែព្រះមិនបានជួយសង្គ្រោះពួកគេទេ ពីព្រោះពួកគេក៏មិនចង់បានព្រះដែរ។ ពួកគេចង់បានរបស់ល្អៗ ដែលព្រះបានប្រទានដល់ពួកគេ ប៉ុន្តែពួកគេមិនចង់បានព្រះអង្គទ្រង់ទេ។
- តើមានអ្វីផ្សេងទៀត ដែលអ្នកបានរៀនអំពីព្រះ នៅក្នុងជំពូក ដែលស្តីអំពីលោកណូអេ និងទឹកជំនន់? (សរសេរការសង្កេតរបស់អ្នក នៅក្នុងផ្នែកនៃក្បួនតម្រានេះ មានចំណងជើងថា "សេចក្តីសង្គ្រោះរបស់ព្រះ" "ព្រះរាជលក្ខណៈរបស់ព្រះ" និង "សេចក្តីសន្យារបស់ព្រះ")

## ប៉មបាបិល

សូមអាន លោកុប្បត្តិ ១១:១-៩

- ប្រជាជនរួមគ្នា សាងសង់ប៉មដ៏ធំមួយ ឡើងដល់ផ្ទៃមេឃ។ ព្រះ ជាមួយសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះមនុស្ស ក៏បានបំបែកនូវបំណងប្រាថ្នារួមគ្នា ដើម្បីធ្វើឲ្យខ្លួនគេអស្ចារ្យនោះ។ ទ្រង់បានធ្វើដូចនេះ ដោយផ្តល់ឲ្យពួកគេនូវភាសាផ្សេងគ្នា ដែលបណ្តាលឲ្យពួកគេផ្លាស់ទីលំនៅ ទៅទីតាំងផ្សេងទៀត នៅទូទាំងពិភពលោក។ ជានិច្ចកាល សកម្មភាពរបស់ព្រះ គឺក្នុងគោលបំណងជួយមនុស្ស ឲ្យ

យល់ពីតម្រូវការរបស់ពួកគេ ចំពោះទ្រង់ ហើយប្រហែលស្រវាឈោងចាប់ ហើយស្វែងរកទ្រង់។ (កិច្ចការ ១៧:២៦-២៧)

- តើមានអ្វីផ្សេងទៀត ដែលអ្នកឃើញអំពីព្រះ នៅក្នុងអត្ថបទនេះ? (សរសេរការសង្កេតរបស់អ្នក នៅក្នុងផ្នែក នៃក្បួនតម្រានេះ ដែលមានចំណងជើងថា “សេចក្ដីសង្គ្រោះរបស់ព្រះ” “ព្រះរាជលក្ខណៈរបស់ព្រះ” និង “សេចក្ដីសន្យារបស់ព្រះ”)

## អ័ប្រាហាំ និងសារ៉ា

សូមអាន លោកុប្បត្តិ ១១:២៧ - ២៥:១១

សេចក្ដីសន្យារបស់ព្រះ ចំពោះអ័ប្រាហាំ នៅក្នុងគម្ពីរ លោកុប្បត្តិ ផ្ដល់ជាគ្រឹះ សម្រាប់ព្រះ ដើម្បីបង្ហាញសេចក្ដីស្រឡាញ់ដ៏អស្ចារ្យ និងអំណាចគ្រប់ព្រះចេស្ដា តាមរយៈប្រវត្តិសាស្ត្រទាំងមូល រហូតដល់ការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវគ្រីស្ទ ដ៏ជាស្ដេច។ ព្រះមានផែនការប្រទានពរ ដល់ពិភពលោកទាំងមូល ហើយផែនការនោះ បានចាប់ផ្ដើមជាមួយអ័ប្រាហាំ។

**សេចក្ដីសន្យារបស់ព្រះ ដែលត្រូវបានធ្វើឡើង ដើម្បីបង្ហាញថា ព្រះទ្រង់កំពុងគ្រប់គ្រងប្រវត្តិសាស្ត្រ**

- ព្រះទ្រង់បានតាំង អ័ប្រាហាំ ជាឪពុកនៃ **ជាតិសាសន៍មួយខាងរូបកាយ** ដែលព្រះបានសន្យាថា នឹងមានរហូតដល់ព្រះយេស៊ូវយាងត្រឡប់មកវិញ (លោកុប្បត្តិ ១៣:១៥) ។
- ព្រះទ្រង់ក៏បានតាំង អ័ប្រាហាំជាឪពុក នៃ**គ្រួសារខាងវិញ្ញាណ** ដែលនឹងស្ថិតស្ថេរជារៀងរហូត។ (រ៉ូម ៤:១-១៧)
- ទាំងប្រជាជាតិខាងរូបកាយ និងក្រុមគ្រួសារខាងវិញ្ញាណ បានចាប់ផ្ដើមនៅក្នុងគម្ពីរ លោកុប្បត្តិ ជាមួយអ័ប្រាហាំ (រ៉ូម ៤:១៦) ។ អ្វីទាំងអស់ដែលយើងបានឃើញ ព្រះធ្វើជាមួយប្រជាជាតិខាងរូបកាយ បង្កើនទំនុកចិត្តរបស់យើង អំពីអ្វីដែលទ្រង់បានសន្យាថា នឹងធ្វើជាមួយគ្រួសារខាងវិញ្ញាណរបស់ទ្រង់។

ព្រះទ្រង់បានប្រទានសេចក្ដីសន្យាបី ដល់អ័ប្រាហាំ។

១. “យើងនឹងបង្កើតជាតិសាសន៍មួយដ៏ធំពីអ្នក”។ (លោកុប្បត្តិ ១២:២)
២. “យើងនឹងឲ្យពរអ្នក ហើយធ្វើឲ្យអ្នកមានឈ្មោះល្បី ដើម្បីឲ្យអ្នកបានជាទីបញ្ចេញពរដល់មនុស្សទាំងឡាយ”។ (លោកុប្បត្តិ ១២: ៣)
៣. យើងនឹងប្រគល់ស្រុកកាណាន ដល់អ្នក និងកូនចៅរបស់អ្នក រហូតតទៅ។ (លោកុប្បតត្តិ ១៣: ១៤-១៧)

សេចក្តីសន្យាទាំងនេះ ត្រូវបានធ្វើឡើងម្តងហើយម្តងទៀត សរុបចំនួន ប្រាំដង គ្រាន់តែនៅក្នុងគម្ពីរ លោកុប្បត្តិ! សេចក្តីសន្យា អំពីអ្វីដែលព្រះនឹងធ្វើសម្រាប់កូនចៅរបស់អ័ប្រាហាំ អ៊ីសាក និងយ៉ាកុប (អ៊ីស្រាអែល) គឺជាគ្រឹះសម្រាប់ព្រះ ដើម្បីបង្ហាញថា ទ្រង់អាចគ្រប់គ្រងព្រឹត្តិការណ៍ទាំងអស់ នៅលើពិភពលោក។ សូម្បីតែសព្វថ្ងៃនេះ ព្រះកំពុងតែបំពេញសេចក្តីសន្យាទាំងនេះ សម្រាប់សាសន៍អ៊ីស្រាអែល ដែលជាកូនចៅរបស់អ័ប្រាហាំ។

- ព្រះបានសន្យាម្តងហើយម្តងទៀត ចំពោះលោកអ័ប្រាហាំ បីដង ទៀត (លោកុប្បត្តិ ១៧:៣-៨, ១៨:១៨-១៩, ២២:១, ៦-១៨) ។
- ក្រោយមក ព្រះបានសន្យាម្តងទៀត ចំពោះអ៊ីសាក (លោកុប្បត្តិ ២៦:៣-៤) និងយ៉ាកុប (លោកុប្បត្តិ ២៨:១៤)។
- យ៉ូសែបបានយល់ច្បាស់ ពីសេចក្តីសន្យារបស់ព្រះ។ លោកយ៉ូសែបមានប្រសាសន៍ទៅបងប្អូនរបស់លោកថា៖ «ខ្ញុំជិតស្លាប់ហើយ។ ប៉ុន្តែ ព្រះនឹងជួយអ្នកហើយនាំអ្នកចេញពីស្រុកនេះទៅស្រុកដែលព្រះអង្គបានសន្យា ជាមួយលោកអ័ប្រាហាំ អ៊ីសាក និងលោកយ៉ាកុប»។ (លោកុប្បត្តិ ៥០:២៤)
- មូលដ្ឋានសម្រាប់ព្រះត្រាស់ហៅលោកម៉ូសេ គឺដើម្បីបំពេញតាមសេចក្តីសន្យា ដែលទ្រង់បានសន្យាថា «ព្រះទ្រង់ឮការស្រែកថ្ងូររបស់គេ ហើយព្រះនឹកចាំពីសេចក្តីសញ្ញាដែលព្រះអង្គបានតាំងជាមួយលោកអ័ប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប»។ (និក្ខមនំ ២:២៤)
- នៅពេលដែលព្រះត្រាស់ហៅលោកម៉ូសេភ្លាម ព្រះអង្គបានមានព្រះបន្ទូល អំពីសេចក្តីសន្យាដែលព្រះអង្គបានធ្វើ ចំពោះលោកអ័ប្រាហាំថា "យើងសម្រេចថា យើងនឹងនាំអ្នករាល់គ្នាចេញពីទុក្ខលំបាកនៅស្រុកអេស៊ីប្ទ ទៅកាន់ស្រុករបស់សាសន៍កាណាន សាសន៍ហេត សាសន៍អាម៉ូរី សាសន៍ពេរិស៊ីត សាសន៍ហេវី និងសាសន៍យេប៊ូសវិញ ជាស្រុកដែលមានទឹកដោះ និងទឹកឃ្មុំហូរហៀរ"។ (និក្ខមនំ ៣:១៧)
- ព្រះបានប្រាប់ម៉ូសេ ឲ្យប្រាប់សាសន៍អ៊ីស្រាអែលថា៖ «យើងនឹងនាំអ្នករាល់គ្នាចូលទៅក្នុងស្រុកដែលយើងបានលើកដៃស្បថថា នឹងឲ្យដល់អ័ប្រាហាំ អ៊ីសាក និងយ៉ាកុប យើងនឹងឲ្យស្រុកនោះដល់អ្នករាល់គ្នាទុកជាកេរអាករ យើងជាព្រះយេហូវ៉ា»។ (និក្ខមនំ ៦:៨) **ចំណាំ:** សេចក្តីថ្លែងនេះ គឺជាផ្នែកនៃបុណ្យរំលង ដែលសាសន៍យូដា នៅតែអានជារៀងរាល់ឆ្នាំ នៅបុណ្យរំលង (និក្ខមនំ ៦:៦-៨) ដែលរួមបញ្ចូលទាំងសេចក្តីសន្យាទាំងបួន សម្រាប់ពែងទាំងបួន។ ។
- ក្រោយមក នៅពេលដែលលោកម៉ូសេ បានអធិស្ឋានសម្រាប់ប្រជាជន គាត់បានយល់ច្បាស់ អំពីសេចក្តីសន្យាទាំងនេះ ៥០០ ឆ្នាំបន្ទាប់ពីពួកគេបានធ្វើ។ លោកមានប្រសាសន៍ថា៖ "សូមនឹកចាំពីលោកអ័ប្រាហាំ លោកអ៊ីសាក និងលោកអ៊ីស្រាអែល ជាអ្នកបម្រើរបស់ព្រះអង្គ ដែលព្រះអង្គបានស្បថនឹងលោកទាំងនោះ ដោយព្រះអង្គទ្រង់ថា យើងនឹងចម្រើនពូជអ្នកឲ្យបានដូចជាផ្កាយនៅលើមេឃ ឯស្រុកទាំងនេះដែលយើងបានសន្យាថានឹងឲ្យដល់ពូជពង្សរបស់អ្នក ហើយពួកគេនឹងទទួលស្រុកនោះទុកជាមរតករហូតតទៅ" (និក្ខមនំ ៣២:១៣)។ ប្រាំពីរដងទៀត ដែលម៉ូសេបានសំដៅទៅដល់ទឹកដី ដែលព្រះបានសន្យា ដល់កូនចៅអ័ប្រាហាំ អ៊ីសាក និងយ៉ាកុប (ជនគណនា ៣២:១១, ចោទិយកថា ១:៨ , ៦:១០, ៩:៥, ២៩:១៣, ៣០:២០, ៣៤:៤) ។

- នៅចុងបញ្ចប់នៃជីវិតរបស់លោកម៉ូសេ គាត់បានកោតស្ញប់ស្ញែង ចំពោះអ្វីដែលព្រះបានធ្វើ ដើម្បីសម្រេចសេចក្តីសន្យារបស់ទ្រង់ ចំពោះអ័ប្រាហាំ និងនាំសាសន៍អ៊ីស្រាអែល ចេញពីស្រុកអេស៊ីព្ទត្រឡប់ទៅស្រុកកាណានវិញ។ គាត់បាននិយាយថា៖

  *"ចូរសាកសួរពីអស់ទាំងថ្ងៃកន្លងមក គឺតាំងពីមុនអ្នកកើតមក ចាប់តាំងពីថ្ងៃដែលព្រះទ្រង់បានបង្កើតមនុស្សនៅលើផែនដី ចូរសាកសួរពីជើងមេឃម្ខាងទៅជើងមេឃម្ខាង តើដែលមានការដ៏ធំបែបនេះ ឬដែលមានឮនិយាយពីការបែបនេះឬទេ? តើដែលមានសាសន៍ណាឮព្រះសូរសៀងព្រះទ្រង់មានព្រះបន្ទូលពីកណ្តាលភ្លើងមក ដូចជាអ្នកបានឮ ហើយនៅរស់ឬទេ? ឬតើដែលមានព្រះណាប្រថុយទៅយកសាសន៍មួយសម្រាប់អង្គទ្រង់ ពីកណ្តាលសាសន៍មួយទៀត ដោយសារការល្បង ដោយទីសម្គាល់ ដោយការអស្ចារ្យ ដោយចម្បាំង ដោយព្រះហស្តដ៏ខ្លាំងពូកែ និងដោយព្រះពាហុលើកសម្រេច ហើយដោយការគួរស្ញែងខ្លាចដ៏ធំ ដូចជាគ្រប់ទាំងការដែលព្រះយេហូវ៉ាជាព្រះរបស់អ្នកបានធ្វើសម្រាប់អ្នកនៅស្រុកអេស៊ីព្ទ នៅចំពោះមុខអ្នកឬទេ? ការទាំងនោះបានសម្តែងមកឲ្យអ្នកឃើញ ដើម្បីឲ្យអ្នកបានដឹងថា ព្រះយេហូវ៉ាពិតជាព្រះមែន ក្រៅពីព្រះអង្គគ្មានព្រះឯណាទៀតឡើយ។ ព្រះអង្គធ្វើឲ្យអ្នកឮព្រះសូរសៀងព្រះអង្គពីលើមេឃ ដើម្បីអប់រំអ្នក។ នៅលើផែនដី ព្រះអង្គឲ្យអ្នកបានឃើញភ្លើងដ៏ធំរបស់ព្រះអង្គ ហើយអ្នកបានឮព្រះបន្ទូលរបស់ព្រះអង្គចេញពីកណ្តាលភ្លើងនោះមក។ ដោយព្រោះព្រះអង្គបានស្រឡាញ់បុព្វបុរសរបស់អ្នក ព្រះអង្គក៏បានរើសយកពូជពង្សរបស់ពួកគេនៅជំនាន់ក្រោយ។ ព្រះអង្គបាននាំអ្នកចេញពីស្រុកអេស៊ីព្ទមកនៅចំពោះព្រះអង្គ ដោយព្រះចេស្តាដ៏ធំរបស់ព្រះអង្គ ដោយបណ្តេញសាសន៍នានាដែលធំ ហើយពូកែជាងអ្នក ចេញពីមុខអ្នក ដើម្បីនាំអ្នកចូលទៅ ហើយប្រគល់ស្រុករបស់គេឲ្យអ្នក ទុកជាមរតក ដូចមាននៅថ្ងៃនេះ។ ដូច្នេះ ចូរដឹងនៅថ្ងៃនេះ ហើយកំណត់ទុកក្នុងចិត្តចុះថា ព្រះយេហូវ៉ា ពិតជាព្រះនៅលើស្ថានសួគ៌ និងនៅផែនដីនេះ គ្មានព្រះឯណាទៀតឡើយ"* (ចោទិយកថា ៤:៣២-៣៩) (អត្ថបទដកស្រង់ ដោយមានការអនុញ្ញាត។)

- ប្រមាណ ៥០០ ឆ្នាំ ក្រោយពី លោកអ័ប្រាហាំ (ប្រហែល ២០០០ មុន គ.ស.) ព្រះបានមានបន្ទូល ទៅយ៉ូស្វេ (ប្រហែល ១៤០០ មុន គ.ស.) ថា៖ "ចូរឲ្យមានកម្លាំង និងចិត្តក្លាហានចុះ ដ្បិតអ្នកនឹងនាំឲ្យប្រជាជននេះបានគ្រងស្រុក ដែលយើងបានស្បថថា នឹងឲ្យដល់បុព្វបុរសរបស់គេ" (យ៉ូស្វេ ១:៦)។
- បន្ទាប់ពីលោកយ៉ូស្វេ ក្នុងអំឡុងពេលនៃពួកចៅហ្វាយ សាសន៍អ៊ីស្រាអែល បានដាច់ចេញឆ្ងាយពីព្រះ ហើយខ្មាំងសត្រូវរបស់ពួកគេបានចាប់ផ្តើមបង្ក្រាបពួកគេ។ វាបានក្លាយជាកាន់តែអាក្រក់ ដែលបានចាប់ផ្តើមមើលទៅ ដូចជាពួកភីលីស្ទីននឹងកាន់កាប់។ ចំណុចរបត់ បានកើតឡើង នៅពេលដែលក្មេងប្រុសដាវីឌ បានឈរតទល់នឹងបុរសមាឌធំ សាសន៍ភីលីស្ទីន គឺកូលីយ៉ាត។ បន្ទាប់មក ដាវីឌបានដឹកនាំសាសន៍អ៊ីស្រាអែល ទទួលបានជ័យជំនះជាច្រើន ប្រឆាំងនឹងសត្រូវរបស់ពួកគេ ហើយអ៊ីស្រាអែល បានក្លាយជាប្រជាជាតិមួយ ដែលមានអំណាច។ នេះគឺ ប្រហែលជា ៤០០ ឆ្នាំ បន្ទាប់ពីលោកម៉ូសេ ហើយវាបានជម្រុញ ឲ្យដាវីឌ និងអ្នកដទៃសរសេរអំពីភាពស្មោះត្រង់របស់ព្រះ ចំពោះអ៊ីស្រាអែល នៅពេលដែលទ្រង់បានធ្វើតាមសេចក្តីសន្យារបស់ទ្រង់ ចំពោះអ័ប្រាហាំ ហើយបានប្រទានសេចក្តីសង្គ្រោះពីសត្រូវរបស់ពួកគេ ដែលកំពុងកាន់កាប់។ ទំនុកតម្កើង ៩៨:១-៣ ជាគម្រូល្អ

*“ចូរច្រៀងបទថ្មីថ្វាយព្រះយេហូវ៉ា ដ្បិតព្រះអង្គបានធ្វើការយ៉ាងអស្ចារ្យ។ ព្រះហស្តស្តាំ និងព្រះពាហុដ៏បរិសុទ្ធរបស់ព្រះអង្គ បាននាំឲ្យព្រះអង្គមានជ័យជម្នះ។ ព្រះយេហូវ៉ាបានសម្តែងឲ្យស្គាល់ការសង្គ្រោះរបស់ព្រះអង្គ។ ព្រះអង្គបានបង្ហាញឲ្យសាសន៍នានា ឃើញសេចក្តីសុចរិតរបស់ព្រះអង្គ។ ព្រះអង្គបាននឹកចាំពីព្រះហឫទ័យសប្បុរស និងព្រះហឫទ័យស្មោះត្រង់របស់ព្រះអង្គ ដល់ពូជពង្សអ៊ីស្រាអែល មនុស្សទាំងអស់រហូតដល់ចុងផែនដី បានឃើញការសង្គ្រោះរបស់ព្រះនៃយើង”។*

- នៅក្នុង ទំនុកតម្កើង ១០៥ អ្នកតែងទំនុកតម្កើងបានរៀបរាប់ អំពីរបៀបដែលព្រះបានសន្យា ដល់អ័ប្រាហាំ អ៊ីសាក និងយ៉ាកុប ហើយបន្ទាប់មក គាត់បានសង្ខេបពីការអស្ចារ្យ ដែលព្រះបានធ្វើតាមរយៈប្រវត្តិសាស្រ្ត រហូតដល់ត្រង់ចំណុចនោះ ដើម្បីរក្សាសេចក្តីសន្យារបស់ទ្រង់។ គាត់បានសរសេរៈ

*«ឱចូរអរព្រះគុណដល់ព្រះយេហូវ៉ា ចូរអំពាវនាវរកព្រះនាមព្រះអង្គ ចូរថ្លែងប្រាប់ពីស្នាព្រះហស្តរបស់ព្រះអង្គ នៅកណ្តាលជាតិសាសន៍ទាំងប៉ុន្មានចុះ! . . . ចូរនឹកចាំពីស្នាព្រះហស្តដ៏អស្ចារ្យដែលព្រះអង្គបានធ្វើ ពីការអស្ចារ្យ និងការជំនុំជម្រះ ដែលព្រះអង្គបានសម្រេច។. . . ព្រះអង្គនឹកចាំពីសេចក្តីសញ្ញា របស់ព្រះអង្គជានិច្ច . . . ជាសេចក្តីសញ្ញាដែលព្រះអង្គ បានតាំងជាមួយលោកអ័ប្រាហាំ ជាសេចក្តីសន្យាដែលព្រះអង្គ បានស្បថជាមួយលោកអ៊ីសាក ហើយព្រះអង្គក៏បានបញ្ជាក់ ជាមួយលោកយ៉ាកុបទុកជាក្រឹត្យវិន័យ គឺជាមួយលោកអ៊ីស្រាអែល ទុកជាសេចក្តីសញ្ញាអស់កល្បជានិច្ច ដោយមានព្រះបន្ទូលថា៖ «យើងនឹងប្រគល់ស្រុកកាណានឲ្យអ្នក ទុកជាចំណែកមរតករបស់អ្នក»* ។(អត្ថបទដកស្រង់ ត្រូវបានប្រើដោយការអនុញ្ញាត។ )

- បន្ទាប់មកដាវីឌ បន្តពិនិត្យមើលប្រវត្តិ នៃអ្វីដែលព្រះបានធ្វើ ជាមួយយ៉ូសែបនៅស្រុកអេស៊ីព្ទ យ៉ាកុបនៅស្រុកអេស៊ីព្ទ ម៉ូសេ គ្រោះកាច និងអ្វីដែលព្រះបានធ្វើ ដើម្បីនាំប្រជាជន ចេញពីស្រុកអេស៊ីព្ទ និងត្រឡប់ទៅស្រុកកាណានវិញ (ទំនុកតម្កើង ១០៥:១-៤៥) ។ នៅក្នុង របាក្សត្រទី១ ១៦:១២-២២ ផ្នែកដំបូង នៃដំណើររឿងនេះ ត្រូវបានកត់ត្រាទុកផងដែរ។
- សូម្បីតែនៅពេលដែលអ៊ីស្រាអែលភ្លេចអំពីព្រះនៅគ្រាលំបាកនៃស្តេចក៏ដោយក៏ព្រះបាននឹកចាំពីសេចក្តីសន្យារបស់ព្រះអង្គថា៖ «ប៉ុន្តែព្រះអម្ចាស់មានព្រះហឫទ័យអាណិតអាសូរពួកគេហើយមានព្រះហឫទ័យអាណិតអាសូរនិងយកចិត្តទុកដាក់ចំពោះពួកគេព្រោះតែសម្ពន្ធមេត្រីរបស់ព្រះអង្គជាមួយអ័ប្រាហាំអ៊ីសាកនិងយ៉ាកុប។ រហូតមកដល់សព្វថ្ងៃនេះព្រះអង្គមិនចង់បំផ្លាញពួកគេឬបណ្ដេញពួកគេចេញពីព្រះវត្តមានរបស់ទ្រង់ឡើយ។ (ពង្សាវតារក្សត្រទី ២ ១៣: ២៣)
- ព្រះបានមានបន្ទូលថា ទ្រង់នឹងរក្សាសេចក្តីសន្យាទាំងនេះ រហូតដល់អនាគត នៅពេលដែលព្រះយេស៊ូវគ្រីស្ទបង្កើតឡើងនូវការគ្រប់គ្រងរបស់ទ្រង់។ យើងឃើញរឿងនេះនៅពេលដែលគាត់បានប្រាប់អេសេគាលថាគាត់នឹងបំពេញសេចក្តីសន្យាទាំងនេះនៅពេលដែលដាវីឌជាអ្នកបម្រើរបស់គាត់នឹងឡើងសោយរាជ្យលើពួកគេ (នៅពេលដែលព្រះយេស៊ូវគ្រីស្ទជាព្រះមេស្ស៊ីជាស្តេច) ។ (អេសេគាល ៣៧: ២០-២៨)

**ហើយ នោះគឺគ្រាន់តែជា ការចាប់ផ្តើម!** យើងបានឃើញ ព្រះបន្ថែមព្រឹត្តិការណ៍អស្ចារ្យជាច្រើនទៀត ទៅក្នុងបញ្ជី នៃអ្វីដែលទ្រង់បានធ្វើ ដើម្បីដកកូនចៅអ៊ីស្រាអែល ចេញពីទឹកដីដោយសារការមិនស្តាប់បង្គាប់ ហើយបន្ទាប់មក នាំពួកគេត្រឡប់មកវិញ តាមរបៀបនៃការអស្ចារ្យជានិច្ច។ នោះពិតជាអស្ចារ្យណាស់ ចំពោះអ្វីដែលព្រះបានធ្វើ ជាមួយប្រជាជនអ៊ីស្រាអែល។ លោកម៉ូសេបានគិតដូច្នេះ នៅជំនាន់របស់គាត់ កាលពី ៤០០០ ឆ្នាំមុន ហើយក៏អស្ចារ្យជាងនេះទៅទៀត នៅសព្វថ្ងៃនេះ! (សូមអាន ផ្នែកនេះ *"កូនចៅអ៊ីស្រាអែលវិលត្រឡប់ ត្រូវបានដកចេញ ហើយវិលត្រឡប់មកវិញ ម្តងហើយម្តងទៀត"*។ សេចក្តីសន្និដ្ឋានជាក់ស្តែងគឺថា **ព្រះជាម្ចាស់កំពុងគ្រប់គ្រងពិភពលោកនិងប្រវត្តិទាំងអស់!**

## សេចក្តីសង្ខេបត្រួសៗ ពីជីវិតរបស់អ័ប្រាហាំ

- ព្រះបានត្រាស់បង្គាប់អាប់រ៉ាម (ក្រោយមក ហៅថា អ័ប្រាហាំ) ឲ្យផ្លាស់ទីលំនៅពីហារ៉ាន (សព្វថ្ងៃស្ថិតនៅភាគខាងជើង ប្រទេសស៊ីរី) ទៅស្រុកកាណាន (អ៊ីស្រាអែលបច្ចុប្បន្ន) ។ (លោកុប្បត្តិ ១១: ៣១ - ១២:១) នេះគឺជាទឹកដី ដែលព្រះបានសន្យាថា នឹងប្រទានកូនចៅរបស់អ័ប្រាហាំ អស់ពេញមួយប្រវត្តិសាស្ត្រ។
- អ័ប្រាហាំមានចិត្តទន់សណ្តោសចំពោះឡុត ហើយអនុញ្ញាតឲ្យគាត់ជ្រើសរើសយកដីល្អបំផុតតាមដែលគាត់ចង់បាន (លោកុប្បត្តិ ១៣: ៥-១៨) ។ អ័ប្រាហាំជឿជាក់ថា ព្រះនឹងថែរក្សាគាត់។
- សារ៉ា និងអ័ប្រាហាំបានបង្កើតគំនិតមួយគឺ អ័ប្រាហាំអាចមានកូនតាមរយៈអ្នកបម្រើម្នាក់របស់ពួកគេ គឺហាការ។ ពួកគេបានធ្វើដូច្នេះ ប៉ុន្តែព្រះមានបន្ទូលថា នេះមិនអាចជាកូន ដែលទ្រង់នឹងបំពេញតាមសេចក្តីសន្យារបស់ទ្រង់ទេ (លោកុប្បត្តិ ១៦)។ កូនរបស់ហាការ មានឈ្មោះថា អ៊ីសម៉ាអែល ហើយបានក្លាយជាឪពុករបស់សាសន៍អារ៉ាប់។
- អ័ប្រាហាំ និងសារ៉ាគ្មានកូន រហូតទាល់តែអ័ប្រាហាំ មានអាយុ ១០០ ឆ្នាំ ហើយសារ៉ា មានអាយុ ៩០ ឆ្នាំ (លោកុប្បត្តិ ១៧:១៧) ។ អ៊ីសាក ជាកូនតែមួយរបស់ពួកគេ (លោកុប្បត្តិ ២១:១-៧)។
- ព្រះបានឲ្យអ័ប្រាហាំថ្វាយកូនប្រុសតែមួយរបស់គាត់ គឺអ៊ីសាក ជាយញ្ញបូជា ដល់ទ្រង់។ (លោកុប្បត្តិ ២២: ១-១៩) នេះហាក់ដូចជាផ្ទុយ ពីសេចក្តីសន្យារបស់ព្រះ ប៉ុន្តែអ័ប្រាហាំមានជំនឿរឹងមាំថា ព្រះនឹងធ្វើអ្វីដែលពិសេស ដើម្បីបំពេញសេចក្តីសន្យារបស់ទ្រង់ (ហេព្រើរ ១១:១៧-១៩) ។ ព្រះបានធ្វើអន្តរាគមន៍ និងបានប្រទានចៀមឈ្មោលមួយ សម្រាប់ជាយញ្ញបូជា ជំនួសអ៊ីសាក។
- ព្រះបានឲ្យអ័ប្រាហាំធ្វើដំណើរបីថ្ងៃ ទៅកាន់ទីតាំងជាក់លាក់មួយ ដែលគាត់គួរតែថ្វាយកូនប្រុសរបស់គាត់។ នេះស្ថិតនៅលើភ្នំមួយ នៃភ្នំម៉ូរីយ៉ា (លោកុប្បត្តិ ២២:២)។ នេះគឺជាទីតាំងតែមួយ ដែលក្រុងយេរូសាឡិម ត្រូវបានសាងសង់ និងកន្លែងដែលព្រះយេស៊ូវ ត្រូវបានថ្វាយយញ្ញបូជា ជាព្រះរាជបុត្រាតែមួយរបស់ព្រះ (របាក្សត្រទី២ ៣:១)។
- ដោយសារជំនឿ មិនមែនជាការប្រព្រឹត្តទេ ដែលជាមូលដ្ឋាន នៃសេចក្តីសុចរិត របស់អ័ប្រាហាំ (លោកុប្បត្តិ ១៥:៦) ។ ជំនឿរបស់គាត់ក៏ត្រូវបានលើកជាឧទាហរណ៍នៅក្នុង រ៉ូម ៤:១-៥ និងកាឡាទី ៣:៥-៨ ។ ការប្រព្រឹត្ត (ការស្តាប់បង្គាប់) ជាលទ្ធផល នៃជំនឿ។

- តើមានអ្វីផ្សេងទៀត ដែលអ្នកបានរៀនអំពីព្រះ នៅក្នុងគម្ពីរ លោកុប្បត្តិ ជំពូកទាំងនេះ? (សរសេរការសង្កេតរបស់អ្នក នៅក្នុងផ្នែកនៃក្បួនតម្រានេះ ដែលមានចំណងជើងថា "សេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់" "ព្រះរាជលក្ខណៈរបស់ព្រះ" និង "សេចក្ដីសន្យារបស់ព្រះ")

## យ៉ាកុប និងយ៉ូសែប

សូមអាន លោកុប្បត្តិ ២៨ - ៣២ និងលោកុប្បត្តិ ៣៧ - ៥០

អ័ប្រាហាំ និងសារ៉ា មានកូនប្រុសតែមួយ នៅក្នុងអាពាហ៍ពិពាហ៍ ដែលពួកគេដាក់ឈ្មោះថា អ៊ីសាក។ អ៊ីសាកបានរៀបការជាមួយរេបិកា ជាចម្លើយចំពោះការអធិស្ឋាន (លោកុប្បត្តិ ២៤) ។ ពួកគេមានកូនប្រុសពីរនាក់ គឺអេសាវ និងយ៉ាកុប។ ផែនការរបស់ព្រះ គឺធ្វើការតាមរយៈកូនចៅរបស់យ៉ាកុប (ក្រោយមក ត្រូវបានដាក់ឈ្មោះថ្មីថា អ៊ីស្រាអែល) ដើម្បីបង្ហាញពីភាពជំឧត្ដមរបស់ទ្រង់។

- យ៉ាកុបមានកូនប្រុស ១២ នាក់ តាមរយៈប្រពន្ធពីរនាក់។ កូនប្រុសទាំងនេះ បានក្លាយជាដើមកំណើត នៃកុលសម្ព័ន្ធអ៊ីស្រាអែលទាំងដប់ពីរ ដែលបានបង្កើតឡើងជាប្រជាជាតិអ៊ីស្រាអែល។
- យ៉ាកុបមានបទពិសោធន៍មិនធម្មតាមួយ ដោយការប្រយុទ្ធជាមួយបុរសម្នាក់ ដែលជាតំណាងព្រះជាម្ចាស់ (លោកុប្បត្តិ ៣២:២២-៣២)។ បន្ទាប់ពីការបោកចម្បាប់នោះ ព្រះសារត្រូវបានប្រាប់ថា ព្រះនឹងប្ដូរឈ្មោះរបស់គាត់ ពីយ៉ាកុប (មានន័យថា "គាត់ចាប់កែងជើង" ឬ "បោកបញ្ឆោត") ទៅជាអ៊ីស្រាអែល (មានន័យថា "តយុទ្ធជាមួយព្រះ")។
- ជីវិតរបស់យ៉ាកុប ត្រូវបានសង្គ្រោះដោយសារកូនប្រុសរបស់គាត់ ឈ្មោះយ៉ូសែប ដែលទំនងជាបានស្លាប់។ នេះបាននាំមកនូវព្រះពរសម្រាប់គ្រួសារទាំងមូល ដែលជារូបភាព នៃអ្វីដែលព្រះបានធ្វើតាមរយៈពូជរបស់គាត់គឺ ព្រះយេស៊ូវ ដល់មនុស្សទាំងអស់។
- ទង្វើអាក្រក់ ហាក់ដូចជាមានច្រើនដង មកលើជីវិតរបស់យ៉ូសែប ប៉ុន្តែវាច្បាស់ណាស់ថា ព្រះបានគ្រប់គ្រងអ្វីៗទាំងអស់ ដោយប្រើប្រាស់ព្រឹត្តិការណ៍អាក្រក់ ដើម្បីនាំមកនូវព្រះពរដ៏ជំធេង សម្រាប់គ្រួសារទាំងអស់ របស់លោកយ៉ាកុប។
- ព្រះបានយកព្រះទ័យទុកដាក់ ចំពោះយ៉ាកុប និងក្រុមគ្រួសាររបស់គាត់គ្រប់ពេល សូម្បីតែពួកគេបានប្រព្រឹត្តអំពើអាត្មានិយម និងសូម្បីតែពេលដែលអ្វីៗ ហាក់ដូចជាដំណើរការខុសក៏ដោយ (លោកុប្បត្តិ ៤២:៣៦ "អ្វីៗទាំងអស់ប្រឆាំងនឹងខ្ញុំ"!)
- យ៉ូសែបមានទំនុកចិត្តថា ព្រះនឹងស្មោះត្រង់ចំពោះសេចក្ដីសន្យារបស់ទ្រង់ ចំពោះអ័ប្រាហាំ អ៊ីសាក និងយ៉ាកុប ដូច្នេះគាត់បានសុំកូនចៅរបស់គាត់ ឲ្យយកឆ្អឹងរបស់គាត់ ត្រឡប់ទៅទឹកដី ដែលព្រះបានសន្យាជាមួយពួកគេ (លោកុប្បត្តិ ៥០:២៤-២៦)។
- ក្នុងជំពូកទាំងនេះ ដែលស្ដីអំពីយ៉ាកុប និងយ៉ូសែប តើអ្នកសង្កេតឃើញមានអ្វីទៀត? (សរសេរការសង្កេតរបស់អ្នក នៅក្នុងផ្នែកនៃក្បួនតម្រានេះ ដែលមានចំណងជើងថា "សេចក្ដីសង្គ្រោះរបស់ព្រះ" "ព្រះរាជលក្ខណៈរបស់ព្រះ" និង "សេចក្ដីសន្យារបស់ព្រះ")។

## លោកម៉ូសេ

សូមអាន និក្ខមនំ ១ - ២០, ៣២-៣៦, ៤០

សូមអាន ជនគណនា ១០:១១ - ១៤:៤៥, ជំពូក ២១

សូមអាន ចោទិយកថា ២៧ - ២៨, ៣១:១-៨, ៣២:៤៨-៥២, ៣៤:១-១២ ។

- កំណើតរបស់លោកម៉ូសេ និងការត្រាស់ហៅរបស់ព្រះ ចំពោះលោកម៉ូសេ - និក្ខមនំ ១-៤ ។
- ព្រះបានប្រាប់លោកម៉ូសេថា ព្រះអង្គមិនភ្លេចផែនការរបស់ទ្រង់ទេ ហើយទ្រង់នឹងនាំកូនចៅអ៊ីស្រាអែល វិលត្រឡប់ទៅទឹកដី ដែលទ្រង់បានសន្យាជាមួយលោកអ័ប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប (អ៊ីស្រាអែល) ។
- ព្រះបានជំនុំជម្រះសាសន៍អេស៊ីព្ទ ចំពោះការប្រព្រឹត្តរបស់ពួកគេ លើសាសន៍អ៊ីស្រាអែល និងចំពោះការបដិសេធមិនឲ្យពួកគេថ្វាយបង្គំព្រះ។ ទ្រង់បានជំនុំជម្រះពួកគេ ដោយគ្រោះកាចទាំង ១០ ដែលចុងក្រោយ គឺការស្លាប់របស់កូនប្រុសច្បង (និក្ខមនំ ៧ - ១១) ។ ប៉ុន្តែ ប្រសិនបើបានលាបឈាមរបស់កូនចៀម នៅខាងលើទ្វារនោះ ទេវតានៃសេចក្ដីស្លាប់ នឹងបានរំលងគ្រួសារនោះ។ នៅពេលនេះ ព្រះបានរៀបចំបុណ្យរំលង សម្រាប់ជាការចងចាំ ពីព្រឹត្តិការណ៍នេះ និងជារូបភាព នៃអ្វីដែលទ្រង់នឹងធ្វើ នាពេលអនាគត ដើម្បីឲ្យមនុស្សទាំងអស់នៅលើពិភពលោក អាចរួចផុតពីការកាត់ទោសប្រហារជីវិត - និក្ខមនំ ១១:១ - ១២:១៧, និង ១២:២៩-៣៣, យ៉ូហាន ១:២៩, កូរិនថូសទី១ ៥:៧, វិវរណៈ ៥:១២-១៣ ។ *ចំណាំ - កត់ត្រាអ្វីដែលអ្នកឃើញ អំពីសេចក្ដីសង្គ្រោះរបស់ព្រះ នៅពេលអ្នកអាន អំពីបុណ្យរំលង និងព្រះយេស៊ូវ ជាកូនចៀម។* កត់ត្រាការសង្កេតរបស់អ្នក នៅក្នុងផ្នែកនៃសៀវភៅនេះ ដែលមានចំណងជើងថា “សេចក្ដីសង្គ្រោះរបស់ព្រះ” ។
- ព្រះបានផ្ដល់សេរីភាពពេញលេញ រួចពីសាសន៍អេស៊ីព្ទ នៅត្រង់សមុទ្រ (សមុទ្រក្រហម) - និក្ខមនំ ១៣:១៧ - ១៤:៣១ ។ នេះគឺជាការអស្ចារ្យមួយ ដែលនៅតែត្រូវបានគេចងចាំ និងពិភាក្សារហូតដល់ថ្ងៃនេះ។
- ព្រះបានផ្គត់ផ្គង់អាហារប្រចាំថ្ងៃ សម្រាប់ប្រជាជនជាងមួយលាននាក់ នៅទីរហោស្ថាន - និក្ខមនំ ១៦: ១-៣៦ ។
- ព្រះបានប្រទានក្រិត្យវិន័យ ទាំង ១០ ប្រការ ដល់លោកម៉ូសេ នៅលើភ្នំស៊ីណាយ (និក្ខមនំ ១៩) ។ បញ្ញត្តិទាំង ១០ ត្រូវបានកត់នៅក្នុង និក្ខមនំ ២០:១-២១ ។ ទាំងនេះគឺជាសេចក្ដីសង្ខេប នៃរបៀបដែលព្រះបានបង្កើតមនុស្ស ឲ្យរស់នៅ។ បួនប្រការដំបូង គឺសម្រាប់ទំនាក់ទំនងរបស់យើងជាមួយព្រះ។ ៦ ប្រការបន្ទាប់ គឺសម្រាប់ទំនាក់ទំនងរបស់យើង ជាមួយមនុស្ស។
- រោងឧបោសថ - និក្ខមនំ ៣៦-៣៨ ។ រោងឧបោសថត្រូវបានរចនាឡើងដោយសារព្រះ ដើម្បីជួបជាមួយប្រជារាស្ត្ររបស់ព្រះអង្គ (ដើមឡើយ ជាត្រសាលជំនុំ និក្ខមនំ ២៥:៨-៩, ៣៣:៧-១១)។ ការរចនានេះ បង្ហាញពីអ្វីដែលចាំបាច់ សម្រាប់មនុស្សមានបាប ដើម្បីជួបជាមួយព្រះ (ការថ្វាយយញ្ញបូជា និងលាងសម្អាត គឺចាំបាច់ណាស់) ។
- ក្រឹត្យវិន័យ និងការដាក់ទោសជាច្រើន បានបង្ហាញពីភាពធ្ងន់ធ្ងរ នៃអំពើបាប និងភាពបរិសុទ្ធរបស់ព្រះ។ ចៀម និងសត្វ ត្រូវបានថ្វាយជាយញ្ញបូជា ដោយសារអំពើបាប - និក្ខមនំ ២៩:៣៨-៤៦។ ពួក

គេត្រូវបានផ្តល់ជាការប្រៀបធៀប នៃសេចក្តីពិតអស់កល្បជានិច្ច (ហេព្រើរ ៨:១-៥) ។ *កត់ត្រាការសង្កេតរបស់អ្នក អំពីសេចក្តីសង្គ្រោះរបស់ព្រះ នៅលើទំព័រ នៃក្បួនតម្រានេះ។*

- ម៉ូសេបានចាត់អ្នកស៊ើបការណ៍ ១២ នាក់ ទៅស្រុកកាណាន ដែលពួកគេភាគច្រើនបានផ្តល់ព័ត៌មានអវិជ្ជមាន អំពីបញ្ហាពិបាកៗ - ជនគណនា ១៣។ តើមានលទ្ធផលយ៉ាងណា នៅពេលដែលប្រជាជនផ្តោតលើបញ្ហា ហើយភ្លេចសេចក្តីសន្យារបស់ព្រះ - ជនគណនា ១៤?
- ការចូលទឹកដី ដែលបានសន្យាជាមួយអ័ប្រាហាំ និងអ៊ីស្រាអែល - ព្រះបានប្រើសាសន៍អ៊ីស្រាអែល ដើម្បីជំនុំជម្រះទោសដល់មនុស្ស ដែលប្រឆាំងនឹងព្រះ ធ្វើតាមវិញ្ញាណអាក្រក់ ហើយបានថ្វាយកូនជាយញ្ញបូជា (លេវីវិន័យ ២០:១-២៤) ។ ព្រះក៏មានបន្ទូលប្រាប់សាសន៍អ៊ីស្រាអែលដែរថា ព្រះអង្គនឹងដាក់ទោសសាសន៍អ៊ីស្រាអែល អាក្រក់ជាងនេះ ប្រសិនបើពួកគេមិនរស់នៅជាមួយទ្រង់ (លេវីវិន័យ ២៦:១៤-៣៩; យ៉ូស្វេ ២៣:៩-១៦)។
- ព្រះគម្ពីរប្រាប់ថា លោកម៉ូសេជាមនុស្សដែលបន្ទាបខ្លួនបំផុតនៅលើផែនដី (ជនគណនា ១២:៣)។ សូមអានអ្វីដែលព្រះយេស៊ូវបានមានបន្ទូលអំពីការបន្ទាបខ្លួន (ម៉ាថាយ ១៨:១-៤ និង ២០:២០-២៨) ហើយប្រៀបធៀបរឿងនេះ ទៅនឹងលោកម៉ូសេ។
- តើមានអ្វីផ្សេងទៀត អំពីព្រះដែលកត់ទុក ក្នុងគម្ពីរ ស្តីពីលោកម៉ូសេ? (សរសេរការសង្កេតរបស់អ្នក នៅក្នុងផ្នែកនៃក្បួនតម្រានេះ ដែលមានចំណងជើងថា "សេចក្តីសង្គ្រោះរបស់ព្រះ" "ព្រះរាជលក្ខណៈរបស់ព្រះ" និង "សេចក្តីសន្យារបស់ព្រះ")។
- យ៉ូស្វេ គឺជាអ្នកដែលដឹកនាំជំនួសលោកម៉ូសេ ហើយបន្ទាប់មក ដឹកនាំប្រជាជន ដើម្បីដណ្តើមយកទឹកដី ដែលព្រះបានសន្យានឹងពួកគេ (យ៉ូស្វេ ១: ១-១៨)។

## កូនចៅអ៊ីស្រាអែលវិលត្រឡប់ ត្រូវបានដកចេញ ហើយវិលត្រឡប់មកវិញម្តងហើយម្តងទៀត

អ្វីដែលព្រះបានធ្វើ ជាមួយកូនចៅរបស់អ័ប្រាហាំ (ត្រូវបានគេស្គាល់ថា ជាសាសន៍អ៊ីស្រាអែល) តាំងពីកំណើតកូនប្រុសដំបូងរបស់គាត់ គឺអ៊ីសាក រហូតមកដល់សព្វថ្ងៃនេះ គឺពិសេសខុសគេ នៅលើពិភពលោក។ ដំណើរតាមលំដាប់ នៃការដកចេញ និងការវិលត្រឡប់ របស់ប្រជាជាតិអ៊ីស្រាអែលទាំងមូល ពីស្រុកកំណើតរបស់ពួកគេ គឺមានលក្ខណៈប្លែកពីគេ ក្នុងចំណោមប្រជាជាតិទាំងអស់ ក្នុងប្រវត្តិសាស្ត្រទាំងមូល។ ព្រឹត្តិការណ៍ជាមួយប្រជាជាតិអ៊ីស្រាអែល មិនត្រឹមតែក្នុងចំណោមប្រជាជាតិនានាប៉ុណ្ណោះទេ ក៏មានបទទំនាយបីព្រះ ហើយបទទំនាយត្រូវបានកត់ត្រា នៅក្នុងព្រះគម្ពីរ។ (សូមអាន ព័ត៌មាននៅក្នុងផ្នែក អំពីអ័ប្រាហាំ ដើម្បីរៀន ពីការចាប់ផ្តើម នៃការថ្លែងទំនាយទាំងនេះ)។ នេះគឺជាអត្ថបទគម្ពីរមួយចំនួនផ្សេងទៀត ដែលបានផ្តល់ព័ត៌មានលម្អិតបន្ថែមទៀត អំពីបទទំនាយទាំងនេះ ស្តីពីអ្វីដែលនឹងកើតឡើងចំពោះសាសន៍អ៊ីស្រាអែល។

- ស្រុកកាណាន នឹងជាកម្មសិទ្ធិនៃសាសន៍អ៊ីស្រាអែល*អស់កល្បជានិច្ច* (លោកុប្បត្តិ ១៧:៧-៨)។
- លេវីវិន័យ ២៦: ៣៣-៣៨ - សាសន៍អ៊ីស្រាអែល នឹងត្រូវដកចេញពីប្រទេសរបស់ខ្លួន។
- ចោទិយកថា ២៨: ៤៩- ៦៨ - សាសន៍អ៊ីស្រាអែល នឹងត្រូវដកចេញពីប្រទេសរបស់ពួកគេ ហើយត្រូវបានគេប្រព្រឹត្តអំពើអាក្រក់លើពួកគេ នៅក្នុងប្រទេសដទៃ។
- យេរេមា ៩:១៣-១៦, អេសេគាល ២០:២៣-២៤, ៣៦:១៩-២១ - សាសន៍អ៊ីស្រាអែល នឹងត្រូវខ្ចាត់ខ្ចាយ ក្នុងចំណោមប្រជាជាតិនានា។

- ចោទិយកថា ៣០: ៣-៥, អេសាយ ៤៣: ៥-៦, ៤៩: ១ 1-2២៣, យេរេមា ១៦: ១៤-១៥, អេសេគាល ២៨:២៥-២៦, ៣៤:១៣, អេសេគាល ៣៧:១០-១៤, ២១-២២, អេម៉ុស ៩:១៤-១៥, យ៉ូអែល ៣:៦, ២០ - អ៊ីស្រាអែលនឹងវិលត្រឡប់ទៅស្រុកកំណើតវិញ ហើយត្រូវបានស្តារជាប្រទេសមួយឡើងវិញ។

**បទទំនាយបានបន្តបំពេញសម្រេច បន្ទាប់ពីការសរសេរព្រះគម្ពីរ ត្រូវបានបញ្ចប់ ហើយក៏កំពុងបន្តបំពេញ រហូតដល់ថ្ងៃនេះ!**

ទាល់តែជាព្រះហស្ត អធិធម្មជាតិ និងឆ្លាតវៃបំផុត ទើបអាចគ្រប់គ្រងព្រឹត្តិការណ៍ពិភពលោកទាំងអស់បាន ដើម្បីនាំមកនូវដំណើររឿងជាលំដាប់ នៃព្រឹត្តិការណ៍បែបនេះ។

ខាងក្រោមនេះគឺជាសេចក្តីសង្ខេបនៃព្រឹត្តិការណ៍ទាំងនេះ៖

ឆ្នាំ ១៨៥០ មុនគ.ស. - យ៉ូសែបបាននាំញាតិសន្តានទាំងអស់របស់គាត់ ទៅរស់នៅក្នុងស្រុកអេស៊ីព្ទ (កូនចៅទាំងអស់របស់ អ័ប្រាហាំ) ។ (សូមអាន ផ្នែកអំពី យ៉ូសែប ក្នុងសៀវភៅក្បួនតម្រានេះ)។

ឆ្នាំ ១១០០ មុនគ.ស. - លោកម៉ូសេបានដឹកនាំកូនចៅអ៊ីស្រាអែល ជាងមួយលាននាក់ ចេញពីស្រុកអេស៊ីព្ទហើយត្រឡប់ទៅស្រុកកាណានវិញ។ (សូមអានវគ្គនៅលើម៉ូសេក្នុងក្បួនតម្រានេះ។ )

ឆ្នាំ ៧២២ មុនគ.ស. - អាសស៊ើរបានវាយដណ្តើមយកទឹកដីអ៊ីស្រាអែលខាងជើង និងបាននិរទេសមនុស្សជាច្រើន - ពង្សាវតារក្សត្រទី២ ១៧។

ឆ្នាំ ៥៨៦ មុនគ.ស. - បាប៊ីឡូនបានកាន់កាប់ទឹកដីអ៊ីស្រាអែលភាគខាងត្បូង (យូដា) និងចាប់ប្រជាជនទៅជាឈ្លើយ - ពង្សាវតារក្សត្រទី២ ២៥ ២ របាក្សត្រ ៣៦: ២០-២១

ឆ្នាំ ៥៣៨ មុនគ.ស. - ពើរស៊ី (ដែលបានផ្តួលរំលំបាប៊ីឡូន) បានអនុញ្ញាតឲ្យពួកយូដា វិលត្រឡប់ទៅស្រុកកំណើតវិញ។

ឆ្នាំ ៦៦ - ៧០ គ.ស. - “ការបះបោរដ៏ធំ នៅឆ្នាំ ៦៦ គ.ស. ប្រឆាំងនឹងរ៉ូម និងការឡោមព័ទ្ធ ទីក្រុងយេរូសាឡិម គឺជាព្រឹត្តិការណ៍ដ៏សំខាន់ និងគួរឲ្យរន្ធត់បំផុតមួយ នៅក្នុងប្រវត្តិសាស្ត្រសាសន៍ជ្វីហ្វ (យូដា)”។ (ប៉ូលចនសុន, <u>ប្រវត្តិសាស្ត្រនៃសាសន៍យូដា</u>, ហាភើ ភេរេនាល, ញូវយ៉ក, ១៩៨៨ ។ បោះពុម្ព, ទំព័រ ១៣៧) “ប្រជាជនត្រូវបានលក់ឲ្យធ្វើជាទាសករ ឬប្រហារជីវិត ឬក៏ទុកដើម្បីសម្លាប់នៅលើវេទិកាក្រុងសេសារា អាន់ទីយ៉ូក និងទីក្រុងរ៉ូម”។ (ចនសុន, អ៊ីប៊ែត, ទំព័រ ១៣៩) តាគិសបានសរសេរថា សាសន៍យូដា ១,១៩៧,០០០ នាក់ត្រូវបានសម្លាប់ ឬលក់ជាទាសករ ពីឆ្នាំ ៦៦-៧០ នៃគ.ស. (ចនសុន អ៊ីប៊ែត ទំព័រ ១៤៨) យេរូសាឡិមត្រូវបានបំផ្លាញ ដោយពួករ៉ូម៉ាំង។ ព្រះវិហារត្រូវបានបំផ្លាញ ហើយជញ្ជាំង ត្រូវបានផ្តួលរំលំ ទៅជាកម្ទេចថ្ម។ (ចនសុន, អ៊ីប៊ែត, ទំព័រ ១៤០) ទីប្រជុំជន ភូមិ ៩៨៥ និងទីលំនៅរបស់សាសន៍ជ្វីហ្វត្រូវបានបំផ្លាញ។ ស្រុកយូ

ដាស្ទើរតែទាំងមូលត្រូវគេបំផ្លាញ។ (ចនសុន ទំព័រ ១៤២) ពួករ៉ូម៉ាំងបានបំផ្លាញក្រុងយេរូសាឡិម និងក្រុង ហើយភូមិជុំវិញទាំងស្រុង ដូច្នេះរដ្ឋជ្វីហ្វ បានបញ្ចប់នៅឆ្នាំ ១៣៥ គ.ស. (ចនសុន, អ៊ីប៊ិត, ទំព័រ ១៤២ បានដកស្រង់ពីកាស៊ីស ឌីអូ ប្រវត្តិសាស្ត្ររ៉ូម៉ាំង សៀវភៅ ៦៩) សាសន៍ជ្វីហ្វ ដែលត្រូវបានគេចាប់ធ្វើជាទាសករ ត្រូវបានខ្ចាត់ខ្ចាយពាសពេញពិភពលោក ប៉ុន្តែពួកគេបានរក្សាអត្តសញ្ញាណសាសន៍របស់ពួកគេ។

ឆ្នាំ ១៩៤៨ គ.ស. - អង្គការសហប្រជាជាតិ បានប្រគល់ទឹកដីកាណាន (ប៉ាឡេស្ទីន) ដល់អ៊ីស្រាអែល ហើយសាសន៍យូដាជាច្រើនត្រូវបានជួយ ឲ្យវិលត្រឡប់ទៅស្រុកកំណើតវិញ។ នៅថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ១៩៤៨ អ៊ីស្រាអែលត្រូវបានអង្គការសហប្រជាជាតិទទួលស្គាល់ថា ជារដ្ឋឯករាជ្យមួយ។ នៅថ្ងៃដដែលនោះ កងទ័ពអេស៊ីព្ទ លីបង់ ស៊ីរី និងអ៊ីរ៉ាក់ បានវាយប្រហារ ដើម្បីបំផ្លាញប្រជាជាតិថ្មីនេះ។ ពិភពលោកទាំងមូលគិតថា អ៊ីស្រាអែលគ្មានឱកាសរស់រាន ពីភាពចលាចលបែបនេះទេ។ អ៊ីស្រាអែលមិនបានបង្កើតរដ្ឋាភិបាលរបស់ខ្លួនទេ នៅពេលដែលប្រទេសទាំងបួនវាយប្រហារ ហើយប្រជាជាតិនីមួយៗ ធំជាងប្រទេសអ៊ីស្រាអែលឆ្ងាយណាស់។ ៩ ខែ ក្រោយមក ក្នុងខែកុម្ភៈ ឆ្នាំ ១៩៤៩ អេស៊ីព្ទបានចុះហត្ថលេខា លើសន្ធិសញ្ញាសន្តិភាព ជាមួយអ៊ីស្រាអែល បន្ទាប់ពីនោះ លីបង់ និងស៊ីរី ក៏បានចុះហត្ថលេខាលើសន្ធិសញ្ញា។ អ៊ីរ៉ាក់ គ្រាន់តែដកទ័ពចេញ។ (historylearningsite.co.uk, អ៊ីស្រាអែល និងសង្គ្រាម ឆ្នាំ ១៩៤៨ ។ )

ឆ្នាំ ១៩៦៧ - នៅឆ្នាំ ១៩៦៧ លោក ណាសស៊ើរ ប្រធានាធិបតី អេស៊ីព្ទ បានប្រកាសតាមវិទ្យុសាធារណៈថា បណ្ដាប្រទេសអារ៉ាប់ជាប់ព្រំដែនអ៊ីស្រាអែល (អេស៊ីព្ទ ស៊ីរី និងហ្សកដានី) នឹងបំផ្លាញប្រទេសអ៊ីស្រាអែល។ (Phyllis Goldstein, ការស្អប់ខ្ពើមដ៏ងាយស្រួលមួយ: ប្រវត្តិសាស្ត្រ នៃការប្រឆាំងនឹងសាសនា, ការប្រឈមមុខនឹងប្រវត្តិសាស្ត្រ និងមូលនិធិជាតិរបស់យើង, Brookline, រដ្ឋ Massachusetts, ឆ្នាំ ២០១២ បោះពុម្ព ទំព័រ ៣២៩) ភ្លាមៗបន្ទាប់ពីការប្រកាសនេះ នៅខែមិថុនា ឆ្នាំ ១៩៦៧ អេស៊ីព្ទ ស៊ីរី និងហ្សកដានី បានចល័តរថក្រោះ និងទាហាន ទៅព្រំដែនអ៊ីស្រាអែល។ ប៉ុន្តែ មុនពេលពួកគេវាយប្រហារ អ៊ីស្រាអែលបានធ្វើការវាយលុកដ៏គួរឲ្យភ្ញាក់ផ្អើលមួយ។ ក្នុងរយៈពេលប្រាំមួយថ្ងៃ អ៊ីស្រាអែលបានវាយយកឈ្នះកងទ័ពនៃប្រទេសជិតខាងរបស់ខ្លួន ហើយដណ្ដើមយកទឹកដី ពីពួកគេរៀងៗខ្លួន។ គ្មានប្រទេសអារ៉ាប់ណាមួយអាចធ្វើអ្វី ដើម្បីសងសឹកបានឡើយ។ (Goldstein, Ibid , ទំព័រ ៣២៩)

ព្រះបានប្រាប់អ័ប្រាហាំថា ទ្រង់នឹងប្រទានទឹកដីកាណាន ដល់កូនចៅរបស់អ័ប្រាហាំជានិច្ច ទុកជាកម្មសិទ្ធិជារៀងរហូត (លោកុប្បត្តិ ១៧:៧-៨) ។ ហើយទ្រង់ក៏បានព្រមានពួកគេ តាមរយៈលោកម៉ូសេផងដែរថា ប្រសិនបើពួកគេមិនគោរពតាមទ្រង់ទេ នោះទ្រង់នឹងដកពួកគេចេញពីទឹកដី ហើយបំផ្លាញពួកគេជាច្រើនទៀត

(ចោទិយកថា ២៨:១៥-៦៨ ជាពិសេស ខ ៥៨-៦៥) ។ នេះពិតជាអ្វី ដែលត្រូវបានធ្វើម្តងហើយម្តងទៀត នៅក្នុងប្រវត្តិសាស្ត្រ!

មិនមានប្រទេសណាមួយ នៅលើពិភពលោក ទូទាំងប្រវត្តិសាស្ត្រទាំងមូល ត្រូវបានគេលុបបំបាត់ចេញពីប្រទេសរបស់ពួកគេ ហើយបន្ទាប់មក បាននាំត្រឡប់មកវិញ នៅពេលក្រោយ ដើម្បីក្លាយជាប្រទេសមួយ ដែលមានឈ្មោះដូចគ្នាដដែលនោះទេ។ ជាមួយអ៊ីស្រាអែល វាបានកើតឡើងបីដង! ប៉ុន្តែ នេះគឺជាអ្វី ដែលព្រះបានសន្យា និងបានទាយទុកមុន!

**បទទំនាយរបស់ព្រះ អំពីអ៊ីស្រាអែល និងការសម្រេចបទទំនាយទាំងនោះ ផ្តល់ភស្តុតាងច្បាស់លាស់ សម្រាប់អធិបតេយ្យភាពបែបអធិធម្មជាតិ របស់ព្រះ**
**(ទស្សនៈខ្នាតធំ ចំពោះកិច្ចការរបស់ព្រះ)**

ដំណើររឿងតាមលំដាប់ នៃការដកចេញ និងការវិលត្រឡប់របស់ប្រជាជាតិអ៊ីស្រាអែលទាំងមូល ពីស្រុកកំណើតរបស់ពួកគេ គឺមានលក្ខណៈប្លែកពីគេ ក្នុងចំណោមប្រជាជាតិទាំងអស់ ក្នុងប្រវត្តិសាស្ត្រទាំងមូល។ ព្រឹត្តិការណ៍ដែលបានកើតឡើងជាមួយប្រជាជាតិអ៊ីស្រាអែល មិនត្រឹមតែមានដំណាលក្នុងចំណោមប្រជាជាតិនានាប៉ុណ្ណោះទេ ពួកគេក៏ត្រូវបានព្រះថ្លែងទំនាយ និងកត់ត្រានៅក្នុងព្រះគម្ពីរដែរ។ ទាល់តែជាព្រះហស្ត និងភាពវៃឆ្លាត នៃអង្គបុគ្គលដ៏ខ្ពស់ដែលគ្រប់គ្រងព្រឹត្តិការណ៍ពិភពលោកទាំងអស់ ទើបនាំមកនូវដំណើររឿងតាមលំដាប់នៃព្រឹត្តិការណ៍បែបនេះបាន។

ព្រះអង្គទ្រង់ផ្ទាល់ បានមានបន្ទូលថា ទ្រង់បានធ្វើការថ្លែងទំនាយ អំពីប្រជាជាតិអ៊ីស្រាអែល ដើម្បីឲ្យមនុស្សដឹងថា ទ្រង់គ្រប់គ្រងលើហេតុការណ៍ទាំងអស់។ ទ្រង់មានព្រះបន្ទូលថា “ឯការដែលបានកើតឡើងតាំងតែពីដើមមក នោះយើងបានថ្លែងប្រាប់ចាប់តាំងពីបុរាណហើយ សេចក្តីនោះបានចេញពីមាត់យើងទៅ . . . ក្រែងអ្នកនិយាយថា គឺជារូបព្រះរបស់អ្នកដែលធ្វើការនោះវិញ។ . . . អ្នកបានឮហើយ ចូរពិចារណាការទាំងនេះចុះ។ តើអ្នកនឹងមិនព្រមថ្លែងប្រាប់ទេឬ?” អេសាយ ៤៨: ៣-៦

## នាងរស់

សូមអាន នាងរស់ ១-៤

- នាងរស់ មិនមែនជាសាសន៍អ៊ីស្រាអែលទេ។ ទោះបីជានាងមកពីប្រទេសផ្សេងក៏ដោយ ព្រះបានធ្វើការដែលពិសេស នៅក្នុងជីវិតរបស់នាង នៅពេលនាងបានសម្រេចចិត្ត នៅជាមួយប្រជារាស្ត្ររបស់ព្រះ។ (នាងរស់ ១)
- ព្រះចង់ជួយមនុស្ស នៅពេលពួកគេបន្ទាបខ្លួន ហើយស្វែងរកទ្រង់។
- ព្រះអង្គបានបញ្ចូលនាងរស់ ក្នុងផែនការរបស់ទ្រង់ ដើម្បីនាំមកនូវមេស្ស៊ី ដែលនឹងជួយសង្គ្រោះមនុស្សលោកទាំងអស់។ (នាងរស់ ៤: ១៦-២២, ប្រៀបធៀបនឹង បញ្ជីពង្សាវតារ នៃ ម៉ាថាយ ១)

- តើមានរឿងអ្វីខ្លះ ដែលទាក់ទងនឹងផ្លូវ ដែលព្រះបាននាំយើង ជាសាសន៍ដទៃ ឲ្យរៀបការជាមួយព្រះអង្គផ្ទាល់? សូមសរសេរការសង្កេតទាំងនេះ នៅក្នុងផ្នែកនៃក្បួនតម្រានេះ ដែលមានចំណងជើងថា "សេចក្តីសង្គ្រោះរបស់ព្រះ" ។
- តើមានរឿងអ្វីទៀត ដែលអ្នកបានមើល អំពីព្រះ នៅក្នុងរឿងរបស់នាងរស់ និងបូអូស? (សរសេរការសង្កេតរបស់អ្នក នៅក្នុងផ្នែកនៃក្បួនតម្រានេះ ដែលមានចំណងជើងថា "សេចក្តីសង្គ្រោះរបស់ព្រះ" "ព្រះរាជលក្ខណៈរបស់ព្រះ" និង "សេចក្តីសន្យារបស់ព្រះ")

## ដាវីឌ

សូមអាន សាំយូអែលទី១ ជំពូក ១៦ - ៣១
សូមអាន សាំយូអែលទី២ ជំពូក ១ - ២៤
សូមអានពង្សាវតារក្សត្រទី១ ជំពូក ១ - ២

- ដាវីឌជាសាសន៍អ៊ីស្រាអែលម្នាក់ ដែលបានទុកចិត្តលើព្រះ តាំងពីគាត់នៅក្មេង រហូតដល់គាត់ក្លាយជាស្តេចអ៊ីស្រាអែល។
- ដាវីឌបានជឿលើសេចក្តីសន្យារបស់ព្រះ អំពីការនាំកូនចៅអ័ប្រាហាំ ចូលទឹកដី ដូច្នេះគាត់សុខចិត្តប្រយុទ្ធ នឹងមនុស្សមាឌធំ ដែលប្រឆាំងនឹងសាសន៍អ៊ីស្រាអែល ពីការរស់នៅលើទឹកដីនេះ។ (សាំយូអែលទី១ ១៧)
- ស្តេចសូល ច្រណែននឹងភាពជោគជ័យ របស់ដាវីឌ។ ជាលទ្ធផល សូលបានព្យាយាមសម្លាប់ដាវីឌម្តងហើយម្តងទៀត រហូតទាល់តែសូលត្រូវបានសម្លាប់ នៅក្នុងការប្រយុទ្ធ ជាមួយពួកភីលីស្ទីន។ (សាំយូអែលទី១ ១៨-៣១)
- ដាវីឌបានទុកចិត្តព្រះ ពេលកំពុងរត់ចេញពីស្តេចសូល (យ៉ាងហោចណាស់ប្រាំបីឆ្នាំ) ។ ឧទាហរណ៍ដ៏ល្អមួយ គឺព្រឹត្តិការណ៍ នៅក្នុងរូងភ្នំ។ (សាំយូអែលទី១ ២៤:១-២២)
- ដាវីឌបានឡើងសោយរាជ្យ នៅស្រុកអ៊ីស្រាអែល ហើយលើកតម្កើងការថ្វាយបង្គំព្រះ។ (សាំយូអែលទី២ ៥:១-៥)
- ព្រះបានសន្យាថា កូនចៅម្នាក់របស់ដាវីឌ នឹងគ្រប់គ្រងលើអ៊ីស្រាអែលជារៀងរហូត។ ស្តេចនាពេលអនាគតនេះ ត្រូវបានគេហៅថា "ព្រះមេស្ស៊ី" (គឺ "ព្រះគ្រីស្ទ" ជាភាសាក្រិក) ដោយសាសន៍អ៊ីស្រាអែល។ (សាំយូអែលទី២ ៧:១១-១៦)
- អំពើបាបរបស់ដាវីឌ ដែលផិតក្បត់ជាមួយនាងបាតសេបា និងការធ្វើឃាតប្តីរបស់នាង គឺប្រហែលជាកំហុស ដែលគេស្គាល់ច្រើនបំផុត។ (សាំយូអែលទី២ ១១-១២) ដាវីឌបានសរសេរ ទំនុកតម្កើង ៥១ ក្នុងការសារភាពពីអំពើបាបនេះ។
- កូនប្រុសម្នាក់របស់ដាវីឌ គឺអាប់សាឡុម បានដណ្តើមរាជ្យពីបិតារបស់ខ្លួន ជាបណ្តោះអាសន្ន ដែលជាការសាកល្បងដ៏អស្ចារ្យមួយសម្រាប់ដាវីឌ។ (សាំយូអែលទី២ ១៥-១៨)
- ព្រះគម្ពីររួមបញ្ចូលកំណាព្យរបស់ដាវីឌជាច្រើន ដែលគាត់បានសរសេរ ដើម្បីបង្ហាញពីអារម្មណ៍ខុសៗគ្នារបស់គាត់ ចំពោះព្រះ។ សាំយូអែលទី២ ២២ គឺជាឧទាហរណ៍មួយ ហើយទំនុកតម្កើងជាច្រើន ត្រូវបានសរសេរដោយដាវីឌ។

- ព្រះបានប្រទានពរដល់អ៊ីស្រាអែល តាមរបៀបជាច្រើន ពីព្រោះដាវីឌបានដឹកនាំពួកគេ ឲ្យទុកចិត្ត និងស្តាប់បង្គាប់ព្រះ។
- សូមអាន ទំនុកតម្កើង ១៤៥ ដែលសរសេរដោយដាវីឌ។ តើអ្នកសង្កេតឃើញ រឿងអ្វីខ្លះអំពីព្រះ? (សរសេរការសង្កេតរបស់អ្នកនៅក្នុងផ្នែក "មូលដ្ឋានគ្រឹះអំពីព្រះ" - ព្រះរាជលក្ខណៈរបស់ព្រះ។ )
- ធ្វើដូចគ្នានឹង ទំនុកតម្កើង ២៧ ។
- តើមានអ្វីផ្សេងទៀតអំពីព្រះ ដែលរៀបរាប់ដោយដាវីឌ? (សរសេរការសង្កេតរបស់អ្នក នៅក្នុងផ្នែកនៃក្បួនតម្រានេះ ដែលមានចំណងជើងថា "សេចក្តីសង្គ្រោះរបស់ព្រះ" "ព្រះរាជលក្ខណៈរបស់ព្រះ" និង "សេចក្តីសន្យារបស់ព្រះ")

## សាឡូម៉ូន

សូមអាន ពង្សាវតារក្សត្រទី១ ជំពូក ១ - ១១

បុត្រារបស់ដាវីឌ ព្រះនាមសាឡូម៉ូន ដែលជាអ្នកស្នងមរតកដំបូងបង្អស់របស់ដាវីឌ បានទទួលពរពីព្រះ ហើយបាននាំសាសន៍អ៊ីស្រាអែល ទៅដល់កំពូលនៃភាពរុងរឿង។

- សាឡូម៉ូនជាបុត្រារបស់ដាវីឌ និងនាងបាតសេបា ជាស្ត្រីដែលដាវីឌប្រព្រឹត្តអំពើផិតក្បត់ជាមួយ។ ពង្សាវតារក្សត្រទី១ ១:១១-៣៥
- សាឡូម៉ូនមានចំណេះដឹង និងទ្រព្យសម្បត្តិច្រើនជាងគេ ក្នុងប្រវត្តិសាស្ត្រ។ ពង្សាវតារក្សត្រទី១ ១០: ១-២៩
- ការគ្រប់គ្រងរបស់សាឡូម៉ូន គឺជាមហាអំណាចកំពូល សម្រាប់អ៊ីស្រាអែល ក្នុងប្រវត្តិសាស្ត្រ។
- សាឡូម៉ូនមិនបានសហការជាមួយព្រះទេ ដូច្នេះហើយបានជាមានការធ្លាក់ចុះ នៃប្រជាជាតិអ៊ីស្រាអែល។ ពង្សាវតារក្សត្រទី១ ១១: ១-២៦
- នៅចុងបញ្ចប់ នៃជីវិតរបស់សាឡូម៉ូន មានស្តេចពីរអង្គ បានកាន់កាប់ប្រទេសអ៊ីស្រាអែល (យេរ៉ូបោម និងរេហូបោម នៅ ពង្សាវតារក្សត្រទី១ ១១:២៦ - ១២:៣៣) ។ រេហូបោម គ្រប់គ្រងបានតែកុលសម្ព័ន្ធខាងត្បូងទាំងពីរ នៃស្រុកយូដា និងអេប្រាអ៊ីម ដែលរួមបញ្ចូលក្រុងយេរូសាឡិមផង។ ចំណែក យេរ៉ូបោមគ្រប់គ្រងកុលសម្ព័ន្ធទាំងដប់ ដែលជាផ្នែកខាងជើង នៃស្រុកអ៊ីស្រាអែល។ នេះជាការចាប់ផ្តើមនៃភាពច្របូកច្របល់ជាច្រើន សម្រាប់សាសន៍អ៊ីស្រាអែល។ មានស្តេចជាច្រើនគ្រប់គ្រងលើពីរផ្នែក ដែលត្រូវបានគេស្គាល់ថា អ៊ីស្រាអែល (កុលសម្ព័ន្ធខាងជើង) និងយូដា (កុលសម្ព័ន្ធពីរខាងត្បូង រួមទាំងក្រុងយេរូសាឡិម) ។ ការគ្រប់គ្រងគឺបែបនេះ រហូតដល់ពួកសាសន៍អាសស៊ើរបានចាប់យកសាសន៍អ៊ីស្រាអែល ទៅជាឈ្លើយសឹក (ឆ្នាំ ៧២២ មុន គ.ស. ) ហើយ បាប៊ីឡូនបានចាប់យកប្រជាជនយូដា ទៅជាឈ្លើយសឹក (ឆ្នាំ ៥៨៧ មុន គ.ស. ) ។
- តើមានអ្វីផ្សេងទៀតអំពីព្រះ ដែលកត់ទុកក្នុងដំណើររឿងសាឡូម៉ូន? (សរសេរការសង្កេតរបស់អ្នកក្នុងផ្នែក នៃក្បួនតម្រានេះ ដែលមានចំណងជើងថា "សេចក្តីសង្គ្រោះរបស់ព្រះ" "ព្រះរាជលក្ខណៈរបស់ព្រះ" និង "សេចក្តីសន្យារបស់ព្រះ")

## អេសាយ

សូមអាន អេសាយ ១:១-៣១, ៦:១-១៣, ៩:១-៧, ជំពូក ១១, ១២, ២៦, ៤០, ៤២, ៤៩: ១-២៦, ៥៣:១-១២, ជំពូក ៦១, ៦៦:១- ២៤

អេសាយជាសាសន៍អ៊ីស្រាអែលម្នាក់ ដែលរស់នៅក្នុងអំឡុងពេលដែលសាសន៍អ៊ីស្រាអែល ត្រូវបាននិរទេសចេញពីប្រទេសរបស់ពួកគេ ទៅស្រុកអាសស៊ើរ និងបាប៊ីឡូន។ មិនមានអ្វីចែងអំពីជីវិតផ្ទាល់ខ្លួនរបស់គាត់ទេ។

- អេសាយបានថ្លែងទំនាយ នៅក្នុងរជ្ជកាលរបស់ស្ដេចបួនអង្គ នៅស្រុកយូដា (អេសាយ ១:១) ដែលត្រូវជាប្រហែល ឆ្នាំ ៧១០-៨៨១ មុន គ.ស.។
- អេសាយបានទាយអំពីប្រទេសជិតខាងជាច្រើន ដូចជាបាប៊ីឡូន (ជំពូក ១៣-១៤ ភីលីស្ទីន (អេសាយ ១៤: ២៨-៣២) ម៉ូអាប់ (ជំពូក ១៥-១៦) ដាម៉ាស និងស៊ីរី (ជំពូក ១៧)) ប្រទេសអេត្យូពី (អេសាយ ១៨) អេស៊ីព្ទ (ជំពូក ១៩-២០) ។
- ក្នុងនាមជាហោរារបស់ព្រះ អេសាយបានទាយ អំពីការបំផ្លាញ និងការជាប់ជាឈ្លើយ របស់អ៊ីស្រាអែល (ដូចជា បាប៊ីឡូនដណ្ដើមយកទឹកដីយូដា នៅជំពូក ៣៩:១-៨ និងការត្រឡប់មកវិញ របស់សាសន៍អ៊ីស្រាអែល នាពេលអនាគត (ជំពូក ៤៩: ១-២៦ និងជំពូក ៥១) ។
- ព្រះបានប្រាប់អេសាយថា បុត្រាដ៏ពិសេសមួយអង្គ នឹងកើតមក ជាសាសន៍អ៊ីស្រាអែល នាអនាគត។ បុត្រានោះនឹងត្រូវបានគេហៅថា ព្រះដ៏មានព្រះចេស្ដា ព្រះវរបិតាដ៏អស់កល្បជានិច្ច (អេសាយ ៩: ៦) ។ ព្រះកំពុងតែជួយប្រជារាស្ត្ររបស់ព្រះអង្គ ឲ្យយល់ថា ព្រះមេស្ស៊ីនាពេលអនាគត ពិតជាព្រះដែលនឹងត្រូវប្រសូតមកជាមនុស្ស។
- អេសាយបានសរសេរ អំពីការរងទុក្ខរបស់អ្នកបម្រើព្រះ ក្នុងរបៀបមួយ ដែលអាចពិពណ៌នាបានតែការរងទុក្ខ និងការឆ្កាងព្រះយេស៊ូវ នៅពេលអនាគតប៉ុណ្ណោះ។ (អេសាយ ៥៣)
- ព្រះបានបង្ហាញរឿងជាច្រើន ដល់អេសាយ អំពីផែនការរបស់ទ្រង់ សម្រាប់ពេលអនាគត ដើម្បីផ្ដល់ក្ដីសង្ឃឹម ដល់សាសន៍អ៊ីស្រាអែល។
- តើមានអ្វីផ្សេងទៀតអំពីព្រះ ដែលកត់ទុកក្នុងគម្ពីរអេសាយ? (សរសេរការសង្កេតរបស់អ្នក នៅក្នុងផ្នែកនៃក្បួនតម្រានេះ ដែលមានចំណងជើងថា “សេចក្ដីសង្គ្រោះរបស់ព្រះ” “ព្រះរាជលក្ខណៈរបស់ព្រះ” និង “សេចក្ដីសន្យារបស់ព្រះ”)

## ដានីយ៉ែល

ដានីយ៉ែល ជំពូក ១ - ១០

ដានីយ៉ែលគឺជាម្នាក់ ក្នុងចំណោមសាសន៍អ៊ីស្រាអែល ដែលត្រូវបានចាប់ជាឈ្លើយ ដោយពួកបាប៊ីឡូន។ បាប៊ីឡូនគឺជាចក្រភពមួយ ក្នុងចំណោមចក្រភពទាំងឡាយនៅគ្រានោះ។ ពួកបាប៊ីឡូន បានបំផ្លាញក្រុងយេរូសាឡិម ហើយបានចាប់សាសន៍អ៊ីស្រាអែលជាច្រើន យកទៅបាប៊ីឡូន និងចក្រភពរបស់ខ្លួន។

- ដានីយ៉ែល គឺជាឧទាហរណ៍មួយ អំពីមនុស្សម្នាក់ ដែលបន្តទុកចិត្តលើព្រះ ទោះបីកាលៈទេសៈហាក់ដូចជា កិច្ចការរបស់ព្រះ ត្រូវបានបំផ្លាញក៏ដោយ។

- ដានីយ៉ែលត្រូវបានតម្លើងឋានៈ ម្តងហើយម្តងទៀត ដោយសារតែចរិត និងសមត្ថភាពដ៏ឆ្នើមរបស់គាត់។ ដោយមានទំនួលខុសត្រូវទាំងអស់នេះ នៅក្នុងប្រទេសដែលជាសត្រូវ គាត់បានរស់នៅដើម្បីផ្គាប់ព្រះហឫទ័យព្រះ គ្រប់បែបយ៉ាង។ (ដានីយ៉ែល ១ -២)
- ព្រះបានប្រើដានីយ៉ែល ដើម្បីជួយស្តេចនេប៊ូក្នេសា ដែលបានក្លាយជាអ្នកថ្វាយបង្គំព្រះ។ សូមអានរឿងមិនធម្មតានេះ នៅក្នុង ដានីយ៉ែល ២ - ៤ ។
- នៅក្រោមព្រះរាជាដារីយុស ដែលបានផ្តួលរំលំពួកបាប៊ីឡូន មន្ត្រីជាច្រើនបានប្រឆាំងនឹងដានីយ៉ែល ហើយបានព្យាយាមសម្លាប់គាត់ នៅក្នុងរូងតោ ប៉ុន្តែព្រះបានធ្វើការបង្ហាញពីភាពជំឧត្តមរបស់ទ្រង់ចំពោះស្តេចនេះ ដែលបន្ទាប់មកបានប្រកាសពីភាពជំឧត្តមរបស់ព្រះ ដល់ចក្រភពទាំង មូល។ (ដានីយ៉ែល ៦)
- ព្រះបានឲ្យដានីយ៉ែល ឃើញក្នុងគំនិតអំពីព្រឹត្តិការណ៍ពិភពលោកនាពេលអនាគត ដែលលោកបានកត់ទុក។ (ដានីយ៉ែល ៧-៨)
- ព្រះក៏បានបង្ហាញដានីយ៉ែល នូវការជំនុំជម្រះចុងក្រោយ នៃពិភពលោក និងចក្ខុវិស័យនៃ «កូនមនុស្ស» ដែលកំពុងមកផែនដី ហើយនឹងត្រូវបានថ្វាយបង្គំ ទុកជាអង្គដែលមានសិទ្ធិអំណាចខ្ពស់បំផុតជាមួយនឹង «ព្រះដ៏មានព្រះជន្មពីចាស់បុរាណ» ដែលជាងាររបស់ព្រះ។ (ដានីយ៉ែល ៧:៩-១៤) សាសន៍យូដាទាំងអស់ចាត់ទុកការនេះ ជាបទទំនាយអំពីមេស្ស៊ីរបស់ពួកគេ ដែលព្រះយេស៊ូវបានអះអាង ក្រោយមកថា គឺជាអង្គទ្រង់ (ម៉ាកុស ១៤:៦២) ។
- ក្នុងដំណើររឿងរបស់ដានីយ៉ែល តើអ្នកសង្កេតឃើញមានរឿងអ្វីទៀត? (សរសេរការសង្កេតរបស់អ្នកនៅក្នុងផ្នែកនៃក្បួនតម្រានេះ ដែលមានចំណងជើងថា "សេចក្តីសង្គ្រោះរបស់ព្រះ" "ព្រះរាជលក្ខណៈរបស់ព្រះ" និង "សេចក្តីសន្យារបស់ព្រះ")។

## ព្រះយេស៊ូវ

សូមអាន លូកា ជំពូក ១ ដល់ ២៤

សូមអាន យ៉ូហាន ជំពូក ១ - ២១

ព្រះយេស៊ូវគ្រីស្ទ គឺជារបត់ចម្បង នៃប្រវត្តិសាស្ត្រទាំងមូល។ សូម្បីតែប្រព័ន្ធកំណត់កាលបរិច្ឆេទ នៃពិភពលោកបច្ចុប្បន្ន ក៏ផ្អែកលើថ្ងៃកំណើតរបស់ព្រះយេស៊ូវ។ ព្រះយេស៊ូវ ក៏ជារបត់នៃរបៀបដែលព្រះបានធ្វើការជាមួយមនុស្សដែរ។ នៅក្នុងសារសំខាន់ទីមួយ ដែលព្រះយេស៊ូវបានថ្លែង (សេចក្តីអធិប្បាយនៅលើភ្នំ) ព្រះយេស៊ូវបានមានបន្ទូល ជាញឹកញាប់ថា "អ្នករាល់គ្ាបានឮចមកហើយ...ប៉ុន្តែ ខ្ញុំប្រាប់អ្នករាល់គ្នាថា . . " (ម៉ាថាយ ៥:២១, ២៧, ៣១, ៣៣, ៣៨, ៤៣)។ ការសង្កត់ធ្ងន់ ទៅលើអ្វីដែលកំពុងកើតឡើង នៅក្នុងចិត្តរបស់មនុស្ស ដែលព្រះគម្ពីរសញ្ញាចាស់បានសង្កត់ធ្ងន់ទៅលើ សកម្មភាពរបស់មនុស្ស។ មានមូលហេតុ បួនយ៉ាង ដែលយើងដឹងថា ព្រះយេស៊ូវគ្រីស្ទពិតជាព្រះ បង្កើតពិភពលោក។ ប្រការទាំងអស់នេះមានឯកសារប្រវត្តិសាស្ត្រល្អបំផុត ដែលអាចធ្វើទៅបាននៅពេលនោះ។

- ទ្រង់បានបំពេញបទទំនាយ ដែលបានទាយអំពីទ្រង់ (ព្រះមេស្ស៊ី នៃសាសន៍យូដា) រាប់រយ រាប់ពាន់ឆ្នាំមុន ព្រះជន្មរបស់ទ្រង់នៅលើផែនដី។
- ទ្រង់បានអះអាងថា ទ្រង់ជាព្រះ នៅចំពោះសត្រូវរបស់ទ្រង់ និងអ្នកដែលដើរតាមទ្រង់។

- ទ្រង់បានបង្ហាញ នូវតេជានុភាពអធិធម្មជាតិ របស់ព្រះ។
- អ្នកដើរតាមទ្រង់ បានចំណាយជីវិតរបស់ពួកគេ ដើម្បីប្រកាសថា ទ្រង់គឺជាព្រះ ហើយពួកគេស្ម័គ្រចិត្តស្លាប់ ព្រោះពួកគេមិនអាចបដិសេធ អំពីការដែលពួកគេបានឃើញ និងប៉ះព្រះយេស៊ូវ នៅក្នុងរូបអង្គដែលបានរស់ឡើងវិញរបស់ទ្រង់ បន្ទាប់ពីទ្រង់ត្រូវបានគេធ្វើគុត ដូចអ្វីដែលទ្រង់បានទាយប្រាប់ពួកគេនោះទេ។

សម្គាល់: ព្រះជន្មគង់នៅរបស់ព្រះយេស៊ូវ ត្រូវបានបង្ហាញយ៉ាងច្បាស់ (ត្រូវនឹងដំណើររឿងព្រះគម្ពីរ) នៅក្នុងខ្សែភាពយន្តរឿង “ព្រះយេស៊ូវ”។ ខ្សែភាពយន្ត នៃដំណើរព្រះជន្មរបស់ទ្រង់ អាចត្រូវបានគេមើលតាម អ៊ិនធើរណេតជាច្រើនរយភាសា នៅគេហទំព័រនេះ៖ www.JesusFilmMedia.org អត្ថបទដកស្រង់ចេញពីគម្ពីរលូកា ហើយត្រឹមត្រូវណាស់។ ការនោះក៏រំឭកពីការបង្កើតការ ធ្លាក់ចុះ អ័ប្រាហាំ ព្រះជន្មរបស់ព្រះយេស៊ូវ ដំណឹងល្អ និងការជឿទុកចិត្ត លើព្រះយេស៊ូវ ដើម្បីទទួលបានសេចក្តីសង្គ្រោះ។ ខាងក្រោមនេះ ជាសង្ខេបខ្លីខ្លះៗ នៃព្រះជន្មរបស់ព្រះយេស៊ូវ នៅលើផែនដី។

- ព្រះយេស៊ូវបានប្រសូតមក ជាពូជរបស់អ័ប្រាហាំ អ៊ីស្រាអែល និងដាវីឌ (ម៉ាថាយ ១: ១-១៧) ដែលជាការសម្រេច នៃបទទំនាយជាច្រើន។
- ទីតាំងកំណើតរបស់ព្រះយេស៊ូវ គឺជាការបំពេញតាមបទទំនាយ។ (មីកា ៥: ២, ម៉ាថាយ ២: ១, លូកា ២: ១-៧)
- ព្រឹត្តិការណ៍ នៃកំណើតព្រះយេស៊ូវ គឺជាការអស្ចារ្យ។ (ម៉ាថាយ ១-២, លូកា ១:២៦ - ២:៤០)
- ព្រះយេស៊ូវមានឥទ្ធិពលយ៉ាងខ្លាំង លើវប្បធម៌អឺរ៉ុប និងលោកខាងលិច ដែលប្រព័ន្ធប្រតិទិន ប្រើប្រាស់នៅជុំវិញពិភពលោកសព្វថ្ងៃ គឺផ្អែកលើកាលបរិច្ឆេទ នៃកំណើតរបស់ទ្រង់។
- ព្រះយេស៊ូវបានជ្រាបថា ទ្រង់គឺជាព្រះ ដែលបានយាងមកជាមនុស្ស ទោះបីទ្រង់ទើបតែមានព្រះជន្ម ១២ ឆ្នាំ ក៏ដោយ។ (លូកា ២:៤១-៥២)
- ព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹក ដោយលោកយ៉ូហានបាទីស្ទ។ (ម៉ាថាយ ៣:១៣-១៧)
- ព្រះយេស៊ូវមានព្រះជន្មគង់នៅក្នុងភាពក្រីក្រទាំងស្រុង ដោយគ្មានផ្ទះសម្បែង ប៉ុន្តែព្រះអង្គនៅតែជួយអ្នកដទៃ។ (ទាំងអស់ តាមរយៈ ម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន)
- ការអស្ចារ្យជាច្រើនរបស់ទ្រង់ ដូចជាការព្យាបាល និងគ្រប់គ្រងធម្មជាតិ គឺជាភស្តុតាងដែលបញ្ជាក់ថាទ្រង់ជាព្រះដែលមានសណ្ឋានជាមនុស្ស។ (ទាំងអស់តាមរយៈ ម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន) គឺជាការគួរឲ្យចាប់អារម្មណ៍ក្នុងការកត់សម្គាល់ ការអស្ចារ្យទាំងអស់របស់ទ្រង់ គឺសម្រាប់គោលបំណងជួយមនុស្ស តាមមធ្យោបាយផ្សេងៗ។ ទ្រង់មិនមិនគ្រាន់តែបានសម្តែងការអស្ចារ្យ ដល់ពួកគេ ដើម្បីបង្ហាញពីអំណាចរបស់ទ្រង់ប៉ុណ្ណោះ។
- ព្រះយេស៊ូវផ្ទាល់បានអះអាងថា ទ្រង់ជាព្រះ។ (យ៉ូហាន ៨: ៥៧-៥៩ និងយ៉ូហាន ១០: ៣០-៣៣, ៣៧-៣៩) នេះជាមូលហេតុដែលអ្នកដឹកនាំសាសនា បាននិយាយថា ទ្រង់ត្រូវតែស្លាប់ ពីព្រោះទ្រង់បានអះអាងថា ទ្រង់ជាព្រះ និងជាព្រះមេស្ស៊ី (យ៉ូហាន ១៩: ៧) ប៉ុន្តែ ទ្រង់មិនបានផ្តួលរំលំ រដ្ឋាភិបាល ដូចដែលមនុស្សជាច្រើន គិតថាព្រះមេស្ស៊ីគួរតែធ្វើមុនគេនោះទេ។

- ព្រះយេស៊ូវបានបង្រៀនយ៉ាងច្បាស់ អំពីព្រះត្រៃឯក ទោះបីជាទ្រង់មិនដែលប្រើពាក្យនោះក៏ដោយ។ ជាច្រើនដង ដែលទ្រង់បានមានបន្ទូល អំពីព្រះវរបិតារបស់ទ្រង់ ហើយនៅបុណ្យរំលងចុងក្រោយ ទ្រង់បានពន្យល់យ៉ាងច្បាស់ អំពីព្រះវិញ្ញាណបរិសុទ្ធ ដែលនឹងមកជំនួសព្រះយេស៊ូវ។ (យ៉ូហាន ១៤ និងយ៉ូហាន ១៦) គឺច្បាស់ណាស់ថា ព្រះយេស៊ូវបានទទួលស្គាល់ព្រះវរបិតារបស់ទ្រង់ដែលគង់នៅស្ថានសួគ៌ ថាជាព្រះ រួចព្រះយេស៊ូវបានមានបន្ទូលថា ទ្រង់ផ្ទាល់គឺជាព្រះ ហើយព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះ។
- ព្រះយេស៊ូវបានបង្រៀនយ៉ាងច្បាស់ ពីសត្រូវធំបំផុតរបស់យើង គឺសាតាំង (យ៉ូហាន ៨:៤២-៤៦) ។
- ព្រះយេស៊ូវក៏បានបង្រៀន អំពីការជំនុំជម្រះអស់កល្បជានិច្ច (ម៉ាថាយ ២៥: ៣១-៤៦ យ៉ូហាន ៣: ១៦-១៨) ។
- ព្រះយេស៊ូវបានជ្រាបថា គោលបំណងសំខាន់នៃព្រះជន្មរបស់ទ្រង់ គឺដើម្បីសងថ្លៃលោះ ជំនួសមនុស្សជាច្រើន (ម៉ាកុស ១០:៤៥) ដើម្បីជួយសង្គ្រោះពួកគេ ពីការជំនុំជម្រះដ៏អស់កល្ប ចំពោះអំពើបាបរបស់គេ។
- ព្រះយេស៊ូវយល់ថា ទ្រង់ជាចំណុចសំខាន់បំផុត នៃប្រវត្តិសាស្ត្រតាំងពីលោកម៉ូសេ រហូតដល់ វិវរណៈ។ ទ្រង់បានប្រាប់អ្នកដើរតាមទ្រង់ថា ការសុគតរបស់ទ្រង់ គឺជាការបំពេញសម្រេចអត្ថន័យ អំពីកូនចៀមបុណ្យរំលង (យញ្ញបូជា ដើម្បីជួយសង្គ្រោះជីវិតកូនច្បង) ។ (ម៉ាកុស ១៤: ១២-២៥, លូកា ២២: ១៤-២០) ទ្រង់ក៏បានមានបន្ទូលផងដែរថា ការសម្រេចពេញលេញ នឹងកើតឡើងនៅក្នុងនគរព្រះ (លូកា ២២:១៦) ។ នៅក្នុងវិវរណៈ ព្រះយេស៊ូវត្រូវបានគេសំដៅជាញឹកញាប់ថា ជាកូនចៀម ពីព្រោះគឺការសុគតរបស់ព្រះអង្គ ដែលមនុស្សគ្រប់រូប អាចត្រូវបានសង្គ្រោះ រួចពីសេចក្តីស្លាប់អស់កល្បជានិច្ច ទៅកាន់ជីវិតអស់កល្ប។ (វិវរណៈ ៧: ៩-១៧) នេះជាមូលហេតុ ដែលព្រះយេស៊ូវបានមានបន្ទូលប្រាប់អ្នកដើរតាមទ្រង់ ឲ្យចែកនំបុ័ង និងទឹកទំពាំងបាយជូរជាមួយគ្នា ដើម្បីជាការចងចាំពីការលះបង់របស់ទ្រង់ សងថ្លៃលោះអំពើបាបរបស់យើង (លូកា ២២:១៩) ។
- ព្រះយេស៊ូវបានទាយជាច្រើនដងថា ទ្រង់នឹងត្រូវគេធ្វើគុត ហើយបីថ្ងៃក្រោយ ទ្រង់នឹងរស់ឡើងវិញ (លូកា ១៨:៣៣) ។ សូម្បីតែសត្រូវរបស់ទ្រង់ ក៏យល់ពីរឿងនេះដែរ (ម៉ាថាយ ២៧: ៦២-៦៦) ។ ពួកសិស្សរបស់ទ្រង់ បានរំពឹងថា ព្រះយេស៊ូវនឹងរៀបចំនគររបស់ទ្រង់ភ្លាមៗ ដូច្នេះពួកគេមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលដែលទ្រង់ត្រូវគេធ្វើគុត នៅលើឈើឆ្កាង ហើយពួកគេមិនរំពឹងថា ទ្រង់នឹងរស់ឡើងវិញទេ (យ៉ូហាន ២០:៩) ។
- ការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាភស្តុតាងដ៏រឹងមាំបំផុត សម្រាប់ការអះអាងរបស់ទ្រង់ថាជាព្រះ។ (កូរិនថូសទី១ ១៥:១-៨)
- ព្រះយេស៊ូវបានលេចមក ឲ្យមនុស្សឃើញ ក្នុងរយៈពេល ៤០ ថ្ងៃ បន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់។ បន្ទាប់មក នៅពេលក្រុមមួកំពុងមើលព្រះយេស៊ូវបានឡើងទៅលើមេឃ។ ពួកទេវតាបានប្រាប់ពួកសិស្សថា ព្រះយេស៊ូវនឹងវិលត្រឡប់មកផែនដីវិញ ជារូបរាងកាយដដែល។ (កិច្ចការ ១: ១-១១)
- ពីមុន ព្រះយេស៊ូវបានមានបន្ទូលប្រាប់អ្នកដើរតាមទ្រង់ថា ទ្រង់នឹងវិលត្រឡប់មកធ្វើជាស្តេចវិញ ប៉ុន្តែគ្មានអ្នកណាដឹងកាលបរិច្ឆេទនោះទេ។ (ម៉ាថាយ ២៤:១-៥៤)

- ក្នុងដំណើររឿង នៃព្រះជន្មរបស់ព្រះយេស៊ូវ តើអ្នកសង្កេតឃើញអ្វីខ្លះអំពីព្រះ? (សរសេរការសង្កេតរបស់អ្នក នៅក្នុងផ្នែកនៃក្បួនតម្រានេះ ដែលមានចំណងជើងថា "សេចក្តីសង្គ្រោះរបស់ព្រះ""ព្រះរាជលក្ខណៈរបស់ព្រះ" និង "សេចក្តីសន្យារបស់ព្រះ")
- ចំណាំៈ សូមអាន "ទិដ្ឋភាពទូទៅ (ខ្នាតធំ) របស់ ព្រះយេស៊ូវគ្រីស្ទ" ដែលអ្នកនឹងឃើញ នៅពេលក្រោយក្នុងផ្នែកនេះ។ នោះនាំមកនូវអ្វីៗជាច្រើន ដែលព្រះបានធ្វើ ក្នុងប្រវត្តិសាស្ត្រ ពីអតីតកាល និងអ្វីៗដែលទ្រង់នឹងធ្វើ នាពេលអនាគត ដើម្បីបង្ហាញថា ទ្រង់កំពុងគ្រប់គ្រងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដើម្បីបង្ហាញពីភាពអស្ចារ្យ នៃព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ។

## វិញ្ញាណបរិសុទ្ធ

សូមអាន កិច្ចការ ១:៤-១១, ២:១ - ៤១, ១០:១-៤៨, ១៩: ១-៧

ព្រះវិញ្ញាណបរិសុទ្ធ ត្រូវបានរៀបរាប់ នៅដើមព្រះគម្ពីរ ក្នុង លោកុប្បត្តិ ១: ២ ។ នៅក្នុងព្រះគម្ពីរ ទ្រង់មិនត្រូវបានលើកឡើង ជាញឹកញាប់ ដូចព្រះជាព្រះវរបិតាទេ។ ទ្រង់ក៏មិនត្រូវបានលើកឡើងជាញឹកញាប់ ដូចព្រះជាព្រះរាជបុត្រា (ព្រះយេស៊ូវគ្រីស្ទ) ដែរ ។ ប៉ុន្តែ ព្រះគម្ពីរបានបង្ហាញយ៉ាងច្បាស់ថា ទ្រង់គឺជាព្រះ ជាព្រះវិញ្ញាណបរិសុទ្ធ។ នេះជាអត្ថបទគម្ពីរខ្លះ ដែលជួយឲ្យយើងយល់ថា ព្រះវិញ្ញាណបរិសុទ្ធ ជានរណា ៖

- រ៉ូម ៨: ៩-១១ - ចែងអំពីព្រះ ព្រះគ្រីស្ទ និងព្រះវិញ្ញាណ ថាជាព្រះដូចគ្នា ប៉ុន្តែការធ្វើការ ជាអង្គដោយឡែកផ្សេងៗគ្នា។ នេះពិបាកយល់ ជាមួយគំនិតដែលមានកំណត់របស់យើង។ ទ្រង់ទាំងបីនាក់គឺមានលក្ខណៈដូចគ្នាតែពួកគេមានមុខងារដូចមនុស្សផ្សេងគ្នា។
- យ៉ូហាន ១៤:១៥-១៧, ២៥-២៦ និងយ៉ូហាន ១៦:៥-១៥ - ព្រះយេស៊ូវមានបន្ទូលប្រាប់ពួកសិស្សរបស់ទ្រង់ថា ព្រះទ្រង់នឹងចាត់ព្រះវិញ្ញាណបរិសុទ្ធ ឲ្យមកជំនួសព្រះយេស៊ូវ នៅក្នុងជីវិតរបស់ពួកគេ។ នៅក្នុងអត្ថបទទាំងនេះ ព្រះយេស៊ូវពន្យល់ពីអ្វីដែលព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើ។
- កិច្ចការ ១: ៨ - ព្រះយេស៊ូវបានសន្យាថា នឹងចាត់ព្រះវិញ្ញាណ ដើម្បីជួយសិស្សរបស់ទ្រង់ ឲ្យធ្វើជាស្មរបន្ទាល់ពីទ្រង់។
- កូរិនថូសទី១ ៣:១៦, ៦:១៩, និងអេភេសូរ ១:១៣-១៥ - ព្រះវិញ្ញាណបរិសុទ្ធបានមក គង់នៅក្នុងមនុស្សដែលទុកចិត្តលើព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះ។
- កូរិនថូសទី១ ១២:១-៣១, កាឡាទី ៥: ១៦-១៨, ២២-២៣, ទីតុស ៣: ៥ - ព្រះវិញ្ញាណបរិសុទ្ធប្រទានអំណោយទានផ្សេងៗគ្នា ដល់អ្នកជឿ ហើយជួយពួកគេឲ្យរីកចម្រើន។

ដូចដែលយើងបានអាន នៅក្នុងយ៉ូហាន ១៤:១៧ និង ១៦:៥-៨ ព្រះវិញ្ញាណបរិសុទ្ធមិនបានគង់សណ្ឋិតនៅក្នុងមនុស្ស នៅពេលណាមួយឡើយ រហូតដល់បន្ទាប់ពីព្រះយេស៊ូវបានសុគតបានរស់ឡើងវិញ និងបន្ទាប់ពីទ្រង់បានយាងឡើងទៅស្ថានសួគ៌។ នៅក្នុងគម្ពីរ កិច្ចការ យើងអានដំណើររឿងផ្សេងគ្នា អំពីរបៀបដែលព្រះវិញ្ញាណបរិសុទ្ធ បានមកគង់នៅជាមនុស្សជារៀងរហូត។ សព្វថ្ងៃនេះ ទ្រង់មកសណ្ឋិតនៅក្នុងមនុស្សភ្លាមៗ នៅពេលពួកគេបើកដួងចិត្តរបស់ពួកគេ ទៅកាន់ព្រះគ្រីស្ទ។ គម្ពីរ កិច្ចការ កត់ត្រាព្រឹត្តិការណ៍ផ្សេងៗគ្នា ដែលព្រះបានប្រើដើម្បីបង្រៀនពួកកូនព្រះ អំពីតួនាទីថ្មី នៃព្រះវិញ្ញាណរបស់ទ្រង់។ តួនាទីនៃព្រះវិញ្ញាណបរិសុទ្ធបានផ្លាស់ប្តូរយ៉ាងខ្លាំង ពីរាប់ពាន់ឆ្នាំមុនពេលព្រះយេស៊ូវ នៅពេលដែលទ្រង់នៅជាមួយអ្នកជឿ រហូតដល់

ពេលដែលទ្រង់បានចាប់ផ្តើមរស់នៅក្នុងអ្នកជឿ បន្ទាប់ពីព្រះយេស៊ូវបានឡើងទៅស្ថានសួគ៌វិញ។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបខ្លីៗ នៃអ្វីដែលបានកើតឡើង។

- ព្រះវិញ្ញាណនៃព្រះ បានមករស់នៅក្នុងអ្នក ដែលជឿលើព្រះយេស៊ូវគ្រីស្ទ ជាដំបូង គឺ ១០ ថ្ងៃ បន្ទាប់ពីព្រះយេស៊ូវបានឡើងទៅស្ថានសួគ៌វិញ (កិច្ចការ ១ - ២)។ ហេតុការណ៍នេះ បានកើតឡើង នៅពេលបុណ្យ ថ្ងៃទី ៥០ ដែលជាបុណ្យរបស់សាសន៍យូដា។ នេះគឺ ៥០ ថ្ងៃ បន្ទាប់ពីបុណ្យ ផលដំបូង (នៅថ្ងៃតែមួយ ដែលព្រះយេស៊ូវ បានរស់ពីសុគតឡើងវិញ) ។
- ភស្តុតាងដំបូងមួយ នៃព្រះវិញ្ញាណ ដែលមករស់នៅក្នុងអ្នកជឿ គឺជាសមត្ថភាពនិយាយភាសា ដែលពួកគេមិនបានរៀន (កិច្ចការ ២:១-១៣) ។ នេះពិតជាគួរឲ្យចាប់អារម្មណ៍ ចំពោះអ្នកដែលនៅជុំវិញដែលនិយាយភាសាទាំងនោះ ដោយដឹងថា សិស្សដំបូងមិនដែលរៀនភាសាផ្សេងៗទាំងនោះទេ។ នៅថ្ងៃដដែលនោះ មានសាសន៍យូដាប្រមាណ ៣០០០ នាក់ មកពីប្រទេសជាច្រើន ដែលបានជឿលើព្រះគ្រីស្ទ និងទទួលបានព្រះវិញ្ញាណបរិសុទ្ធ (កិច្ចការ ២:៥, ៤១)។ ដូចដែលយើងបានដឹងហើយថាមិនមានជនបរទេសណាដែលជឿលើព្រះគ្រីស្ទក្នុងឱកាសនេះទេ។
- មិនយូរប៉ុន្មានប្រជាជននៅស្រុកសាម៉ារី (សាសន៍យូដាពាក់កណ្តាល និងសាសន៍ដទៃពាក់កណ្តាល) បានជឿលើព្រះគ្រីស្ទ។ សូមអាន កិច្ចការ ៨: ១៤-១៧ ។ ពេត្រុសនិងយ៉ូហានត្រូវបានបញ្ជូនទៅពួកគេហើយបន្ទាប់ពីពួកគេបានអធិស្ឋានសម្រាប់អ្នកជឿសាសន៍សាម៉ារី នោះសាសន៍សាម៉ារីក៏បានទទួលព្រះវិញ្ញាណបរិសុទ្ធដែរ។
- ជំហានបន្ទាប់គឺឲ្យព្រះវិញ្ញាណបរិសុទ្ធមករស់នៅក្នុងសាសន៍ដទៃ (មនុស្សដែលមិនមែនជាសាសន៍យូដា) ។ រឿងនេះបានកើតឡើងជាលើកដំបូងជាមួយពេត្រុសនិងកូនេលាសនៅក្នុងកិច្ចការ ១០ នៅពេលដែលសាសន៍ដទៃទាំងនេះជឿលើព្រះគ្រីស្ទ ពួកគេមានបទពិសោធន៍ដូចគ្នានឹងពួកសិស្សដំបូងដែលមានបទពិសោធន៍នៅបុណ្យថ្ងៃទី ៥០ ដែលមានន័យថា ពួកគេក៏និយាយភាសាដែលពួកគេមិនបានរៀន (កិច្ចការ ១០: ៤៤-៤៨) ។
- មនុស្សចុងក្រោយ ដែលបានទទួលព្រះវិញ្ញាណបរិសុទ្ធ គឺជាមនុស្សមួយចំនួនដែលជឿលើព្រះបន្ទូលរបស់ព្រះ តាមរយៈលោកយ៉ូហានបាទីស្ទ (ដែលបានមកមុនព្រះយេស៊ូវ) ប៉ុន្តែមិនទាន់បានឮអំពីព្រះយេស៊ូវគ្រីស្ទនៅឡើយទេ បន្ទាប់ពីបានឮដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទពួកគេបានជឿលើទ្រង់និងបានទទួលព្រះវិញ្ញាណបរិសុទ្ធ តាមរបៀបដែលពួកសិស្សដំបូង បានធ្វើសូម្បីតែនិយាយភាសាផ្សេងទៀត (បកប្រែជា ភាសាដទៃ នៅក្នុងព្រះគម្ពីរខ្លះ) ។ កិច្ចការ ១៩: ១-៧

  សម្គាល់: ព្រះវិញ្ញាណបរិសុទ្ធយាងមករស់នៅក្នុងអ្នកជឿ គឺជាការផ្លាស់ប្តូរដ៏សំខាន់មួយ នៅក្នុងប្រវត្តិសាស្ត្រទាំងមូល ប៉ុន្តែមើលមិនឃើញដោយភ្នែក។ អ្នកជឿដែលបានរស់នៅ មុនព្រះយេស៊ូវ ដូចជាអេសាយ និងអ័ប្រាហាំ មិនដែលមានព្រះវិញ្ញាណបរិសុទ្ធមកគង់នៅជារៀងរហូតទេ ទោះបីយើងនឹងឃើញពួកគេដើរ ជាមួយព្រះអម្ចាស់ក៏ដោយ។ (សូមមើល តារាងខាងក្រោមកថាខណ្ឌនេះ។) ដើម្បីជួយមនុស្សឲ្យយល់ពីព្រះពរថ្មី នៃព្រះវិញ្ញាណបរិសុទ្ធ ដែលកំពុងគង់នៅនោះព្រះបានប្រទានភស្តុតាងមិនធម្មតាមួយ នៃព្រឹត្តិការណ៍ដែលកើតឡើងនេះ - សមត្ថភាពក្នុងការនិយាយភាសា ដែលពួកគេមិនបានរៀន។ បន្ទាប់មក នៅពេលដែលក្រុមមនុស្សផ្សេងទៀត

ក្រៅពីសាសន៍យូដា បានជួបប្រទះរឿងដូចគ្នា (សាសន៍សាម៉ារី សាសន៍យូដាពាក់កណ្ដាល សាសន៍ដទៃ ពួកសាសន៍ដទៃ និងអ្នកដែលជឿលើលោកយ៉ូហាន មុនពេលព្រះយេស៊ូវ) សាសន៍យូដាដឹងថា ព្រះវិញ្ញាណបរិសុទ្ធក៏បានមកគង់នៅក្នុងអ្នកផ្សេងទៀត ដោយសារតែពួកគេបានឃើញដូចគ្នា ការអស្ចារ្យដ៏អស្ចារ្យ នៃការនិយាយជាភាសាមួយ ដែលមិនបានរៀន។ មនុស្សគ្រប់គ្នា ដែលបានជឿលើព្រះយេស៊ូវ បន្ទាប់ពីការយាងមកនៃព្រះវិញ្ញាណបរិសុទ្ធ នៅបុណ្យថ្ងៃទី ៥០ តែងតែទទួលបានព្រះវិញ្ញាណបរិសុទ្ធ នៅពេលពួកគេជឿ។ នេះជាអ្វីដែលបានកើតឡើងចំពោះយើង។ បន្ទាប់ពីរយៈពេលនៃការផ្លាស់ប្ដូរជាប្រវត្តិសាស្ត្រ នៃព្រះវិញ្ញាណបរិសុទ្ធមករស់នៅក្នុងមនុស្ស ការអស្ចារ្យនៃការនិយាយជាភាសាពិត ដែលមិនបានរៀន ត្រូវបានផ្ដល់ជាភស្តុតាងនៃព្រះវិញ្ញាណបរិសុទ្ធ មកគង់នៅក្នុងមនុស្ស។ សព្វថ្ងៃនេះ ព្រះទ្រង់តែងតែផ្ដល់សមត្ថភាពការអស្ចារ្យ ដល់បុគ្គលម្នាក់ៗ សម្រាប់គោលបំណងជាក់លាក់ ប៉ុន្តែការនិយាយភាសា ដែលមិនបានរៀន មិនត្រូវបានផ្ដល់ជាភស្តុតាង នៃព្រះវិញ្ញាណបរិសុទ្ធ មកគង់នៅក្នុងមនុស្សម្នាក់ទេ។




សម្គាល់: សព្វថ្ងៃនេះ គ្រីស្ទបរិស័ទ និងមិនមែនជាគ្រីស្ទបរិទមួយចំនួន ធ្វើត្រាប់តាមការអស្ចារ្យនៃការនិយាយជាភាសា ដែលមិនបានរៀន ដោយបង្កើតសំឡេងរដិបរដុប ដោយនិយាយថា វាជាការអស្ចារ្យអធិធម្មជាតិ។ ប៉ុន្តែ គ្មាននរណាម្នាក់ភ្ញាក់ផ្អើល ឬស្ងើចសរសើរ ចំពោះដែលមនុស្សមានសមត្ថភាពតាមរបៀបនោះ កាលពីក្នុងគម្ពីរ កិច្ចការ ទេ។ ប៉ូលបាននិយាយអំពីការធ្វើការអស្ចារ្យនេះ នៅក្នុងសំបុត្ររបស់គាត់ ទៅកាន់ពួកជំនុំ កូរិនថូស (កូរិនថូសទី១ ១៤) ដោយនិយាយថា វាប្រសើរជាង ប្រសិនបើអ្នកនិយាយ ដឹងថាគាត់កំពុងនិយាយអ្វី ហើយប្រសិនបើអ្នកស្ដាប់ ក៏ដឹងពីអ្វី ដែលត្រូវបានគេនិយាយដែរ។ ព្រះទ្រង់ពិតជាអាចផ្ដល់ឲ្យនរណាម្នាក់ មានសមត្ថភាពនិយាយភាសា ដែលពួកគេមិនបានរៀន ប៉ុន្តែ វានឹងជាការអស្ចារ្យជាក់ស្ដែង នៅពេលដែលអ្នកស្ដាប់ឮ ពួកគេនិយាយជាភាសារបស់ពួកគេ!

- ភស្តុតាងសំខាន់បំផុត នៃព្រះវិញ្ញាណបរិសុទ្ធ ដែលគង់នៅក្នុងមនុស្សម្នាក់ គឺលក្ខណៈសម្បត្តិ សេចក្តីស្រឡាញ់ អំណរ មេត្រីភាព ភាពអត់ធ្មត់ សប្បុរស និងការចេះទប់ចិត្ត។ គុណសម្បត្តិទាំងនេះ ត្រូវបានគេហៅថា ជាផលផ្លែនៃព្រះវិញ្ញាណ ដូចដែលបានពិពណ៌នា នៅក្នុង កាឡាទី ៥:២២-២៣ ។ លោកប៉ូលពន្យល់ថា សេចក្តីស្រឡាញ់ គឺសំខាន់បំផុត សូម្បីតែមនុស្សម្នាក់ និយាយភាសា ដែលពួកគេមិនបានរៀនក៏ដោយ ក៏គ្មានប្រយោជន៍ដែរ ប្រសិនបើមិនបានបង្ហាញចេញនូវសេចក្តីស្រឡាញ់ (កូរិនថូសទី១ ១៣:១)។
- ព្រះយេស៊ូវបានពិពណ៌នា អំពីការងាររបស់ព្រះវិញ្ញាណបរិសុទ្ធ ក្នុងពិធីលៀងព្រះអម្ចាស់ ចុងក្រោយ (បុណ្យរំលង) ជាមួយពួកសិស្សរបស់ទ្រង់។ នៅពេលអ្នកអានអ្វី ដែលព្រះយេស៊ូវបានមានបន្ទូល នៅក្នុងយ៉ូហាន ១៤:២៦ និង ១៦:៧-១៥ សូមសរសេរនូវអ្វី ដែលព្រះយេស៊ូវបានមានបន្ទូលថា ព្រះវិញ្ញាណនឹងធ្វើ។ ទាំងនេះគឺជាការសំខាន់ណាស់ សម្រាប់ឲ្យអ្នកយល់ ព្រោះទាំងអស់ គឺជារឿងដែលព្រះវិញ្ញាណបរិសុទ្ធ បានធ្វើ ឬចង់ធ្វើ នៅក្នុងជីវិតរបស់អ្នក។
- អំណោយទាននៃព្រះវិញ្ញាណ គឺជាសមត្ថភាព និងការលើកទឹកចិត្តផ្សេងៗគ្នា ដែលបានផ្តល់ដល់ គ្រីស្ទបរិស័ទផ្សេងៗគ្នា ជាសមាជិកនៃព្រះកាយរបស់ព្រះគ្រីស្ទ។ បទគម្ពីរចម្បងៗចំនួនពីរ ដែលពិពណ៌នាអំពីអំណោយទាំងនេះ គឺ រ៉ូម ១២:៦-៨ និងកូរិនថូសទី១ ១២:១-៣១ ។ គោលបំណងនៃអំណោយទានទាំងនេះ គឺដើម្បីស្អាងមនុស្សឯទៀតឡើង ដូចដែលបានចែងនៅក្នុង កូរិនថូសទី១ ១២:៧ ។

ចូរចងចាំថា ព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះ។ តើអ្នកបានឃើញគុណសម្បត្តិអ្វីខ្លះរបស់ទ្រង់? (សរសេរការសង្កេតរបស់អ្នក នៅក្នុងផ្នែកនៃក្បួនតម្រានេះ ដែលមានចំណងជើងថា “សេចក្តីសង្គ្រោះរបស់ព្រះ”“ព្រះរាជលក្ខណៈរបស់ព្រះ” និង “សេចក្តីសន្យារបស់ព្រះ”)។

## ពេត្រុស

សូមអាន លូកា ៥:១-១១

សូមអាន លូកា ៦ - ២៤

សូមអាន យ៉ូហាន ជំពូក ១៣, ២០ - ២១

ពេត្រុស (ស៊ីម៉ូន ពេត្រុស) គឺជាបុរសម្នាក់ ក្នុងចំណោមបុរសទាំង ១២ នាក់ ដែលព្រះយេស៊ូវបានជ្រើសរើសធ្វើជាសិស្ស និងជាសាវ័ករបស់ទ្រង់។ ពេត្រុសឆាប់និយាយ ពីអ្វីដែលគាត់កំពុងគិត ដែលនោះប្រហែលជាហេតុផល ត្រូវបានសរសេរអំពីគាត់ច្រើន។ គាត់ក៏បានសរសេរសំបុត្រ ពេត្រុសទី១ និងទី២ ដែរ។

- ពេត្រុស នេសាទត្រីដើម្បីចិញ្ចឹមជីវិត មុនពេលជួបព្រះយេស៊ូវ។ ព្រះយេស៊ូវ បានបង្ហាញពីភាពជំឧត្តមរបស់ទ្រង់ ចំពោះពេត្រុស ដោយដាក់ត្រីចូលក្នុងសំណាញ់របស់ពេត្រុស ច្រើនជាងអ្វីដែលគាត់ធ្លាប់មានទៅទៀត (ម៉ាថាយ ៥:១-១១) ។ បន្ទាប់ពីការរស់ឡើងវិញរបស់ព្រះយេស៊ូវ នៅពេលដែលពេត្រុសនៅតែប្រឫកប្របល់ ហើយត្រឡប់ទៅនេសាទវិញ ព្រះយេស៊ូវបានធ្វើការអស្ចារ្យដដែលសម្រាប់គាត់ (យ៉ូហាន ២១: ១-១៤) ទោះបីជាពេត្រុសបានបដិសេធមិនស្គាល់ព្រះយេស៊ូវមុនពេលគេឆ្កាងក៏ដោយ (យ៉ូហាន ១៨:១៥ - ២៧) ) ។ បន្ទាប់មក ព្រះយេស៊ូវបានមានបន្ទូលប្រាប់ពេត្រុសថា ពេត្រុសអាចបង្ហាញសេចក្តីស្រឡាញ់របស់គាត់ ចំពោះព្រះយេស៊ូវ ដោយការផ្តល់ចំណីដល់ចៀមរបស់ទ្រង់ (យ៉ូហាន ២១:១៥-១៧) ។

- ព្រះយេស៊ូវបានប្រាប់ពេត្រុសថា ឈ្មោះរបស់គាត់មានន័យថា "ថ្ម" ហើយថា ព្រះយេស៊ូវនឹងសង់ពួកជំនុំរបស់ទ្រង់នៅលើ "ថ្មដានេះ" (ម៉ាថាយ ១៦:១៧-១៩)។ តើព្រះយេស៊ូវចង់មានន័យយ៉ាងណាពេលទ្រង់មានបន្ទូលទៅពេត្រុស? វិធីល្អបំផុត ដើម្បីដឹងថា ទ្រង់ចង់មានន័យអ្វី គឺត្រូវមើលអ្វីដែលពេត្រុសបានថ្លែងអំពីព្រះយេស៊ូវ សង់ពួកជំនុំរបស់ទ្រង់នៅលើថ្ម។ គាត់បានសរសេរ ការពន្យល់អំពីរឿងនេះ នៅក្នុងសំបុត្ររបស់គាត់ គឺ ពេត្រុសទី១ ២:៤-៨ ។
- ពេត្រុសបានពិសោធ នូវភាពងាយទទួលឥទ្ធិពល ពីសាតាំង។ នៅក្នុង ម៉ាកុស ៨ គាត់មានការយល់ដឹងយ៉ាងខ្លាំង អំពីព្រះយេស៊ូវ ហើយបន្ទាប់មក មិនយូរប៉ុន្មាន គាត់បានផ្តល់ដំបូន្មានព្រះយេស៊ូវ ហើយព្រះយេស៊ូវក៏មានបន្ទូលថា "សាតាំងអើយ ចូរថយទៅក្រោយទៅ" (ម៉ាកុស ៨:២៧-៣៣) ។
- ពេត្រុសបានជួយអ្នកដឹកនាំពួកជំនុំជំនាន់ដើម ឲ្យយល់ថា ព្រះជាអ្នកផ្តល់សេចក្តីសង្គ្រោះ ដល់មនុស្សណាដែលមានចិត្តរាបទាប ចំពោះទ្រង់ ហើយមិនស្របតាមសកម្មភាពរបស់ពួកគេ ឬពួកគេបានកាន់តាមក្រឹត្យវិន័យបានល្អ (កិច្ចការ ១៥:៨-១១) ។ នេះជាការពិត សម្រាប់សាសន៍យូដា និងមនុស្សទាំងអស់។
- ព្រះបានប្រើពេត្រុសបើកទ្វារ សម្រាប់ទំនាក់ទំនងដំណឹងល្អ ទៅកាន់មនុស្ស ដែលមិនមែនជាសាសន៍យូដា (សាសន៍ដទៃ) ។ កាលពីមុន គ្រីស្ទបរិស័ទបានគិតថា មនុស្សត្រូវតែទៅជាសាសន៍យូដាសិន មុនពេលពួកគេអាចទទួលយកព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះរបស់ពួកគេ។ កិច្ចការ ១០: ១ - ១១:១៨។
- ក្នុងជីវិតរបស់ពេត្រុស តើអ្នកសង្កេតមើលរឿងអ្វីខ្លះអំពីព្រះ? (សរសេរការសង្កេតរបស់អ្នកនៅក្នុងផ្នែកនៃក្បួនតម្រានេះ ដែលមានចំណងជើងថា "សេចក្តីសង្គ្រោះរបស់ព្រះ" "ព្រះរាជលក្ខណៈរបស់ព្រះ" និង "សេចក្តីសន្យារបស់ព្រះ")។

## យ៉ូហាន

សូមអាន លូកា ៥: ១-១១

សូមអាន យ៉ូហាន ជំពូក ១ - ២១

សូមអាន យ៉ូហាន, យ៉ូហានទី១, យ៉ូហានទី២ និងយ៉ូហានទី៣

សូមអាន វិវរណៈ ១ - ៥, ២១ - ២២ (ឬគម្ពីរ វិវរណៈទាំងមូល ឲ្យបានឆាប់បំផុត)

- យ៉ូហានជាដៃគូនេសាទ ជាមួយពេត្រុស មុនពេលព្រះយេស៊ូវត្រាស់ហៅពួកគេ ឲ្យធ្វើជាសិស្សរបស់ទ្រង់។ បងប្រុសរបស់យ៉ូហានឈ្មោះយ៉ាកុប ក៏ជាអ្នកនេសាទផងដែរ ហើយបានចូលរួម ជាមួយព្រះយេស៊ូវ ធ្វើជាសិស្សរបស់ទ្រង់។
- នៅពេលដែលយ៉ូហានបានសរសេរ ដំណឹងល្អយ៉ូហាន ពេលខ្លះគាត់សំដៅទៅលើខ្លួនគាត់ថាជា "សិស្សម្នាក់ដែលព្រះយេស៊ូវស្រឡាញ់" (យ៉ូហាន ១៣:២៣) ។
- យ៉ូហានក៏បានសរសេរសំបុត្រចំនួន៣ ដែលក្លាយជាផ្នែក នៃបទគម្ពីរ - យ៉ូហានទី១ ទី២ និងទី៣ ។
- យ៉ូហានសង្កត់ធ្ងន់ថា យើងអាចមានជីវិតអស់កល្បជានិច្ច តាមរយៈជំនឿរបស់យើង លើព្រះយេស៊ូវគ្រីស្ទ។ (យ៉ូហាន ៣:១៦, យ៉ូហាន ៥:២៤, យ៉ូហាន ២០ ៣០-៣១, យ៉ូហានទី១ ៥:១១-១៣)
- នៅជិតចុងបញ្ចប់ នៃជីវិតរបស់គាត់ យ៉ូហានបានសរសេរ គម្ពីរ វិវរណៈ ដែលជាគម្ពីរចុងក្រោយ នៃព្រះគម្ពីរ (វិវរណៈ ១:១-៤) ។ គាត់បានសរសេរ នៅលើកោះ ផាត់ម៉ូស (វិវរណៈ ១:៩) ជាកន្លែង

ដែលគាត់ត្រូវបាននិរទេស ដោយអាជ្ញាធររ៉ូម។ គម្ពីរនេះ គឺជាការបើកសម្តែងជាចម្បង នូវអ្វីដែលព្រះយេស៊ូវគ្រីស្ទ នឹងធ្វើនៅគ្រាចុងក្រោយបំផុត (វិវរណៈ ១:១-២) ។

- ដំណឹងល្អរបស់យ៉ូហាន ដែលបានសរសេរ អំពីព្រះជន្ម ការសុគត និងការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ មានរឿងប្លែកៗជាច្រើន ដែលបានកត់ទុក ពីព្រោះការសង្កត់ធ្ងន់របស់គាត់ គឺផ្តោតលើព្រះយេស៊ូវ ជាព្រះ។ យ៉ូហានពន្យល់ពីគោលបំណងនេះ នៅក្នុង យ៉ូហាន ២០:៣០-៣១ ។
- ក្នុងជីវិតរបស់យ៉ូហាន តើអ្នកសង្កេតឃើញអ្វីខ្លះអំពីព្រះ? (សរសេរការសង្កេតរបស់អ្នកនៅក្នុងផ្នែកនៃក្បួនតម្រានេះ ដែលមានចំណងជើងថា "សេចក្តីសង្គ្រោះរបស់ព្រះ" "ព្រះរាជលក្ខណៈរបស់ព្រះ" និង "សេចក្តីសន្យារបស់ព្រះ")។

## ប៉ូល

សូមអាន កិច្ចការ ៧:៥៤ - ៨: ៣, ៩: ១ - ៣១, ១១:១៩ - ៣០, ១២:២៥ - ២៨:៣១

សូមអាន កាឡាទី ១:១៣-២៤

បន្ទាប់ពីការសោយទិវង្គតរបស់ព្រះយេស៊ូវគ្រីស្ទ ពួកសិស្សរបស់ទ្រង់ បានប្រាប់មនុស្សទាំងឡាយ អំពីព្រះអង្គ ជាស្តេចនៃស្តេច និងជាព្រះអង្គសង្គ្រោះ ឲ្យរួចពីអំពើបាបរបស់យើង។ ដំបូង ប៉ុលបានជំទាស់ នឹងពួកសិស្ស (នៅពេលនោះឈ្មោះរបស់គាត់គឺ សូល) ប៉ុន្តែ បន្ទាប់ពីព្រះយេស៊ូវ បានបង្ហាញអង្គទ្រង់ដល់គាត់ សូលក៏ក្លាយជាអ្នកនាំសារដ៏ខ្នះខ្នែង អំពីព្រះយេស៊ូវគ្រីស្ទផងដែរ (កិច្ចការ ៩:១-៣១) ។ ក្រោយមក គាត់ត្រូវបានគេហៅថា ប៉ូល។

- ប៉ូលបានទទួលការអប់រំខ្ពស់បំផុត ពីសាសន៍យូដា នៅសម័យគាត់ ដែលរួមបញ្ចូលការសិក្សាយ៉ាងខ្លាំង ពីគម្ពីរសញ្ញាចាស់ ដូចដែលយើងហៅសព្វថ្ងៃនេះ។ (ភីលីព ៣:៤-៦)
- ព្រះទ្រង់ជ្រាបថា ចេតនារបស់ប៉ុល គឺចង់ស្តាប់តាមព្រះ ឲ្យអស់ពីសមត្ថភាពរបស់គេ ដូច្នេះព្រះយេស៊ូវគ្រីស្ទ បានសម្តែងអង្គទ្រង់ ឲ្យលោកប៉ូលទទួលសិរីរុងរឿងនៃទ្រង់ ដែលបានរស់ឡើងវិញ (កិច្ចការ ៩:១-៣១ ធីម៉ូថេទី ១ ១: ១២-១៣) ។ នេះជាចំណុចរបត់ នៃជីវិតរបស់ប៉ូល។
- ប៉ុលត្រូវបានបញ្ជូន ជាអ្នកផ្សព្វផ្សាយដំណឹង ពីពួកជំនុំ នៅក្រុងអាន់ទីយ៉ូក (កិច្ចការ ១៣:១-៣)។ តើអ្នកឃើញអ្វីខ្លះអំពីកិច្ចការរបស់ព្រះ តាមរយៈរាស្ត្ររបស់ទ្រង់ នៅក្នុងអត្ថបទនេះ? កត់ត្រាការសង្កេតរបស់អ្នកនៅក្នុងផ្នែក "មូលដ្ឋានគ្រឹះអំពីព្រះ - ព្រះរាជលក្ខណៈរបស់ព្រះ។
- ព្រះបានប្រើប៉ូល ដើម្បីជួយអ្នកដឹកនាំក្រុមជំនុំ ឲ្យយល់កាន់តែច្បាស់ថា សេចក្តីសង្គ្រោះ និងជីវិតជាមួយព្រះ គឺផ្អែកទៅលើព្រះគុណរបស់ព្រះ មិនមែនលើការសម្តែង ឬស្នាដៃរបស់យើងទេ។ ប៉ូលបានពន្យល់អំពីរឿងនេះ ដល់ក្រុមប្រឹក្សាពួកជំនុំក្រុងយេរូសាឡិម (កិច្ចការ ១៥:១៩-២១) ហើយគាត់ក៏បានពន្យល់អំពីរឿងនេះ ដល់ពេត្រុស និងអ្នកដឹកនាំផ្សេងទៀត នៅពេលពួកគេចាប់ផ្តើមសង្កត់ធ្ងន់ លើក្រឹត្យវិន័យសញ្ញាចាស់ ថាចាំបាច់សម្រាប់សេចក្តីសង្គ្រោះ (កាឡាទី ២:១១-២១) ។
- ប៉ុល និងគូកនរបស់គាត់ គឺជាមនុស្សដំបូងគេ ដែលនាំសារដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ទៅកាន់ទីក្រុងជាច្រើន ចាប់ពីក្រុងអាន់ទីយ៉ូក រហូតដល់ប្រទេសក្រិក (កិច្ចការ ១៣-២១)។ នៅក្នុង កិច្ចការ ១៧:២៦-២៧ តើប៉ូលមានការយល់ដឹងអ្វីខ្លះ អំពីរបៀបដែលព្រះធ្វើការ នៅក្នុងជីវិតរបស់មនុស្ស? សរសេរការសង្កេតរបស់អ្នកនៅក្នុងផ្នែក "មូលដ្ឋានគ្រឹះអំពីព្រះ - ព្រះរាជលក្ខណៈរបស់ព្រះ។

- ប៉ូលបានទៅទីក្រុងជាច្រើនទៀត ដែលគាត់បានចាប់ផ្តើមដាំក្រុមជំនុំ ហើយបានសរសេរសំបុត្រទៅពួកគេដើម្បីជួយពួកគេ ឲ្យ រីកចម្រើនក្នុងជីវិតរបស់ពួកគេជាមួយព្រះយេស៊ូវគ្រីស្ទ។ សំបុត្រទាំងនេះភាគច្រើនត្រូវបានទទួលស្គាល់ជាផ្នែកមួយនៃបទគម្ពីរដោយពួកសាវ័កដើមសូម្បីតែនៅក្នុងជីវិតរបស់ប៉ុលក៏ដោយ។ (ពេត្រុសទី២ ៣:១៤-១៦) ដោយដឹងថា សំបុត្រខ្លះត្រូវបានសរសេរពេលប៉ូលជាប់គុក (ដូចជា ភីលីព) តើអ្នកសង្កេតឃើញអ្វីខ្លះអំពីព្រះរាជលក្ខណៈរបស់ព្រះ? (កត់ត្រាការសង្កេតរបស់អ្នកនៅក្នុងផ្នែកសមស្រប)។
- ជីវិតរបស់ប៉ុល ត្រូវបានផ្តល់ជាគម្រូជាច្រើន សម្រាប់យើងធ្វើតាម (ភីលីព ៣:១២-១៧) ។ គម្រូរបស់គាត់ ក្នុងការទាក់ទងមនុស្ស ជាមួយនឹងដំណឹងល្អ និងការចាប់ផ្តើមពួកជំនុំ ត្រូវបានគេអនុវត្តតាម ទូទាំងប្រវត្តិសាស្ត្រទាំងមូល។
- ប៉ុលបានបង្រៀន ពីសេចក្តីបង្រៀន និងគោលលទ្ធិ យ៉ាងប្រុងប្រយ័ត្ន នៅក្នុងសំបុត្រជាច្រើនរបស់គាត់ ជាពិសេស រ៉ូម និង កាឡាទី។
- ក្នុងដំណើររឿងរបស់ប៉ូល តើអ្នកសង្កេតឃើញមានអ្វីផ្សេងទៀត? (សរសេរការសង្កេតរបស់អ្នកនៅក្នុងផ្នែកនៃក្បួនតម្រានេះ ដែលមានចំណងជើងថា "សេចក្តីសង្គ្រោះរបស់ព្រះ" "ព្រះរាជលក្ខណៈរបស់ព្រះ" និង "សេចក្តីសន្យារបស់ព្រះ")។

## ទិដ្ឋភាពទូទៅ (ខ្លាតធំ) នៃព្រះយេស៊ូវគ្រីស្ទ
## បង្ហាញឲ្យឃើញការគ្រប់គ្រងរបស់ព្រះ លើប្រវត្តិសាស្ត្រទាំងអស់

ស្រដៀងនឹងវិធីដែលព្រះបានបង្ហាញអង្គទ្រង់ ហើយកំពុងបង្ហាញអង្គទ្រង់ តាមរយៈសាសន៍អីស្រាអែល នៅទូទាំងប្រវត្តិសាស្ត្រ (ពី លោកុប្បត្តិ រហូតដល់ វិវរណៈ) ទ្រង់ក៏កំពុងតែបង្ហាញអង្គទ្រង់ តាមរយៈព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទដែរ។ នៅក្នុងជំពូកពីរបីដំបូង នៃលោកុប្បត្តិ ភ្លាមៗបន្ទាប់ពីការធ្លាក់ចុះ នៃបុរស និងស្ត្រីដំបូង ព្រះចាប់ផ្តើមបង្ហាញដល់ពួកគេ នូវផែនការរបស់ព្រះអង្គ សម្រាប់ព្រះអង្គប្រោសលោះ មិនត្រឹមតែសម្រាប់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់មនុស្សរាប់ពាន់លាននាក់ នាពេលអនាគត។ ព្រះបង្ហាញផែនការនេះ កាន់តែខ្លាំងឡើងៗ តាមពេលវេលា ដោយធ្វើការថ្លែងទំនាយ នៅក្នុងផ្នែកជាច្រើន នៃបទគម្ពីរ។ បទទំនាយជាច្រើន បានក្លាយជាការពិត នៅពេលដែលព្រះយេស៊ូវបានប្រសូតមកជាទារក មានព្រះជន្មរស់នៅ សុគត និងរស់ឡើងវិញ។ ទាំងនេះគ្រប់គ្រាន់ ដើម្បីបង្ហាញថា ព្រះទ្រង់មានការគ្រប់គ្រងពេញលេញ នៃប្រវត្តិសាស្ត្រទាំងអស់ ប៉ុន្តែនៅតែមានបទទំនាយជាច្រើន នៅតែរង់ចាំ នឹងបំពេញ នៅពេលដែលទ្រង់វិល ត្រឡប់មក ធ្វើជាស្តេចលើអស់ទាំងស្តេច និងជាព្រះអម្ចាស់ លើអស់ទាំងអម្ចាស់។ គម្ពីរ វិវរណៈ គឺជាការសម្រេចចុងក្រោយ នៃបទទំនាយទាំងអស់នេះ។ ខាងក្រោមនេះ ជាសេចក្តីសង្ខេប នៃការថ្លែងទំនាយ អំពីព្រះយេស៊ូវគ្រីស្ទ និងវិធីផ្សេងទៀត ដែលព្រះបានបង្ហាញថា ទ្រង់អាចគ្រប់គ្រងប្រវត្តិសាស្ត្រទាំងមូល។

## ទិដ្ឋភាពទូទៅ (ខ្នាតធំ) នៃព្រះយេស៊ូវគ្រីស្ទ

- លោកុប្បត្តិ ៣:១៤-១៥ - ព្រះមានបន្ទូលថា ពូជ របស់អេវ៉ាម្នាក់ នឹងជាន់ក្បាលពស់ (តំណាងសាតាំង) ហើយពស់ (សាតាំង) នឹងចឹកកែងជើងរបស់ពូជនាងអេវ៉ា។ ព្រះយេស៊ូវគ្រីស្ទ គឺជាអ្នកដែលបានបំពេញ នូវបទទំនាយទាំងពីរនេះ។
- លោកុប្បត្តិ ១២:១-៣ - ព្រះទ្រង់បានមានបន្ទូលថា កូនចៅរបស់អ័ប្រាហាំ នឹងជាពរមួយដល់ពិភពលោក។ ក្រោយមក ព្រះយេស៊ូវគ្រីស្ទ គឺជាពូជម្នាក់ ក្នុងចំណោមកូនចៅទាំងនេះ ហើយទ្រង់ជាព្រះពរដ៏អស្ចារ្យបំផុត ដល់ពិភពលោកទាំងមូល។
- លោកុប្បត្តិ ២២:១-១៩ - ព្រះបានឲ្យអ័ប្រាហាំ ថ្វាយយញ្ញបូជាអ៊ីសាក ជាកូនប្រុសតែមួយរបស់គាត់ ពីសារ៉ា ប៉ុន្តែគាត់ទ្រង់បានប្រាប់អ័ប្រាហាំថា គាត់គួរតែយកទៅថ្វាយ នៅលើភ្នំជាក់លាក់មួយ។ អ័ប្រាហាំ ត្រូវធ្វើដំណើររយៈពេលបីថ្ងៃ ដើម្បីទៅដល់ទីតាំងនេះ ដែលជាភ្នំម៉ូរីយ៉ា ជាកន្លែងដដែលដែលក្រុងយេរូសាឡិម នឹងត្រូវសាងសង់ នាពេលអនាគត និងជាកន្លែងដដែល ដែលព្រះយេស៊ូវនឹងត្រូវគេឆ្កាង គឺជាង ២០០០ ឆ្នាំក្រោយ! ព្រះទ្រង់ជ្រាបថា សាតាំងនឹងបណ្ដាលឲ្យគេ ឆ្កាងទ្រង់ ប៉ុន្តែនៅក្នុងអធិបតេយ្យភាពរបស់ព្រះអង្គ ទ្រង់ជ្រាបច្បាស់ពីកន្លែងដែលវានឹងកើតឡើង។ ព្រះបានគ្រោងទុកថា យញ្ញបូជាដែលបានធ្វើដោយអ័ប្រាហាំ (កន្លែងដែលព្រះបានផ្ដល់ចៀម ដើម្បីជំនួសអ៊ីសាក តំណាងឲ្យព្រះយេស៊ូវ ជាកូនចៀមនៃព្រះ ដែលត្រូវថ្វាយជំនួសយើង) នឹងត្រូវបានធ្វើនៅកន្លែងតែមួយ ជាមួយយញ្ញបូជាដ៏ពិត នោះគឺជាការលះបង់ជំនួសមនុស្សជាតិ គ្រប់ពេលវេលា។
- លោកុប្បត្តិ ២៨:១០-១៥ - ព្រះទ្រង់បានប្រាប់យ៉ាកុបថា កូនចៅរបស់គាត់ នឹងក្លាយជាព្រះពរ ដល់ពិភពលោក ហើយពួកគេនឹងទទួលទឹកដីប៉ាឡេស្ទីនជារៀងរហូត។ ឈ្មោះរបស់យ៉ាកុប ក្រោយមក ត្រូវបានប្ដូរទៅជាអ៊ីស្រាអែល ហើយបន្ទាប់មកព្រះយេស៊ូវ បានក្លាយជាកូនចៅម្នាក់របស់យ៉ាកុប (អ៊ីស្រាអែល)។
- និក្ខមនំ ១១:១ - ១២:១៧, និង ១២:២៩-៣៣ - កូនចៀមនៃបុណ្យរំលង។ កូនច្បងទាំងអស់ នៅស្រុកអេស៊ីព្ទ ត្រូវបានសម្លាប់ ដោយសារតែការបះបោរ ប្រឆាំងនឹងព្រះ។ ប៉ុន្តែ ព្រះមានបន្ទូលថា ប្រសិនបើពួកគេសម្លាប់កូនចៀម ហើយលាបឈាមនៅពីលើទ្វារ នោះទេវតានៃសេចក្ដីស្លាប់ នឹងឆ្លងផុតគ្រួសារពួកគេ។ នៅពេលនោះ ព្រះបានរៀបចំបុណ្យរំលង សម្រាប់ាការចងចាំ ពីព្រឹត្តិការណ៍នេះ និងជារូបភាពនៃអ្វីដែលទ្រង់នឹងធ្វើ នាពេលអនាគត ដូច្នេះមនុស្សទាំងអស់នៅលើពិភពលោក អាចរួចផុតពីការកាត់ទោសប្រហារជីវិត។ - និក្ខមនំ ១១:១ - ១២:១៧, និង ១២: ២៩-៣៣, យ៉ូហាន ១:២៩, កូរិនថូសទី១ ៥:៧, វិវរណៈ ៥:១២-១៣ ។ **សម្គាល់:** ព្រះទ្រង់បានមានបន្ទូលថា បុណ្យរំលង គួរត្រូវបានប្រារព្ធធ្វើនៅថ្ងៃខែឆ្នាំដដែល។ ប្រហែលជា ២ ០០០ ឆ្នាំក្រោយព្រះយេស៊ូវគ្រីស្ទ ដែលជាកូនចៀមបុណ្យរំលង ត្រូវបានគេធ្វើគុត នៅថ្ងៃដដែលនោះ។ សូមអានបន្ថែម អំពីចំណុចនេះ នៅក្នុងចំណុចខាងក្រោម ដែលពិពណ៌នា អំពីព្រះយេស៊ូវ ប្រារព្ធពិធីជប់លៀងចុងក្រោយ (បុណ្យរំលង) ជាមួយពួកសិស្សរបស់ទ្រង់។
- និក្ខមនំ - ត្រសាលជំនុំ ដែលក្រោយមក ហៅថា រោងឧបោសថ គឺជាកន្លែងដែលព្រះបានជួបជាមួយប្រជារាស្ត្ររបស់ព្រះអង្គ និក្ខមនំ ២៥:៨-៩, ៣៣: ៧-១១ ។ ការរចនា បង្ហាញពីអ្វី ដែលចាំបាច់សម្រាប់មនុស្សមានបាប ជួបជាមួយព្រះ (ការថ្វាយយញ្ញបូជា និងការលាងសម្អាត គឺចាំបាច់)។

ក្រឹត្យវិន័យ និងការដាក់ទោសជាច្រើន បានបង្ហាញពីភាពធ្ងន់ធ្ងរ នៃអំពើបាប និងភាពបរិសុទ្ធរបស់ព្រះ។ ចៀម និងសត្វ ត្រូវបានថ្វាយជាយញ្ញបូជា ដោយសារអំពើបាប - និក្ខមនំ ២៩:៣៨-៤៦ ។ នេះគឺជាការអនុវត្តប្រចាំថ្ងៃ និងមេរៀនពីនិមិត្តរូបប្រចាំថ្ងៃថា សេចក្ដីស្លាប់ គឺជាលទ្ធផល នៃអំពើបាប ហើយការស្លាប់ជំនួស គឺចាំបាច់ណាស់ ដូច្នេះមនុស្សមានបាប មិនត្រូវស្លាប់ទេ។ ហេព្រើរ ៩:១-២៨ ក៏ពន្យល់ពីរឿងនេះដែរ។

- សាំយូអែលទី២ ៧: ១១-១៦ - ព្រះមេស្ស៊ីនឹងប្រសូតចេញពីកូនចៅម្នាក់របស់ដាវីឌ - ព្រះទ្រង់បានសន្យាថា កូនចៅម្នាក់របស់ដាវីឌ នឹងគ្រប់គ្រងលើអ៊ីស្រាអែល ជារៀងរហូត។ ស្ដេចនាពេលអនាគតនេះ ត្រូវបានគេហៅថា “ព្រះមេស្ស៊ី” (គឺ “ព្រះគ្រីស្ទ” ជាភាសាក្រិក) ដោយសាសន៍អ៊ីស្រាអែល។
- អេសាយ ៩:៦-៧ - ព្រះបានទាយ តាមរយៈអេសាយថា បុត្រាមួយនឹងប្រសូតមក សម្រាប់សាសន៍អ៊ីស្រាអែល ដែលនឹងត្រូវបានគេហៅថា “ព្រះដ៏ជួយយ៉ាងអស្ចារ្យ ព្រះដ៏មានព្រះគ្រប់ចេស្ដា ព្រះវរបិតាដ៏អស់កល្ប និងជាព្រះអម្ចាស់នៃមេត្រីភាព”។ នោះគឺជាសេចក្ដីថ្លែងការណ៍យ៉ាងច្បាស់មួយ ដែលថា ព្រះអាទិករនៃសកលលោក នឹងប្រសូតមកជាទារកធម្មតា ហើយនឹងជាព្រះមេស្ស៊ីនៃ អ៊ីស្រាអែល។
- អេសាយ ៥៣ - ចាប់ផ្ដើម ពីអេសាយ ៥២:១៣ ព្រះទ្រង់មានបន្ទូល អំពីអ្នកបម្រើរបស់ទ្រង់ ហើយបន្តរៀបរាប់ អំពីមនុស្សម្នាក់ដែលអាចជាព្រះយេស៊ូវគ្រីស្ទ ដែលត្រូវគេចាក់ទម្លុះ និងវាយដំ ហើយផ្ទុកអំពើបាបរបស់មនុស្ស។ អេសាយថ្លែងអំពីអ្នកបម្រើដដែលនោះ នៅក្នុង អេសាយ ៤២:១-៩ ។ ការបញ្ជាក់អះអាងថា អត្ថបទគម្ពីរទាំងនេះពិពណ៌នា អំពីព្រះយេស៊ូវគ្រីស្ទ គឺចេញមកពីសំណេររបស់អ្នកដើរតាមព្រះយេស៊ូវ។ ម៉ាថាយ ផ្ទៀងផ្ទាត់ខគម្ពីរ អេសាយ ៤២:១-៤ នៅក្នុង ម៉ាថាយ ១២:១៥-២១ ។ បទគម្ពីរ អេសាយ ជំពូក ៥៣ ត្រូវបានផ្ទៀងផ្ទាត់ដោយ លូកា ដែលបានដកស្រង់អ្វី ដែលភីលីព បាននិយាយទៅកាន់សាសន៍អេត្យូពី នៅក្នុង កិច្ចការ ៨:៣០-៣៥ ។
- មីកា ៥: ២ - មានការថ្លែងទំនាយយ៉ាងច្បាស់ថា ស្រុកកំណើតរបស់ព្រះមេស្ស៊ី នឹងស្ថិតនៅ ភូមិ បេថ្លេហិម-អេប្រាតា ដោយកំណត់ថា ភូមិបេថ្លេហិម ព្រោះមានក្រុងពីរឈ្មោះបេថ្លេហិម នៅអ៊ីស្រា អែល។ នៅពេលដែលពួកអ្នកប្រាជ្ញ មកពីទិសខាងកើត ហើយបានសួរហេរ៉ូឌ ពីកន្លែងដែលព្រះឱរសដ៏ជាស្ដេចត្រូវប្រសូត អ្នកប្រាជ្ញអាចរកមើលនៅក្នុងគម្ពីរ ហើយប្រាប់ហេរ៉ូឌ នូវចម្លើយពិតប្រាកដ (ម៉ាថាយ ២: ៤-៨) ។

  សម្គាល់: មានភស្ដុតាងពិសេសសម្រាប់យើង ដើម្បីដឹងថា ការថ្លែងទំនាយនេះ និងអ្វីផ្សេងទៀតជាច្រើន មានលក្ខណៈត្រឹមត្រូវ ជាប្រវត្តិសាស្ត្រ ហើយមិនដែលត្រូវបានផ្លាស់ប្ដូរ ពីបទទំនាយដើមឡើយ។ ឯកសារគម្ពីរសញ្ញាចាស់ ដែលយើងមានសព្វថ្ងៃនេះ ត្រូវបានគេប្រៀបធៀប ជាមួយនឹងក្រាំងគម្ពីរមួយចំនួនធំ ដែលត្រូវបានរកឃើញនៅក្នុងរូងភ្នំ នៅក្បែរសមុទ្រស្លាប់ (ពីឆ្នាំ ១៩៤៦ - ១៩៥៦) ។ ក្រាំងទាំងនេះ ត្រូវបានគេកំណត់កាលបរិច្ឆេទ ថាត្រូវបានសរសេរប្រហែល ១០០ មុនគ.ស.។ ឯកសារទាំងអស់ ត្រូវគ្នានឹងការសរសេរគម្ពីរសញ្ញាចាស់ ដូចដែលយើងមានសព្វថ្ងៃ ជាភាសាហេព្រើរ ស្ទើរតែមិនមានការផ្លាស់ប្ដូរ!
- ម៉ាថាយ ១:៦-១៦ - ពង្សាវតារ ពីអ័ប្រាហាំ ដល់ដាវីឌ ហើយដល់ព្រះយេស៊ូវ ត្រូវបានផ្ដល់មក តាមរយៈខ្សែរស្រឡាយរបស់យ៉ូសែប (ស្វាមីរបស់នាងម៉ារា បន្ទាប់ពីកំណើត ព្រះយេស៊ូវ)។ លូកា ៣: ២៣-៣១ គឺជាបញ្ជីពង្សាវតារ តាមរយៈបុព្វបុរសរបស់នាងម៉ារា។ ពង្សាវតារទាំងពីរនេះបង្ហាញថា

ព្រះទ្រង់បានរក្សាសេចក្ដីសន្យា និងបទទំនាយចំពោះអ័ប្រាហាំ (លោកុប្បត្តិ ១២:១-៣) ហើយក៏ជាសេចក្ដីសន្យា និងបទទំនាយចំពោះដាវីឌដែរ (សាំយូអែលទី២ ៧:១២-១៦) ។ (មានភាពខុសគ្នានៅក្នុងពង្សាវតារទាំងពីរនេះ ដែលអាចពន្យល់បានតាមទំនៀមទម្លាប់ខុសគ្នានៃការកត់ត្រាពង្សាវតាររបស់សាសន៍យូដា។)

- ម៉ាថាយ ១:២១ - ទេវតាបានប្រាប់ម៉ារាថា បុត្ររបស់នាង គួរតែថ្វាយព្រះនាមថា យេស៊ូវ ដែលមានន័យថា "ព្រះអង្គសង្គ្រោះ" ជាភាសាខ្មែរ ពីព្រោះគោលបំណងរបស់ព្រះ គឺថា ព្រះយេស៊ូវនឹងផ្ដល់ផ្លូវសម្រាប់អស់អ្នកណា ដែលចង់បានជីវិត ជាមួយព្រះយេស៊ូវគ្រីស្ទ មុនពេលដែលទ្រង់ឡើងសោយរាជ្យនៅលើផែនដី។ ។
- យ៉ូហាន ១:២៩ - មុនពេលព័ន្ធកិច្ចជាសាធារណៈរបស់ព្រះយេស៊ូវ យ៉ូហានបាទីស្ទទទួលស្គាល់ថា ព្រះយេស៊ូវជា «កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក!»
- ព្រះយេស៊ូវផ្ទាល់ បានមានបន្ទូលថា «ខ្ញុំមិនមែនមកដើម្បី ឲ្យគេបម្រើទេ គឺដើម្បីបម្រើគេវិញ ក៏នឹងឲ្យជីវិតខ្ញុំទុកជាថ្លៃលោះមនុស្សជាច្រើន»។ (ម៉ាកុស ១០:៤៥)
- ព្រះយេស៊ូវបានពន្យល់ អំពីនិមិត្តរូប នៃអាហារបុណ្យរំលង នៅពេលទ្រង់បាសោយជាមួយពួកសិស្សពីរបីម៉ោងមុនពេលទ្រង់ត្រូវថ្វាយជាយញ្ញបូជា ជំនួសសេចក្ដីរំលង និងអំពើបាបរបស់យើង។ ចាប់ពីលូកា ២២:១៤-២៥ យើងដឹងថា ពួកគេបានចែកយ៉ាងហោចណាស់ពីរពែង មួយក្នុងកំឡុងពេលអាហារ និងមួយទៀតបន្ទាប់ពីអាហារ តាមដែលពួកយូដាបានធ្វើ ចាប់តាំងពីសម័យអែសរ៉ា។ អស់រយៈពេលរាប់រយឆ្នាំមកហើយ សាសន៍អ៊ីស្រាអែល (សាសន៍យូដា) បានប្រើនំបុ័ងឥតដំបែ ដើម្បីរំឭកពីការរងទុក្ខ នៅស្រុកអេស៊ីព្ទ ហើយឥឡូវនេះ ព្រះយេស៊ូវមានបន្ទូលថា «នេះជារូបកាយខ្ញុំ ដែលបានឲ្យមកអ្នក ចូរធ្វើបែបនេះដើម្បីរំឭកពីខ្ញុំ" (លូកា ២២:១៩) ។ បន្ទាប់មក ពេលពួកគេចែកពែងបន្ទាប់ពីបរិភោគរួច គេហៅថា ពែងនៃការលោះដែលតំណាង ឲ្យឈាមរបស់កូនចៀម ដែលលាបនៅខាងលើទ្វារ ដើម្បីលោះពួកគេ ពីសេចក្ដីស្លាប់។ ព្រះយេស៊ូវមានបន្ទូលថា "ពែងនេះជាសញ្ញាថ្មី ដោយនូវឈាមខ្ញុំ ដែលត្រូវចាក់សម្រាប់អ្នករាល់គ្នា" (លូកា ២២:២០)។
- សាតាំងកំពុងតែធ្វើការប្រហារព្រះជន្មព្រះយេស៊ូវ (លូកា ២២:៣) ប៉ុន្តែវាបានជួយដោយអចេតនា ដើម្បីបង្ហាញថា អធិបតេយ្យរបស់ព្រះ គឺអស្ចារ្យប៉ុណ្ណា។ ទោះជាសត្រូវដ៏អាក្រក់បំផុតរបស់ព្រះអង្គ ទាស់ប្រឆាំងនឹងទ្រង់ក៏ដោយ ព្រះទ្រង់បានធ្វើអ្វីៗដើម្បី ឲ្យពេលវេលានៃការសោយទិវង្គតរបស់ព្រះយេស៊ូវ គឺដូចគ្នានឹងពេលដែលកូនចៀមនៃបុណ្យរំលង ត្រូវបានគេសម្លាប់ ហើយយកមកធ្វើជាផ្នែកនៃអាហារ និងការប្រារព្ធពិធី សម្រាប់ការចងចាំពីសេចក្ដីសង្គ្រោះរបស់ព្រះ ពីការស្លាប់នៅអេស៊ីព្ទប្រហែលជា ២០០០ឆ្នាំមុន។ និមិត្តសញ្ញា និងការពិតបានកើតឡើងក្នុងពេលតែមួយ!
- ខណៈពេលដែលព្រះយេស៊ូវកំពុងតែបង្រៀននៅទីនេះ ទ្រង់បានមានបន្ទូលថា នៅពេលដែលទ្រង់ជិតយាងត្រឡប់មកវិញ នោះនឹងមានទីសម្គាល់ នៅក្នុងពិភពលោក (ម៉ាថាយ ២៤) ហើយមានខ្លះដែលយើងកំពុងតែជួបប្រទះ សព្វថ្ងៃនេះ។ ទាំងនេះរួមបញ្ចូលទាំងសង្គ្រាម និងពាក្យចចាមអារាមអំពីសង្គ្រាម ទុរភិក្ស រញ្ជួយដី ការធ្វើទុក្ខបុកម្នេញរបស់គ្រីស្ទបរិស័ទ នៅជុំវិញពិភពលោក ព្រះគ្រីស្ទក្លែងក្លាយ និងហោរាក្លែងក្លាយ សម្ដែងការអស្ចារ្យ និងបញ្ហាកាន់តែអាក្រក់ទៅៗ។

- នៅចុងបញ្ចប់ នៃប្រវត្តិសាស្ត្រមនុស្សជាតិនៅលើផែនដី ដូចដែលយើងបានដឹងហើយថា ព្រះយេស៊ូវគ្រីស្ទ គឺជាតំណាងឲ្យកូនចៀម។ នៅក្នុងកណ្ឌចុងក្រោយនៃព្រះគម្ពីរ (វិវរណៈ) ដែលពិពណ៌នាអំពីការងារចុងក្រោយរបស់ព្រះ ជាមួយពិភពលោក ព្រះយេស៊ូវត្រូវបានគេហៅថា "កូនចៀម" សាមសិបមួយ ដង។ កូនចៀម គឺជាតួអង្គសំខាន់បំផុត នៅក្នុងកម្រិតកំពូលនៃប្រវត្តិសាស្ត្រ។ ទ្រង់ត្រូវបានគេហៅថា កូនចៀម ពីព្រោះយញ្ញបូជារបស់ទ្រង់ គឺជាមូលដ្ឋានពេញលេញ សម្រាប់មនុស្សមានបាប ដែលត្រូវបានស្តារឡើងវិញ នូវទំនាក់ទំនងប្រកបដោយសេចក្តីស្រឡាញ់ដ៏អស់កល្ប ជាមួយព្រះអាទិកររបស់ពួកគេ។

ការសម្រេចនៃបទទំនាយទាំងអស់នេះ ក្នុងរយៈពេល ៤ ០០០ ឆ្នាំ បង្ហាញឲ្យឃើញច្បាស់ថា នរណាជាអ្នកត្រួតត្រាប្រវត្តិទាំងមូល!

# សេចក្តីសង្គ្រោះរបស់ព្រះ

ព្រះយេស៊ូវគ្រីស្ទបានមានបន្ទូលថា ទ្រង់ត្រូវបានចាត់មកក្នុងពិភពលោក ដើម្បីជួយសង្គ្រោះ ពីការជំនុំជម្រះ (យ៉ូហាន ៣:១៧) ។ តើសេចក្តីសង្គ្រោះនេះ កើតឡើងយ៉ាងដូចម្តេច?

នៅពេលអ្នកដឹកនាំសាសនាម្នាក់ បានមកនិយាយជាមួយទ្រង់ផ្ទាល់ អំពីរឿងខាងវិញ្ញាណ ព្រះយេស៊ូវបានមានបន្ទូលប្រាប់គាត់ថា "ខ្ញុំប្រាប់អ្នកការពិតថា គ្មាននរណាម្នាក់អាចឃើញនគរព្រះបានទេ លើកលែងតែអ្នកកើតជាថ្មី" (យ៉ូហាន ៣:៣) ។ បន្ទាប់មក លោកនីកូដេម ដែលជាអ្នកដឹកនាំសាសនា សួរថា តើរឿងបែបនេះអាចកើតឡើងយ៉ាងដូចម្តេច។

មិនថាត្រូវបានហៅថា សេចក្តីសង្គ្រោះ ឬការចាប់កំណើតជាថ្មីទេ នេះគឺជាសេចក្តីសង្ខេប នៃអ្វីដែលព្រះគម្ពីរបានចែង អំពីរបៀបដែលព្រះ បានប្រទានជីវិតអស់កល្បជានិច្ច សម្រាប់មនុស្សគ្រប់គ្នា ដែលចង់បាន។ ចំណងជើងនៃផ្នែកដែលផ្តល់ការយល់ដឹង អំពីសេចក្តីសង្គ្រោះរបស់ព្រះ មាននៅខាងក្រោមនេះ។ បន្ទាប់មក ធ្វើតាមតារាងផ្នែកនីមួយៗ ដើម្បីពង្រីកការយល់ដឹងអត្ថបទគម្ពីរ។ បន្ទាប់ពីផ្នែកនីមួយៗ ក៏មានកន្លែងទំនេរមួយ ដែលអ្នកអាចសរសេរអត្ថបទព្រះគម្ពីរជាច្រើនទៀត ដែលជួយអ្នកឲ្យយល់ពីសេចក្តីពិត ដូចគ្នាទាំងនេះ។

**១. បញ្ហារបស់មនុស្ស**

**២. ភាពមិនគ្រប់គ្រាន់របស់មនុស្ស**

**៣. ការផ្គត់ផ្គង់របស់ព្រះ**

**៤. ការឆ្លើយតបរបស់មនុស្សចំពោះព្រះ**

**៥. ការធានារបស់ព្រះ ចំពោះប្រជារាស្ត្ររបស់ទ្រង់**

ប្រធានបទទាំង ៥ គឺស្ថិតនៅផ្នែកខាងលើ នៃទំព័រមួយ ក្នុងចំណោមទំព័រខាងក្រោម។ កន្លែងទំនេរ អាចឲ្យអ្នកសរសេរសេចក្តីយោង និងការពន្យល់ព្រះគម្ពីរ ដែលទាក់ទងនឹងប្រធានបទទាំងប្រាំនេះ។ ប្រធានបទនីមួយៗ ជួយយើងឲ្យយល់ពីរបៀបដែលព្រះបានជួយមនុស្ស ក្នុងស្ថានភាពជាច្រើន និងសេចក្តីសង្គ្រោះជារៀងរហូត ពីអំពើបាប និងសេចក្តីស្លាប់ ដែលព្រះបានផ្តល់ក្នុងរបៀបដ៏អស្ចារ្យ តាមរយៈព្រះយេស៊ូវគ្រីស្ទ។

## ១. បញ្ហារបស់មនុស្ស

- លោកុប្បត្តិ ២:១៥-១៧, ៣:១-១៩ - អ័ដាម និងអេវ៉ា បានបាត់បង់ទំនាក់ទំនងជាមួយព្រះ នៅពេលពួកគេបានប្រព្រឹត្តអំពើបាបដំបូង។
- យ៉ាកុប ២:១០ - សកម្មភាព នៃការមិនស្តាប់បង្គាប់ព្រះ ធ្វើឲ្យយើងឃ្លាតឆ្ងាយពីទ្រង់ ទៅកម្រិតនៃអំពើបាបទាំងអស់។
- ម៉ាថាយ ៥:២១-២២, ២៧-២៨ - គំនិតខុស គឺធ្ងន់ធ្ងរដូចគ្នានឹងសកម្មភាពខុស នៅចំពោះព្រះ។

អំពើបាបប្រភេទណាក៏ដោយ ក៏អាចបំបែកយើងចេញពីព្រះ ហើយបណ្តាលឲ្យស្លាប់ខាងវិញ្ញាណដែរ។ ខាងក្រោមនេះជាបទគម្ពីរខ្លះ ដែលពន្យល់អំពីរឿងនេះ៖
ប្រាក់ឈ្នួលនៃអំពើបាបគឺសេចក្តីស្លាប់ (រ៉ូម ៦:២៣) ។

- ផលវិបាកសម្រាប់អំពើបាបគ្រប់ប្រភេទ មិនត្រឹមតែជាសេចក្តីស្លាប់ខាងរូបកាយប៉ុណ្ណោះទេ ប៉ុន្តែក៏ជាសេចក្តីស្លាប់អស់កល្បជានិច្ចផងដែរ (ថែស្សាឡូនីចទី២ ១:៩, វិវរណៈ ២០:១១-១៥ និង ២១:៨) ដែលជាការបំបែកចេញពីព្រះ ទៅក្នុងសេចក្តីវេទនាអស់កល្បជានិច្ច ក្នុងបឹងភ្លើង។

ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ២. ភាពមិនគ្រប់គ្រាន់របស់មនុស្ស

- យ៉ាកុប ២:១០ - មិនថាមនុស្សម្នាក់ធ្វើបានល្អប៉ុណ្ណាទេ វានៅតែមិនគ្រប់គ្រាន់ ក្នុងការបង់ថ្លៃពិន័យខាងព្រលឹងវិញ្ញាណ ដែលមនុស្សគ្រប់គ្នាសមនឹងទទួល។
- កាឡាទី ២:១៦, ២០-២១ - មិនថាមនុស្សម្នាក់កាន់សាសនាបែបណាក៏ដោយ វាមិនគ្រប់គ្រាន់ទេ ក្នុងការបង់ថ្លៃពិន័យ ខាងព្រលឹងវិញ្ញាណរបស់គាត់។
- ទំនុកតម្កើង ៤៩:៧-៩ - មនុស្សម្នាក់ផ្សេងទៀត មិនអាចសងទោសប្រហារជីវិត ជំនួសនរណាម្នាក់បានទេ ពីព្រោះពួកគេត្រូវបង់ថ្លៃពិន័យរបស់ខ្លួនឯង ដែលជាសេចក្តីស្លាប់អស់កល្បជានិច្ច។

ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ៣. ការផ្គត់ផ្គង់របស់ព្រះ

- អេភេសូរ ១:៣-១០ - ព្រះមានផែនការជួយសង្គ្រោះ (សង្គ្រោះ) មនុស្សមុនពេលដែលលោកបានបង្កើតពួកគេ។
- រ៉ូម ៥:៦-១១ - ទោះបីយើងប្រៀបដូចជាខ្មាំងសត្រូវរបស់ព្រះ ហើយអស់សង្ឃឹមទាំងស្រុង ក្នុងការផ្តល់សេចក្តីសង្គ្រោះដល់ខ្លួនយើងក៏ដោយ ក៏ព្រះចាត់វិធានការប្រកប ដោយសេចក្តីស្រឡាញ់ ហើយធ្វើឲ្យមានសេចក្តីសង្គ្រោះ។
- ហេព្រើរ ១០:៨ - ការបូជាសត្វ គឺមិនគ្រប់គ្រាន់ សម្រាប់ទោសប្រហារជីវិត ចំពោះមនុស្សទេ។
- ព្រះ ដែលជាចៅក្រមរបស់យើង បានសម្រេចថា មនុស្សល្អឥតខ្ចោះម្នាក់ អាចទទួលទោសប្រហារជីវិតរបស់មនុស្សដទៃទៀតបាន (ហេព្រើរ ១០:៨-១៤) ។ ដើម្បីធ្វើឲ្យមានលទ្ធភាពនេះ ព្រះផ្ទាល់បានត្រឡប់ជាមនុស្ស ដែលមានគត៌បែបអធិធម្មជាតិ ជាមួយនាងម៉ារា ប្រហែលជា ២ ០០០ ឆ្នាំ មុន។ បុត្រារបស់នាងម៉ារា ត្រូវបានថ្វាយព្រះនាមថា យេស៊ូវ ហើយនៅពេលដែលទ្រង់ចម្រើនវ័យធំឡើង ទ្រង់បានមានបន្ទូលថា គាត់គឺជា ព្រះគ្រីស្ទ (ព្រះមេស្ស៊ី) ដូច្នេះហើយ ទើត្រូវបានគេហៅថា ព្រះយេស៊ូវគ្រីស្ទ។ ទ្រង់បានប្រាប់អ្នកដើរតាមទ្រង់ថា ទ្រង់បានមកដើម្បីទទួលទោសប្រហារជីវិត ដែលយើងម្នាក់ៗសមនឹងទទួល (ម៉ាកុស ១០:៤៥) ។
- ពេលព្រះយេស៊ូវគ្រីស្ទត្រូវបានគេកាត់ទោសប្រហារជីវិត ដោយព្យួរនៅលើឈើឆ្កាង នោះទ្រង់បានស្រែកថា «ព្រះអង្គ ឱព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជាព្រះអង្គបោះបង់ចោលទូលបង្គំ? (ម៉ាថាយ ២៧:៤៦) នៅពេលនោះទ្រង់កំពុងមានសេចក្តីក្រោធយ៉ាងពេញទី នៃភាពយុត្តិធម៌របស់ព្រះ ប្រឆាំងនឹងអំពើបាបរបស់មនុស្ស។ (រ៉ូម ៨:៣-៤, កូរិនថូសទី២ ៥:២១)
- ព្រះយេស៊ូវគ្រីស្ទ គឺជាថ្លៃសងជំនួស (យញ្ញបូជា) សម្រាប់ទោសប្រហារជីវិតរបស់យើង។ នេះត្រូវបានធ្វើជានិមិត្តរូប តាមវិធីជាច្រើន តាំងពីដំបូងនៃព្រះគម្ពីរ រហូតដល់ចប់។
    - ព្រះទ្រង់បានប្រទានចៀមមួយ សម្រាប់អ័ប្រាហាំ ដើម្បីបូជាជំនួស កូនប្រុសរបស់គាត់ - លោកុប្បត្តិ ២២ ។
    - កូនចៀមនៃបុណ្យរំលង ត្រូវបានថ្វាយជាយញ្ញបូជា ដូច្នេះកូនច្បង នឹងមិនត្រូវស្លាប់ - និក្ខមនំ ១២:១-១៣ ។
    - យញ្ញបូជាសត្វ ត្រូវតែធ្វើនៅឯត្រសាលជំនុំ ដើម្បីតំណាងការទូទាត់សងបាប - លេវីវិន័យ ៤: ៣២-៣៥, ៥: ១-១៩ ។
    - អ្នកបម្រើព្រះ (មេស្ស៊ី) នឹងទទួលទោស ពីអំពើបាបរបស់យើង។ - អេសាយ ៥៣
    - ព្រះយេស៊ូវគ្រីស្ទ ត្រូវបានគេហៅថា ជាកូនចៀមនៃព្រះ ជាច្រើនដង (៣១ ដង) នៅក្នុង វិវរណៈ។ (វិវរណ: ៧:១៧, ១៥:៣, ២១:២៣)
- ព្រះយេស៊ូវគ្រីស្ទ បានបង្ហាញភស្តុតាងថា ការថ្វាយបូជារបស់ទ្រង់ សម្រាប់អំពើបាប គឺត្រឹមត្រូវហើយ គ្រប់ពាក្យរបស់ទ្រង់សុទ្ធតែពិត។ ទ្រង់បានទាយប្រាប់អ្នកដើរតាមទ្រង់ថា នៅថ្ងៃទីបីបន្ទាប់ពីទ្រង់សោយទិវង្គត នោះទ្រង់នឹងមានព្រះជន្មរស់ឡើងវិញ (ម៉ាថាយ ១៦:២១) ។ នេះគឺជាការបង្ហាញយ៉ាងច្បាស់ថា រាល់ការអះអាងរបស់ទ្រង់ គឺពិត ហើយថា ទ្រង់ពិតជាព្រះ ដែលបានត្រឡប់ជាមនុស្ស

ដើម្បីជួយសង្គ្រោះយើង។ (យ៉ូហាន ៥:៣៦) ទោះជាសត្រូវរបស់ព្រះយេស៊ូវបានធ្វើ ដើម្បីទប់ស្កាត់រស់ឡើងវិញរបស់ទ្រង់ នៅថ្ងៃទីបីក៏ដោយ ទ្រង់បានលេចមកជួបអ្នកដើរតាមទ្រង់ និងអ្នកឯទៀត។ ទ្រង់បានជួបជាមួយមនុស្សអស់រយៈពេល ៤០ ថ្ងៃ ហើយនៅពេលដែលក្រុមមួយ មើលឃើញទ្រង់បានឡើងទៅលើពពក។ មុនពេលដែលព្រះយេស៊ូវចាកចេញទៅ ទ្រង់បានបញ្ជាក់យ៉ាងច្បាស់ថាទ្រង់នឹងវិលត្រឡប់មកធ្វើជាអ្នកគ្រប់គ្រងពិភពលោកនេះវិញ ហើយក្រោយមក នឹងត្រូវជំនុំជម្រះមនុស្សចុងក្រោយ។ (ម៉ាថាយ ២៧:៦២-៦៦, កិច្ចការ ១:១-១១)

ការពន្យល់ព្រះគម្ពីរបន្ថែមៈ

## ៤. ការឆ្លើយតបរបស់មនុស្ស ចំពោះព្រះ

- រ៉ូម ៥: ១៥-១៧, ៦:២៣, អេភេសូរ ២:៨-៩ - ផែនការរបស់ព្រះ សម្រាប់ការដាក់ទោសនៃអំពើបាបរបស់យើង តាមរយៈព្រះយេស៊ូវគ្រីស្ទ ត្រូវបានពិពណ៌នាថា ជាអំណោយទាន។
- យ៉ូហាន ១:១២, រ៉ូម ១០:៩-១៣ - អ្វីដែលត្រូវការសម្រាប់សេចក្តីសង្គ្រោះ គឺជាជំនឿថា ព្រះកំពុងតែផ្តល់អំណោយទាន ហើយទទួលយកអំណោយនោះ។
- រ៉ូម ១០:៩-១៣, កិច្ចការ ១៦:៣១ - ការទទួលយកអំណោយទានរបស់ព្រះ ត្រូវបានបង្ហាញដោយការប្រាស្រ័យទាក់ទងជាមួយព្រះ។ នេះអាចត្រូវបានធ្វើដោយផ្ទាល់មាត់ ឬដោយគំនិតរបស់យើង។
- លូកា ២៣:៤០-៤៣ - ឧទាហរណ៍ នៃចោរម្នាក់នៅលើឈើឆ្កាង ក្បែរព្រះយេស៊ូវ បង្ហាញពីរបៀបដែលអាចទទួលយកអំណោយទាន នៃសេចក្តីសង្គ្រោះនេះ។

ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ៥. ការធានារបស់ព្រះចំពោះប្រជារាស្ត្ររបស់ទ្រង់

ខាងក្រោមនេះ ជាខយោងព្រះគម្ពីរ ដែលបញ្ជាក់ថា យើងគឺជាផ្នែកនៃក្រុមគ្រួសារអស់កល្បរបស់ព្រះ បន្ទាប់ពីយើងបានទុកចិត្តលើព្រះយេស៊ូវគ្រីស្ទ ជាអ្នកដែលបានសងថ្លៃលោះបាបរបស់យើងទាំងអស់។

- យ៉ូហាន ៥:២៤
- រ៉ូម ៨: ១-៤
- យ៉ូហានទី ១ ៥: ១១-១៣
- ហេព្រើរ ១០: ១០-១៤
- ទំនុកតម្កើង ១០៣: ១២

ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ការផ្តោតសំខាន់នៃប្រវត្តិសាស្រ្ត

ការលះបង់របស់ព្រះយេស៊ូវគ្រីស្ទ គឺជាការផ្តោតសំខាន់នៃប្រវត្តិសាស្រ្តទាំងមូល ពីអតីតកាល បច្ចុប្បន្នកាល និងអនាគត។

ការផ្តល់សេចក្តីសង្គ្រោះរបស់ព្រះ បានមកតាមរយ:ព្រះយេស៊ូវគ្រីស្ទ ដែលបានរស់នៅ ក្នុងជីវិតសាមញ្ញបំផុត ក្រីក្រ ហើយមានរយ:ពេលតែ ៣ ឆ្នាំ នៃការបម្រើជាសាធារណ:។ ប៉ុន្តែ ព្រះជន្មគង់ និងការសុគត និងការរស់ឡើងវិញរបស់ទ្រង់ មានឥទ្ធិពលខ្លាំង លើពិភពលោកនេះ ជាងមនុស្សដទៃទៀត។ ព្រះបានរៀបចំពិភពលោក សម្រាប់ការយាងមករបស់ព្រះយេស៊ូវ ដោយកត់ទុកបទទំនាយទុកមុន នៅពេលដែលបានកើតឡើង (លូកា ២៤:២៥-២៧)។ ព្រះក៏បាននាំមកនូវព្រឹត្តិការណ៍ពិសេសៗ ដើម្បីជួយមនុស្សឲ្យត្រៀមខ្លួនសម្រាប់ព្រះយេស៊ូវគ្រីស្ទ ដែលត្រូវបានគេហៅថា ព្រះរាជបុត្រានៃព្រះ កូនមនុស្ស និងជាព្រះអង្គសង្គ្រោះនៃពិភពលោក។

- ព្រះបានបង្រួមបណ្តាញគ្រួសារ ដែលព្រះមេស្ស៊ី (ព្រះគ្រីស្ទ) នឹងចាប់កំណើត ជាបន្តបន្ទាប់ ដោយចាប់ផ្តើម ពីអ័ប្រាហាំ អ៊ីសាក យ៉ាកុប យូដា នាងរស់ ដាវីឌ និងកូនចៅសាឡូម៉ូន។
- ព្រះ បានទាយអំពីទីក្រុងតូចមួយជាក់លាក់ ដែលព្រះមេស្ស៊ី (ព្រះគ្រីស្ទ) នឹងប្រសូតមក (មីកា ៥:២) ប្រហែលជាប្រាំរយឆ្នាំមុនព្រឹត្តិការណ៍នេះ។
- ព្រះ ក៏បានទាយទុកមុនជាង ៤០០ ឆ្នាំ មុនព្រឹត្តិការណ៍ដែលព្រះឱរសពិសេស ប្រសូតក្នុងគ្រួសារអ៊ីស្រាអែល ជាព្រះដ៏មានព្រះចេស្តា (អេសាយ ៩:៦) ។
- ទីតាំងនៃការសោយទិវង្គតរបស់ព្រះយេស៊ូវ គឺជាការអស្ចារ្យមួយទៀត។ ទោះបីជាសត្រូវរបស់ទ្រង់បានសម្រេចចិត្តកាត់ទោសប្រហារជីវិតទ្រង់ក៏ដោយ តែទីនោះគឺស្ថិតនៅលើភ្នំតែមួយ (ភ្នំម៉ូរីយ៉ា) ជាកន្លែងដែលព្រះបានសុំអ័ប្រាហាំ ឲ្យថ្វាយកូនប្រុសរបស់គាត់ ហើយកន្លែងដែលព្រះបានផ្តល់ចៀមដើម្បីជំនួស ដូច្នេះមនុស្សនឹងមិនត្រូវស្លាប់ឡើយ។
- ពេលវេលានៃការសោយទិវង្គតរបស់ព្រះយេស៊ូវ គឺអស្ចារ្យណាស់។ ទោះបីជាសត្រូវរបស់ទ្រង់បានសម្រេច នៅពេលដែលត្រូវប្រហារជីវិតក៏ដោយ វាគឺជាពេលដំណាលគ្នា នឹងពេលនៃបុណ្យរំលងដែរ នៅពេលដែលពួកយូដាបានសម្លាប់កូនចៀម ក្នុងការចងចាំពីចៀមបុណ្យរំលង ដែលត្រូវបានសម្លាប់នៅស្រុកអេស៊ីព្ទ ដូច្នេះប្រជាជនមិនចាំបាច់ស្លាប់។
- នៅចុងបញ្ចប់នៃប្រវត្តិសាស្រ្តមនុស្សជាតិនៅលើផែនដី ដូចដែលយើងបានដឹងហើយថា ព្រះយេស៊ូវគ្រីស្ទត្រូវជាតំណាង ឲ្យកូនចៀម។ នៅក្នុងកណ្ឌចុងក្រោយនៃព្រះគម្ពីរ (វិវរណ:) ដែលពិពណ៌នា អំពីការងារចុងក្រោយរបស់ព្រះ ជាមួយពិភពលោក ព្រះយេស៊ូវត្រូវបានគេហៅថា “កូនចៀម” ចំនួនសាបសិបមួយដង។ កូនចៀមគឺជាតួអង្គសំខាន់បំផុត នៅក្នុងកម្រិតកំពូលនៃប្រវត្តិសាស្រ្ត។ ទ្រង់ត្រូវបានគេហៅថា កូនចៀម ពីព្រោះការបូជារបស់ទ្រង់ គឺជាមូលដ្ឋានពេញលេញ សម្រាប់មនុស្សមានបាប ដែលត្រូវបានស្តារឡើងវិញ នូវទំនាក់ទំនងប្រកបដោយសេចក្តីស្រឡាញ់ដ៏អស់កល្បជាមួយព្រះអាទិការរបស់ពួកគេ។
- ព្រះបានសម្រេច នូវព្រឹត្តិការណ៍ដ៏ពិសេសនេះទាំងស្រុង ដើម្បីធ្វើឲ្យសេចក្តីសង្គ្រោះជារៀងរហូត អាចកើតមានសម្រាប់មនុស្សទាំងអស់ ដែលកើតមានហើយ និងមិនកើតមានក្តី។ ព្រឹត្តិការណ៍ដ៏ពិសេសបំផុត នៃប្រវត្តិសាស្រ្តទាំងមូលនេះ ត្រូវបានធ្វើឡើងតាមរបៀប ដែលបង្ហាញថា វាអាចត្រូវបាន

សម្រេចដោយដៃរបស់អ្នកបង្កើតដ៏វាងវៃ ដែលសមត្ថភាព និងចំណេះដឹងរបស់យើង មិនអាចយល់បានឡើយ។ មនុស្សស្មោះត្រង់ ដែលបានធ្វើការស៊ើបអង្កេតយ៉ាងជិតដល់ ពួកគេកាន់តែភ្ញាក់ផ្អើលចំពោះគ្រប់ផ្នែកនៃព្រឹត្តិការណ៍។ នៅក្នុងពិភពលោក ដែលពោរពេញទៅដោយការរងទុក្ខ ការឈឺចាប់ និងការភាន់ច្រឡំ ការសុគត និងការរស់ឡើងវិញ របស់ព្រះយេស៊ូវគ្រីស្ទ ផ្ដល់មកនូវក្តីសង្ឃឹម ដល់មនុស្សគ្រប់គ្នា។

ការពន្យល់ព្រះគម្ពីរបន្ថែម៖

# ព្រះរាជលក្ខណៈរបស់ព្រះ

ព្រះគម្ពីរពណ៌នាអំពីរឿងជាច្រើន អំពីអ្វីដែលព្រះបានធ្វើតាំងពីដំបូង នៃពិភពលោក រហូតដល់ទ្រង់បង្កើតពិភពលោកថ្មី នាពេលអនាគត។ យើងរៀនអំពីព្រះពី៖ ១) សិក្សាដំណើររឿងគម្ពីរ អំពីអ្វីដែលទ្រង់បានធ្វើ ក្នុងប្រវត្តិសាស្ត្រមុន និង ២) សិក្សាការពិពណ៌នាដែលគម្ពីរប្រាប់អំពីព្រះ។ យើងក៏រៀនអ្វីៗ អំពីព្រះ ពីការសិក្សាសេចក្តីសន្យារបស់ទ្រង់ ដែលនឹងត្រូវបានរកឃើញ នៅក្នុងផ្នែកចុងក្រោយ នៃសៀវភៅនេះ។

ពេលអ្នកអានព្រះគម្ពីរ សូមសរសេរចម្លើយដែលអ្នករកឃើញ ចំពោះសំណួរខាងក្រោម អំពីថាតើព្រះជានរណា។ សរសេរខយោង និងសេចក្តីសង្ខេបសង្ខេបនៃរឿងនីមួយៗ ដែលអ្នករកឃើញ។ នេះនឹងជួយអ្នកឲ្យពិនិត្យឡើងវិញ នូវចំណុចទាំងនេះនាពេលអនាគត។ នេះគឺជាការសង្ខេបសំណួរទាំងអស់។ ចំណុចនីមួយៗត្រូវបានរាយ នៅក្រោយនៃទំព័រដាច់ដោយឡែកមួយ ដែលមានកន្លែងសម្រាប់សរសេរព័ត៌មាន ដែលអ្នករកឃើញ។ បន្ទាប់ពីសំណួរនីមួយៗ ឧទាហរណ៍មួយចំនួនពីព្រះគម្ពីរ ត្រូវបានផ្តល់រួចហើយ។ អ្នកអាចបន្តបន្ថែមទៀតនៅពេលអ្នករកឃើញ។

១. ទំហំនៃ*អំណាចរបស់ព្រះ*
២. ទំហំនៃ*វត្តមានរបស់ព្រះ*
៣. ទំហំនៃ*សេចក្តីស្រឡាញ់របស់ព្រះ*
   (រួមទាំង*សេចក្តីមេត្តាករុណា* និង*ព្រះគុណរបស់ទ្រង់*)
៤. ទំហំនៃ*ការជ្រាបដឹងរបស់ព្រះ*
៥. ទំហំនៃ*សេចក្តីយុត្តិធម៌របស់ព្រះ*
៦. ទំហំនៃ*ការគ្រប់គ្រង* និង*អធិបតេយ្យភាពរបស់ព្រះ*
៧. ទំហំនៃព្រះ *មិនចេះប្រែប្រួលឡើយ*
៨. ទំហំនៃ*ភាពស្មោះត្រង់របស់ព្រះ*
៩. ទំហំនៃ*ភាពល្អឥតខ្ចោះ* និង*ភាពបរិសុទ្ធរបស់ព្រះ*
១០.ទំហំនៃ*ការជួយរបស់ព្រះ*

នៅទំព័របន្តបន្ទាប់ សំណួរនីមួយៗខាងលើ ត្រូវបានរាយ នៅលើទំព័រដាច់ដោយឡែក។ សរសេរខយោង និងព័ត៌មាន ដែលអ្នករកឃើញ ដើម្បីផ្តល់ចម្លើយចំពោះសំណួរនីមួយៗ។

កាលណាអ្នកកាន់តែយល់អំពីព្រះជានរណា នោះជីវិតអ្នក នឹងកាន់តែផ្លាស់ប្តូរ!

## ១. ទំហំនៃអំណាចរបស់ព្រះ

ជាច្រើនដង ក្នុងព្រះគម្ពីរទាំងមូល ព្រះ ត្រូវបានគេហៅថា ជាអ្នកបង្កើត ឬព្រះអាទិករ។ តាមរបៀបជាច្រើន អ្នកបង្កើតអ្វីមួយ មានអំណាចច្រើនជាងអ្វីដែលត្រូវបានបង្កើត។ មានខជាច្រើនទៀត អំពីអំណាច និងព្រះចេស្តារបស់ព្រះ។

លោកុប្បត្តិ ១:១ "កាលពីដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី"។
ទំនុកតម្កើង ១៤៦:៥-៦ "មានពរហើយ អស់អ្នកដែលមានព្រះរបស់យ៉ាកុប ជាជំនួយរបស់ខ្លួន ជាអ្នកដែលសង្ឃឹមដល់ព្រះយេហូវ៉ា ជាព្រះរបស់ខ្លួន ជាព្រះដែលបង្កើតផ្ទៃមេឃ និងផែនដី ព្រមទាំងសមុទ្រ និងអ្វីៗសព្វសារពើ នៅស្ថានទាំងនោះ។ ព្រះអង្គរក្សាសេចក្ដីស្មោះត្រង់ជារហូត។
ទំនុកតម្កើង ៦៦:៥-៧ ព្រះបានញែកសមុទ្រក្រហម។ " ទ្រង់សោយរាជ្យ ដោយព្រះចេស្តាព្រះអង្គ អស់កល្បជានិច្ច"។

ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ២. ទំហំនៃព្រះវត្តមានរបស់ព្រះ

លោកុប្បត្តិ ២៨:១៦-១៧ - ព្រះបានឲ្យយ៉ាកុប តាមរយៈសុបិន នៅពេលដែលគាត់កំពុងដេកនៅខាងក្រៅ។ នេះបានឲ្យយ៉ាកុបជឿជាក់ថា ព្រះគង់នៅទីនោះ ទោះបីជាគាត់មិនបានដឹង អំពីទ្រង់ទាំងស្រុងក៏ដោយ។
ទំនុកតម្កើង ១៣៩:៧-១០ “តើទូលបង្គំនឹងទីឯណា ឲ្យផុតពីព្រះវត្តមានរបស់ព្រះអង្គបាន? តើទូលបង្គំនឹងរត់ ទៅឯណា ឲ្យផុតពីព្រះវត្តមានរបស់ព្រះអង្គបាន? ប្រសិនបើទូលបង្គំឡើងទៅស្ថានសួគ៌ ព្រះអង្គគង់នៅទីនោះ។ ប្រសិនបើទូលបង្គំរៀបដំណេកនៅស្ថានឃុំព្រលឹងមនុស្សស្លាប់ ព្រះអង្គគង់នៅទីនោះ។ ប្រសិនបើទូលបង្គំពាក់ស្លាបហោះទៅ ទិសព្រះអាទិត្យរះ ហើយទៅរស់នៅឯទីបំផុតនៃសមុទ្រ ក៏គង់តែព្រះហស្តព្រះអង្គ នឹងក្ដាប់ទូលបង្គំជាប់។

ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ៣. ទំហំនៃសេចក្ដីស្រឡាញ់របស់ព្រះ

(រួមទាំង*សេចក្តីមេត្តាករុណា* និង*ព្រះគុណ* របស់ទ្រង់)

<u>ជនគណនា ១៤:១៨</u> "ព្រះយេហូវ៉ាយឺតនឹងខ្ញាល់ ហើយមានសេចក្តីសប្បុរសជាបរិបូរ។ ព្រះអង្គអត់ទោសសេចក្តីទុច្ចរិត និងអំពើរំលង"។

<u>យ៉ូណាស</u> - ព្រះទ្រង់បាន ជម្នះ "បញ្ហា" បន្ថែម ដើម្បីជួយប្រជាជននីនីវេ ដែលជាទីក្រុងសាសន៍ដទៃ ដែលមានកេរ្តិ៍ឈ្មោះអាក្រក់ ក្នុងការរំលោភបំពាន និងធ្វើទារុណកម្មមនុស្សផ្សេងទៀត។ ព្រះចង់នាំពួកគេទៅឯទ្រង់!

<u>លូកា ១៣:៣៤</u> ព្រះទ្រង់ស្រឡាញ់មនុស្សទាំងអស់ រួមទាំងអ្នកដែលស្អប់ និងបះបោរប្រឆាំងនឹងទ្រង់។ នេះត្រូវបានបង្ហាញ ដោយព្រះយេស៊ូវ នៅពេលដែលទ្រង់បានស្រែកថា "ឱយេរូសាឡិម ក្រុងយេរូសាឡិម ជាទីក្រុងដែលសម្លាប់ពួកហោរា ហើយគប់ដុំថ្មលើអស់អ្នកដែលបានចាត់មកឯងអើយ តើប៉ុន្មានដងហើយ ដែលយើងចង់ប្រមូលកូនរបស់ឯង ដូចជាមេមាន់ប្រមូលកូនក្រុងក្រោមស្លាប តែឯងមិនព្រមសោះ"។

សម្គាល់: នៅក្នុងបទគម្ពីរ ព្រះត្រូវបានស្គាល់ដោយសារតួនាទីដូចខាងក្រោម ដែលទាំងអស់នេះរួមបញ្ចូលទាំងសេចក្តីស្រឡាញ់ជាច្រើន។ អ្នកអាចសរសេរខយោងព្រះគម្ពីរ បន្ទាប់ពីតួនាទីនីមួយៗ ដូចដែលអ្នករកឃើញ។

- ព្រះអង្គសង្គ្រោះ

- ឪពុក

- ប្តី

- មិត្តសំឡាញ់

លោកុប្បត្តិ ៦-៩ - ព្រះទ្រង់ស្រឡាញ់មនុស្ស ហើយចង់មានទំនាក់ទំនងប្រកបដោយសេចក្តីស្រឡាញ់ជាមួយពួកគេ ប៉ុន្តែទ្រង់នឹងមិនបង្ខំមនុស្ស ឲ្យស្រឡាញ់ទ្រង់វិញទេ។ ទ្រង់នឹងមិនបង្ខំមនុស្សឲ្យរស់នៅជាមួយទ្រង់ទេ។ នេះត្រូវបានបង្ហាញ នៅពេលព្រះជំនុំជម្រះពិភពលោក ដោយទឹកជំនន់ពាសពេញពិភពលោក។

- ព្រះហឫទ័យរបស់ព្រះពោរពេញទៅដោយការឈឺចាប់ ដោយសារតែភាពអាត្មានិយមរបស់មនុស្ស (លោកុប្បត្តិ ៦: ៦) ។

ការពន្យល់ព្រះគម្ពីរបន្ថែមៈ

## (ត)	៣. ទំហំនៃសេចក្តីស្រឡាញ់របស់ព្រះ

(រួមទាំង *សេចក្តីមេត្តា ករុណា* និង *ព្រះគុណ* របស់ទ្រង់)

(ត) ៣. តើព្រះ*ស្រឡាញ់*មនុស្សដល់កម្រិតណា?

(សេចក្តីស្រឡាញ់របស់ព្រះ រួមមាន*សេចក្តីមេត្តា ករុណា* និង*ព្រះគុណ* របស់ទ្រង់)

## ៤. ទំហំនៃភាពសព្វញ្ញូញាណរបស់ព្រះ

លោកុប្បត្តិ ១៨:១០-១៥ - នៅពេលដែលព្រះអម្ចាស់ និងទេវតាពីររូប បានទៅឯអ័ប្រាហាំ ព្រះអម្ចាស់បានដឹងថា សារ៉ាកំពុងតែគិតយ៉ាងណា ទោះបីនៅពេលដែលទ្រង់មិនមើលឃើញនាងក៏ដោយ។

ទំនុកតម្កើង ១៤៧:៥ "ការយល់ដឹងរបស់ទ្រង់គ្មានព្រំដែន" ។

លូកា ១២:៦-៧ - ព្រះយេស៊ូវបានមានបន្ទូលថា ព្រះស្គាល់អស់ទាំងសរសៃសក់ និងសត្វចាបទាំងអស់។

ទំនុកតម្កើង ១៣៩:១-៤ - ព្រះទ្រង់ស្គាល់គំនិត ដែលមនុស្សមាន។

លូកា ១៦:១៥ - ព្រះជ្រាប ពីបំណងចិត្តរបស់មនុស្សទាំងអស់ "អ្នករាល់គ្នាគឺជាមនុស្ស ដែលរប់ខ្លួនឯងជាមនុស្សសុចរតិ តែព្រះស្គាល់ចិត្តអ្នករាល់គ្នាវិញ" ។

ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ៥. ទំហំនៃភាពយុត្តិធម៌របស់ព្រះ

ព្រះទ្រង់ស្រឡាញ់មនុស្ស ហើយចង់បានទំនាក់ទំនងប្រកបដោយសេចក្ដីស្រឡាញ់ជាមួយពួកគេ ប៉ុន្តែទ្រង់នឹងមិនបង្ខំមនុស្សឲ្យស្រឡាញ់ទ្រង់វិញទេ។ ទ្រង់នឹងមិនបង្ខំមនុស្សឲ្យរស់នៅជាមួយទ្រង់ទេ។

លោកុប្បត្តិ ២:១៧ - ព្រះបានប្រាប់អ័ដាម និងអេវ៉ាថា នៅពេលណាដែលមនុស្សធ្វើបាប ពួកគេនឹងស្លាប់។ នេះត្រូវបានបង្ហាញ នៅពេលព្រះជំនុំជម្រះពិភពលោក ដោយទឹកជំនន់ពាសពេញពិភពលោក។

លោកុប្បត្តិ ៦ - ៩ -

- ព្រះហឫទ័យរបស់ព្រះពោរពេញទៅដោយការឈឺចាប់ ដោយសារតែភាពអាត្មានិយមរបស់មនុស្ស (លោកុប្បត្តិ ៦: ៦) ។
- ណូអេបាននិយាយទៅកាន់ប្រជាជនអំពីព្រះ (ពេត្រុសទី២ ២:៥) ប៉ុន្តែ គ្មាននរណាម្នាក់ចង់ចូលរួមជាមួយណូអេទេ ដូច្នេះព្រះបានធ្វើការជំនុំជម្រះ លើអំពើបាបទាំងអស់។
- យើងអាចដឹងប្រាកដថា មនុស្សគ្រប់គ្នាស្អប់ទឹកជំនន់ ប៉ុន្តែព្រះមិនបានជួយសង្គ្រោះពួកគេទេ ពីព្រោះពួកគេក៏មិនចង់បានព្រះដែរ។ ពួកគេចង់បានរបស់ល្អៗ ដែលព្រះបានប្រទានដល់ពួកគេ ប៉ុន្តែពួកគេមិនចង់បានព្រះជាអង្គទ្រង់ទេ។

ការពន្យល់ព្រះគម្ពីរបន្ថែម៖

ភាពយុត្តិធម៌របស់ព្រះ ក្នុងការទាក់ទងជាមួយប្រជាជាតិនានា ក្នុងប្រវត្តិសាស្ត្រ

មនុស្សជាច្រើនបាននិយាយថា ព្រះមិនស្រឡាញ់ និងអយុត្តិធម៌ណាស់ នៅពេលដែលទ្រង់បានទាមទារឲ្យសាសន៍អ៊ីស្រាអែលបំផ្លាញក្រុមមនុស្សជាច្រើន នៅប៉ាឡេស្ទីន។ សូមអានបទគម្ពីរខាងក្រោមនេះ អធិស្ឋាន ហើយធ្វើការសម្រេចចិត្តរបស់អ្នក។

ចោទិយកថា ៩:៤-៦, ១៨: ៩-១៣, ទំនុកតម្កើង ១០៦:៣៤-៣៨ - ហេតុផលរបស់ព្រះ ក្នុងការបំផ្លាញក្រុមមនុស្ស

លេវីវិន័យ ២៦:១៤-៣៩, ចោទិយកថា ២៨:១៥-៦៨ - ព្រះនឹងរឹតតែធ្ងន់ធ្ងរថែមទៀត ចំពោះសាសន៍អ៊ីស្រាអែល ប្រសិនបើពួកគេបានធ្វើដូចគ្នា - (ទាំងអស់ ដែលក្រោយមកព្រះបានធ្វើ ចំពោះអ៊ីស្រា អែល តាមរយៈស្រុកអាសស៊ើរ បាប៊ីឡូន និងរ៉ូម)

លោកុប្បត្តិ ២:១៥-១៧, រ៉ូម ៦:២៣, វិវរណៈ ២១:៨ - ព្រះមានបទដ្ឋានដូចគ្នា សម្រាប់មនុស្សទាំងអស់ ក្នុងប្រវត្តិសាស្ត្រ។

## ៦. ទំហំនៃការគ្រប់គ្រង និងអធិបតេយ្យភាពរបស់ព្រះ

លោកុប្បត្តិ ៣៧ - ៤៧ - ព្រឹត្តិការណ៍ជាច្រើន នៅក្នុងជីវិតរបស់យ៉ូសែប បានកើតឡើងចំពោះគាត់ ដើម្បីធ្វើឲ្យគាត់ក្លាយជាអ្នកគ្រប់គ្រង នៅក្បែរព្រះចៅផារ៉ោន ហើយក្រោយមក ជួយសង្គ្រោះបងប្អូនរបស់គាត់។ ឈ្មួញសាសន៍ម៉ាឌាន បានមកក្បែតបងប្អូនរបស់គាត់ នៅពេលពួកគេសម្រេចចិត្តធ្វើអ្វីមួយ។ យ៉ូសែប ត្រូវបានលក់ជាទាសកររបស់លោកប៉ូទីផារ។ អ្នកថ្វាយពែង និងអ្នកដុតនំ ត្រូវបានគេចាប់ដាក់គុក ជាមួយគាត់ ហើយពួកគេទាំងពីរនាក់ បានយល់សុបិន្ត ហើយក្រោយមក ព្រះចៅផារ៉ោន ក៏បានយល់សុបិន្ត។

លោកុប្បត្តិ ៥០:១៩-២០ - ព្រះបានប្រើព្រឹត្តិការណ៍អាក្រក់ ដើម្បីសម្រេចផែនការល្អរបស់ទ្រង់។

ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ៧. ទំហំនៃភាពមិនចេះប្រែប្រួលរបស់ព្រះ

<u>សាំយូអែលទី១ ១៥:២៩</u> - ព្រះមិនចេះប្រែប្រួល

<u>ហេព្រើរ ១៣:៨</u> - “ព្រះយេស៊ូវគ្រីស្ទ គឺនៅដដែល កាលពីម្សិលមិញ ថ្ងៃនេះ និងរហូតតទៅ”។

<u>យ៉ាកុប ១:១៧</u> - ព្រះមិនដែលផ្លាស់ប្តូរ

ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ៨. ទំហំនៃភាពស្មោះត្រង់របស់ព្រះ

<u>លោកុប្បត្តិ ១៣:១៤-១៧</u> - ព្រះបានប្រាប់អ័ប្រាហាំថា កូនចៅរបស់គាត់ នឹងទទួលទឹកដីប៉ាឡេស្ទីនជានិច្ច រហូតដល់សព្វថ្ងៃនេះ នៅតែជាការពិតទោះបីមានការសម្លាប់ និងការបំផ្លិចបំផ្លាញ ដែលពួកយូដាបានឆ្លងកាត់ក៏ដោយ។

<u>លោកុប្បត្តិ ៤៩:៨-១០</u> ប្រៀបធៀបនឹង <u>វិវរណៈ ៥:៥</u> ។ ព្រះទ្រង់បានប្រាប់យ៉ាកុបថា អ្នកគ្រប់គ្រងនាពេលអនាគត (មេស្ស៊ី) នឹងយាងចេញមកពីកូនចៅយូដា។ ក្រោយមក រឿងនេះត្រូវបានកត់ត្រានៅក្នុង វិវរណៈ។ ព្រះយេស៊ូវ មកពីកុលសម្ព័ន្ធយូដា។

<u>ទំនុកតម្កើង ១៤៦:៦</u> "... ព្រះដែលបង្កើតយើង ... ព្រះអម្ចាស់ទ្រង់នៅតែស្មោះត្រង់រហូតតទៅ"។

ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ៩. ទំហំនៃភាពល្អឥតខ្ចោះ និងភាពបរិសុទ្ធរបស់ព្រះ

យ៉ូស្វេ ៧:១-២៦ - ព្រះបានណែនាំកងទ័ពអ៊ីស្រាអែល ឲ្យបំផ្លាញក្រុងយេរីខូរទាំងស្រុង ហើយកុំយករបស់អ្វីផ្សេងទៀតសម្រាប់ខ្លួនគេឡើយ។ ដោយសារតែមានតែទាហានម្នាក់ប៉ុណ្ណោះ ដែលបានយករបស់ខ្លះសម្រាប់ខ្លួនគាត់ ពីក្រុងយេរីខូរ ព្រះមិនបានជួយកងទ័ពអ៊ីស្រាអែលទេ នៅពេលដែលវាវាយប្រហារទីក្រុង បន្ទាប់។ ទាហានបានស្លាប់ ដោយសារតែរឿងនេះ។ តហូតទាល់តែអំពើបាបរបស់អេកានត្រូវបានដោះស្រាយជាមួយនឹងព្រះ ទើបទ្រង់បានជួយកងទ័ពម្តងទៀត។

វិវរណៈ ៤:៨ - “បរិសុទ្ធ បរិសុទ្ធ បរិសុទ្ធ គឺព្រះអម្ចាស់ ជាព្រះដែលមានគ្រប់ព្រះចេស្ដា”។

ហាបាគុក ១:១៣ - ព្រះនេត្ររបស់ព្រះស្អាតស្អំណាស់ ដែលទ្រង់មិនអាចទតមើលអំពើអាក្រក់បានឡើយ។ (ជាក់ស្តែង ព្រះទតឃើញអំពើអាក្រក់ទាំងអស់ តែមានវិធីខ្លះ ដែលទ្រង់មិនចង់ឃើញ។ )

ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ១០. ទំហំនៃការជួយរបស់ព្រះ

ព្រះតែងតែបង្រៀនមនុស្សគ្រប់គ្នា នៅលើពិភពលោក ក្នុងគ្រប់ទិដ្ឋភាព នៃជីវិតរបស់ពួកគេ។ ទ្រង់តែងតែជួយពួកគេ ឲ្យស្គាល់កាន់តែច្បាស់ថា ទ្រង់ជានរណា និងរបៀបដែលពួកគេអាចពិសោធន៍ នូវសេចក្តីពេញលេញរបស់ទ្រង់។

<u>ហេព្រើរ ១២:៤-១១</u> - ព្រះទ្រង់ប្រើការសាកល្បង ដើម្បីបង្ហាត់យើង។

<u>ទំនុកតម្កើង ៧១:១៧</u> - ព្រះទ្រង់បានបង្រៀន អ្នកតែងទំនុកតម្កើង តាំងពីវ័យក្មេង។

<u>ទំនុកតម្កើង ៩៤:១០-១៤</u> - ព្រះទ្រង់បង្រៀនមនុស្ស។

<u>ទំនុកតម្កើង ៣២:៨</u> - ព្រះទ្រង់ដឹកនាំ និងណែនាំយើង។

<u>ចោទិយកថា ៨:២-៥</u> - ព្រះទ្រង់បង្រៀនយើង ហើយប្រៀនប្រដៅយើង។

ការពន្យល់ព្រះគម្ពីរបន្ថែម៖

# សេចក្តីសន្យារបស់ព្រះ

ពេត្រុសបានសង្ខេបយ៉ាងល្អ ពីមូលហេតុដែលសេចក្តីសន្យារបស់ព្រះ មានសារៈសំខាន់បំផុត៖

> “ព្រះចេស្តារបស់ព្រះអង្គ បានប្រទានឲ្យយើងមានអ្វីៗទាំងអស់ខាងឯជីវិត និងការគោរពប្រតិបត្តិដល់ព្រះ តាមរយៈការស្គាល់ព្រះអង្គដែលបានត្រាស់ហៅយើង ដោយសារសិរីល្អ និងសេចក្តីល្អរបស់ព្រះអង្គ ដោយសារសេចក្តីទាំងនេះ ព្រះអង្គបានប្រទានសេចក្តីសន្យាដ៏វិសេស និងធំបំផុតដល់យើង ដើម្បីឲ្យអ្នករាល់គ្នាបានចំណែកជានិស្ស័យនៃព្រះ ដោយសារសេចក្តីនោះឯង ទាំងបានរួចផុតពីសេចក្តីពុករលួយដែលនៅក្នុងលោកីយ៍នេះ ដោយសារសេចក្តីប៉ងប្រាថ្នា។ ហេតុនេះ ត្រូវខំប្រឹងឲ្យអស់ពីសមត្ថភាព ដើម្បីបន្ថែមកិរិយាល្អពីលើជំនឿរបស់អ្នករាល់គ្នា ហើយបន្ថែមការស្គាល់ព្រះពីលើកិរិយាល្អ” (ពេត្រុសទី២ ១:៣-៥)។

ខាងក្រោមនេះគឺជាសេចក្តីសង្ខេប នៃសេចក្តីសន្យា ដែលព្រះបានប្រទាន និងត្រូវបានរាយតាមប្រភេទទូទៅ។

១. សេចក្តីសន្យារបស់ព្រះ អំពីសេចក្តីសង្គ្រោះ / ការផ្សះផ្សា
២. សេចក្តីសន្យារបស់ព្រះ អំពីវត្តមានរបស់ទ្រង់
៣. សេចក្តីសន្យារបស់ព្រះ អំពីភាពជាអ្នកដឹកនាំ / ការណែនាំ
៤. សេចក្តីសន្យារបស់ព្រះ អំពីការការពារ
៥. សេចក្តីសន្យារបស់ព្រះ អំពីប្រាជ្ញា / ចំណេះដឹង / ការយល់ដឹង
៦. សេចក្តីសន្យារបស់ព្រះ អំពីការផ្គត់ផ្គង់ / អំណោយទាន
៧. សេចក្តីសន្យារបស់ព្រះ អំពីការព្យាបាល / ការស្តារឡើងវិញ
៨. សេចក្តីសន្យារបស់ព្រះ អំពីជំនួយ / កម្លាំង
៩. សេចក្តីសន្យារបស់ព្រះ អំពីការសាកល្បង និងការរងទុក្ខ
១០.សេចក្តីសន្យារបស់ព្រះ អំពីទំនាក់ទំនងរបស់ទ្រង់ ជាមួយយើង

ពេលអ្នកអានព្រះគម្ពីរ សូមសរសេរសេចក្តីសន្យា ដែលអ្នករកឃើញ យោងទៅតាមទិដ្ឋភាពផ្សេងៗ នៃជីវិតដែលយើងទាំងអស់គ្នាត្រូវការ។ សរសេរខយោង និងសេចក្តីសង្ខេបសង្ខេប នៃឯកសារនីមួយៗ ដែលអ្នករកឃើញ។ នេះនឹងជួយអ្នកឲ្យពិនិត្យឡើងវិញ នាពេលអនាគត។ ខាងក្រោមនេះ គឺជាទំព័រដែលអ្នកអាចសរសេរសេចក្តីសន្យាដែលអ្នករកឃើញ។ ទំព័រនីមួយៗមានកន្លែងទំនេរ សម្រាប់ប្រភេទនីមួយៗ អំពីសេចក្តីសន្យា។ នៅក្នុងប្រភេទនីមួយៗ មានឧទាហរណ៍មួយចំនួន អំពីសេចក្តីសន្យាដែលបានផ្តល់រួចហើយ។ អ្នកអាចបន្តបន្ថែមទៀត នៅពេលអ្នករកឃើញវា។

## ១. សេចក្តីសន្យារបស់ព្រះអំពីសេចក្តីសង្គ្រោះ / ការផ្សះផ្សា

<u>និក្ខមនំ ៦:៧</u> "យើងនឹងយកអ្នកធ្វើជាប្រជារាស្ត្ររបស់ហើយ ហើយយើងនឹងធ្វើជាព្រះរបស់អ្នក"។
<u>យ៉ូហាន ១:១២</u> "ប៉ុន្តែ ចំពោះអស់អ្នកណាដែលបានទទួលទ្រង់ ចំពោះអស់អ្នកដែលជឿលើព្រះនាមទ្រង់ នោះទ្រង់បានប្រទានសិទ្ធិ ឲ្យក្លាយជាកូនរបស់ព្រះ" ។
<u>រ៉ូម ៦:២៣</u> "ដ្បិតឈ្នួលនៃអំពើបាបគឺសេចក្តីស្លាប់ តែអំណោយទានរបស់ព្រះវិញ គឺជាជីវិតអស់កល្បជានិច្ច តាមរយៈព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង"។
<u>យ៉ូហានទី១ ៥:១១-១៣</u> "នេះជាទីបន្ទាល់៖ ព្រះបានប្រទានជីវិតអស់កល្បដល់យើង ហើយជីវិតនេះ គឺនៅក្នុងព្រះរាជបុត្រាទ្រង់។ អ្នកណាមានព្រះបុត្រាអ្នក នោះមានជីវិតហើយ។ អ្នកណាគ្មានព្រះបុត្រារបស់ព្រះ អ្នកនោះគ្មានជីវិតនេះឡើយ។ ខ្ញុំសរសេរសេចក្តីទាំងនេះមកអ្នករាល់គ្នា ដែលជឿលើព្រះនាមព្រះបុត្រារបស់ព្រះ ដើម្បីឲ្យអ្នករាល់គ្នាដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ច"។
ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ២. សេចក្តីសន្យារបស់ព្រះ អំពីព្រះវត្តមានរបស់ទ្រង់

<u>លោកុប្បត្តិ ២៨:១៥</u> “យើងនឹងនៅជាមួយអ្នក ហើយនឹងឃ្លាំមើលអ្នក គ្រប់ទីកន្លែងដែលអ្នកទៅ”។

<u>យ៉ូស្វេ ១:៩</u> “ ... ព្រះអម្ចាស់ជាព្រះរបស់អ្នក នឹងនៅជាមួយអ្នកគ្រប់ទីកន្លែងដែលអ្នកទៅ”។

<u>ម៉ាថាយ ២៨:២០</u> “ប្រាកដជាខ្ញុំនៅជាមួយអ្នករាល់គ្នា រហូតដល់ចុងបំផុតនៃអស់ទាំងកល្ប” ។

ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ៣. សេចក្តីសន្យារបស់ព្រះ អំពីការដឹកនាំ / ការតម្រង់ផ្លូវ

ទំនុកតម្កើង ៣២:៨ "យើងនឹងបង្ហាត់បង្រៀនឲ្យអ្នកស្គាល់ផ្លូវដែលអ្នកត្រូវដើរ យើងនឹងទូន្មានអ្នក ដោយភ្នែកយើងមើលអ្នកជាប់"។

សុភាសិត ៣:៥-៦ "ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ។ ត្រូវទទួលស្គាល់ព្រះអង្គនៅគ្រប់ទាំងផ្លូវឯងចុះ ព្រះអង្គនឹងតម្រង់អស់ទាំងផ្លូវច្រករបស់ឯង។"។

ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ៤. សេចក្តីសន្យារបស់ព្រះ អំពីការការពារ

<u>ទំនុកតម្កើង ៣៤:១៩</u> "មនុស្សសុចរិតរងទុក្ខលំបាកច្រើន តែព្រះយេហូវ៉ារំដោះគេ ឲ្យរួចពីទុក្ខលំបាកទាំងអស់"។
<u>ទំនុកតម្កើង ៤៦:១</u> "ព្រះជាទីពឹងជ្រក និងជាកម្លាំងរបស់យើង ជាជំនួយដែលនៅជាប់ជាមួយ" ។
<u>ថែស្សាឡូនីចទី២ ៣:៣</u> "ព្រះអម្ចាស់ទ្រង់ស្មោះត្រង់ ព្រះអង្គនឹងតាំងអ្នករាល់គ្នា ឲ្យមាំមួនឡោះង ហើយការពារអ្នករាល់គ្នាពីមេកំណាច។"

ការពន្យល់ព្រះគម្ពីរបន្ថែមៈ

## ៥. សេចក្ដីសន្យារបស់ព្រះ អំពីប្រាជ្ញា / ចំណេះដឹង / ការយល់ដឹង

យ៉ូហាន ១៤:២៦ "ប៉ុន្តែ ព្រះដ៏ជាជំនួយ គឺព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះវរបិតានឹងចាត់មកក្នុងនាមខ្ញុំ ទ្រង់នឹងបង្រៀនសេចក្ដីទាំងអស់ដល់អ្នករាល់គ្នា ហើយរំឭកអស់ទាំងអ្វីៗដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាផង"។
យ៉ាកុប ១:៥ "ប្រសិនបើអ្នកណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាខ្វះប្រាជ្ញា អ្នកនោះត្រូវទូលសូមពីព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា ដ្បិតទ្រង់នឹងប្រទានឲ្យ ឥតបន្ទោសឡើយ"។
ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ៦. សេចក្តីសន្យារបស់ព្រះ អំពីការផ្គត់ផ្គង់ / អំណោយទាន

ភីលីព ៤:១៩ “ព្រះនៃខ្ញុំ ព្រះអង្គនឹងបំពេញគ្រប់ទាំងអស់ដែលអ្នករាល់គ្នាត្រូវការ តាមភោគសម្បត្តិនៃទ្រង់ដ៏ឧត្តម ក្នុងព្រះគ្រីស្ទយេស៊ូវ”។

យ៉ូហានទី១ ៥:១៤-១៥ “នេះជាទំនុកចិត្តដែលយើងមានចំពោះព្រះអង្គ គឺថា បើយើងទូលសូមអ្វីស្របតាមព្រះហឫទ័យព្រះអង្គ នោះព្រះអង្គនឹងស្តាប់យើង។ បើយើងដឹងថា ព្រះអង្គស្តាប់យើងក្នុងការអ្វីដែលយើងទូលសូម នោះយើងដឹងថា យើងបានអ្វីដែលយើងបានសូមពីព្រះអង្គនោះហើយ”។

ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ៧. សេចក្ដីសន្យារបស់ព្រះ អំពីការព្យាបាល / ការស្ដារឡើងវិញ

និក្ខមនំ ៦:៦ "យើងនឹងព្យាបាលអ្នក ពីការធ្វើជាបាវបម្រើដល់គេ"។ (ទីមួយ ចំពោះសាសន៍អ៊ីស្រាអែល ហើយជាគោលការណ៍អនុវត្ត ចំពោះយើងដែលត្រូវបានដោះលែង ពីទាសភាពនៃអំពើបាប)។

និក្ខមនំ ១៥:២៦ "យើងជាព្រះអម្ចាស់ ដែលព្យាបាលអ្នក។"

ទំនុកតម្កើង ១០៣:២-៣ "ឱព្រលឹងខ្ញុំអើយ ចូរថ្វាយព្រះពរព្រះយេហូវ៉ា ហើយកុំឲ្យភ្លេចអស់ទាំងព្រះគុណរបស់ព្រះអង្គ ដែលព្រះអង្គអត់ទោស គ្រប់ទាំងអំពើទុច្ចរិតរបស់ឯង ក៏ប្រោសជំងឺទាំងប៉ុន្មានរបស់ឯងឲ្យបានជា"។

ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ៨. សេចក្តីសន្យារបស់ព្រះ អំពីជំនួយ / កម្លាំង

លោកុប្បត្តិ ៥០:២០ «បងៗមានបំណងធ្វើបាបខ្ញុំ តែព្រះទ្រង់ធ្វើឲ្យការនោះប្រែទៅជាល្អ ដើម្បីជួយសង្គ្រោះជីវិតមនុស្សជាច្រើន ដូចជាបានកើតមានសព្វថ្ងៃនេះ។»។
និក្ខមនំ ៦:៦ “យើងនឹងប្រោសលោះអ្នករាល់គ្នា ដោយលើកដៃយើងឡើង”។ (សំដៅដល់ សាសន៍អ៊ីស្រាអែលជាមុន ហើយបន្ទាប់មកយើងគ្រប់គ្នា) ។
រ៉ូម ៨:៣៥-៣៧ “តើអ្នកណាអាចពង្រាត់យើងចេញពីសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទបាន? តើទុក្ខលំបាក ឬសេចក្តីវេទនា ការបៀតបៀន ការអត់ឃ្លាន ភាពអាក្រាត សេចក្តីអន្តរាយ ឬមួយដាវ? ដូចមានសេចក្តីចែងទុកមកថា៖ «ដោយព្រោះព្រះអង្គ យើងត្រូវគេសម្លាប់រាល់ព្រឹករាល់ល្ងាច គេរាប់យើងទុកដូចជាចៀមដែលត្រូវគេយកទៅសម្លាប់»។ ទេ ក្នុងគ្រប់សេចក្តីទាំងនេះ យើងវិសេសលើសជាងអ្នកដែលមានជ័យជម្នះទៅទៀត តាមរយៈព្រះអង្គដែលបានស្រឡាញ់យើង”។
ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ៩. សេចក្តីសន្យារបស់ព្រះ អំពីការសាកល្បង និងការរងទុក្ខ

<u>កូរិនថូសទី២ ៤:១៦-១៧</u> - ការសាកល្បងបណ្តោះអាសន្នរបស់យើង ជួយផ្នែកខាងក្នុងរបស់យើង និង សម្រេចបាននូវសិរីល្អអស់កល្បជានិច្ច។

<u>យ៉ាកុប ១:២-៤</u> - ចូរអរគុណចំពោះការសាកល្បង ពីព្រោះអ្នកដឹងថា ការទាំងនោះកំពុងស្អាងចរិតរបស់អ្នក រាល់គ្នា។

កូរិនថូសទី២ ១២:៧-១០ - ព្រះចេស្តារបស់ព្រះ ត្រូវបានបង្ហាញឲ្យឃើញច្បាស់ នៅពេលយើងទន់ខ្សោយ។

ការពន្យល់ព្រះគម្ពីរបន្ថែម៖

## ១០. សេចក្ដីសន្យារបស់ព្រះ អំពីទំនាក់ទំនងរបស់ទ្រង់ជាមួយយើង

យ៉ូហាន ១៤:២១ - "អ្នកណាដែលមានបទបញ្ញារបស់ខ្ញុំ ហើយធ្វើតាម គឺអ្នកនោះហើយដែលស្រឡាញ់ខ្ញុំ ព្រះវរបិតាខ្ញុំស្រឡាញ់អ្នកណាដែលស្រឡាញ់ខ្ញុំ ហើយខ្ញុំក៏ស្រឡាញ់អ្នកនោះ ក៏នឹងសម្ដែងខ្លួនឲ្យអ្នកនោះស្គាល់ទៀតផង"។

យ៉ូហាន ១៤:៣ - "បើខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា នោះខ្ញុំនឹងត្រឡប់មកវិញ ហើយទទួលអ្នករាល់គ្នាទៅឯខ្ញុំ ដើម្បីឲ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅនោះដែរ"។

យ៉ូហាន ១៤:១២ - "ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលជឿដល់ខ្ញុំ នឹងធ្វើកិច្ចការដែលខ្ញុំធ្វើដែរ ហើយក៏នឹងធ្វើការធំជាងនេះទៅទៀត ព្រោះខ្ញុំទៅឯព្រះវរបិតា"។

# ការទទួលស្គាល់ និងវិញ្ញាបនបត្រ

នៅពេលមនុស្សម្នាក់ បំពេញនូវតម្រូវការសម្រាប់ចំណុចខាងក្រោម នោះនឹងទទួលបានវិញ្ញាណបនបត្រមួយ៖

១. សៀវភៅ ១ - មូលដ្ឋានគ្រឹះអំពីព្រះ

២. សៀវភៅ ២ - មូលដ្ឋានគ្រឹះ នៃការបណ្តុះបណ្តាលរបស់ព្រះ

៣. សៀវភៅ ៣ - មូលដ្ឋានគ្រឹះ នៃគ្រួសាររបស់ព្រះ

៤. អានព្រះគម្ពីរចប់សព្វគ្រប់

៥. ការបណ្តុះបណ្តាលជាក់ស្តែង ដើម្បីក្លាយជាឪពុកម្តាយខាងវិញ្ញាណ

ស្ត្រី ដែលបំពេញនូវតម្រូវការដូចខាងក្រោម អាចត្រូវបានគេទទួលស្គាល់ថា ជា*គ្រូបណ្តុះបណ្តាលស្ត្រីម្នាក់* ហើយនឹងទទួលបានវិញ្ញាបនបត្រផងដែរ។

១. សៀវភៅ ១ - មូលដ្ឋានគ្រឹះអំពីព្រះ

២. សៀវភៅ ២ - មូលដ្ឋានគ្រឹះ នៃការបណ្តុះបណ្តាលរបស់ព្រះ

៣. សៀវភៅ ៣ - មូលដ្ឋានគ្រឹះ នៃគ្រួសាររបស់ព្រះ

៤. អានព្រះគម្ពីរចប់សព្វគ្រប់

៥. ការបណ្តុះបណ្តាលជាក់ស្តែង ដើម្បីក្លាយជាឪពុកម្តាយខាងវិញ្ញាណ តាមរយៈជំហានទី ១០ (នៅចុងបញ្ចប់ នៃសៀវភៅ ៣ - មូលដ្ឋានគ្រឹះ នៃគ្រួសាររបស់ព្រះ)

៦. ការយល់ព្រម ពីអ្នកដឹកនាំពួកជំនុំរបស់នាង ស្វាមីរបស់នាង (ប្រសិនបើរៀបការ) និងសមាជិក នៃពួកជំនុំរបស់នាង ឲ្យធ្វើជាគ្រូបណ្តុះបណ្តាលស្ត្រី

បុរស ដែលបំពេញនូវតម្រូវការដូចខាងក្រោម អាចត្រូវបានគេទទួលស្គាល់ថា ជា*ព័ន្ធការី ដែលមានមុខងារ*។

១. សៀវភៅ ១ - មូលដ្ឋានគ្រឹះអំពីព្រះ

២. សៀវភៅ ២ - មូលដ្ឋានគ្រឹះ នៃការបណ្តុះបណ្តាលរបស់ព្រះ

៣. សៀវភៅ ៣ - មូលដ្ឋានគ្រឹះ នៃគ្រួសាររបស់ព្រះ

៤. អានព្រះគម្ពីរចប់សព្វគ្រប់

៥. ការបណ្តុះបណ្តាលជាក់ស្តែង ដើម្បីក្លាយជាឪពុកម្តាយខាងវិញ្ញាណ និងបន្តដឹកនាំក្រុម ដែលកំពុងរីកចម្រើន នៅក្នុងជីវិតរបស់ពួកគេជាមួយព្រះគ្រីស្ទ (នៅចុងបញ្ចប់ នៃសៀវភៅ ៣ - មូលដ្ឋានគ្រឹះនៃគ្រួសាររបស់ព្រះ)

៦. ការយល់ព្រមពីមេដឹកនាំពួកជំនុំ ភរិយារបស់គាត់ (ប្រសិនបើរៀបការ) និងសមាជិកពួកជំនុំរបស់គាត់ ឲ្យធ្វើជាគ្រូគង្វាល

៧. ការយល់ព្រមពីគ្រូគង្វាល ដែលស្គាល់គាត់ច្បាស់ថា គាត់បំពេញតាមលក្ខណៈសម្បត្តិ របស់អ្នកចាស់ទុំម្នាក់ ក្នុង ធីម៉ូថេទី១ ៣ និង ទីតុស ១

បុរស ដែលបំពេញតម្រូវការទាំងអស់នេះ នឹងត្រូវបានគេទទួលស្គាល់ថា ***ជាព័ន្ធការីដែលមានមុខងារ*** ហើយនឹងទទួលបានវិញ្ញាណបនបត្រ បញ្ជាក់ការទទួលស្គាល់នេះ។